KH/2009/CL/LAW/27
Phnom Penh, March 2009
Original: English

United Nations Educational, Scientific and Cultural Organization

Intangible Cultural Heritage

MDG-F
Culture and Development – Cambodia
Creative Industries Support Programme

# អនុសញ្ញា

# ស្តីពី

# ការការពារបេតិកភណ្ឌវប្បធម៌អរូបិយ

ឯកសារគ្រឹះ

United Nations
Educational, Scientific and
Cultural Organization

Intangible
Cultural
Heritage

Culture and Development – Cambodia
Creative Industries Support Programme

# អនុសញ្ញា
# ស្ដីពី
# ការការពារបេតិកភណ្ឌវប្បធម៌អរូបិយ

ឯកសារគ្រឹះ

ខែមិនា ឆ្នាំ២០០៩

# អនុសញ្ញា
# ស្តីពី
# ការការពារបេតិកភណ្ឌវប្បធម៌អរូបិយ

ឯកសារគ្រឹះ

ប្រែសម្រួលជាភាសាខ្មែរក្រៅផ្លូវការពីច្បាប់ដើមជាភាសាអង់គ្លេស

ខែមិនា ឆ្នាំ២០០៩

# មាតិកា


**សេចក្ដីផ្ដើម............................................................................................... ៦**

**អនុសញ្ញាស្ដីពី ការការពារបេតិកភណ្ឌវប្បធម៌អរូបី............................................១០**

**សេចក្ដីណែនាំប្រតិបត្តិស្ដីពីការអនុវត្តអនុសញ្ញាស្ដីពីការអភិរក្ស ...........................២៨**

*ជំពូកទី I: ការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ................................................ ៣០*

១.១ ការចុះឈ្មោះចូលទៅក្នុងបញ្ជីអភិរក្សបន្ទាន់ ........................................ ៣០

១.២ ការចុះឈ្មោះចូលទៅក្នុងបញ្ជីតំណាង ................................................ ៣៦

១.៣ ការដាក់បញ្ចូលបេតិកភណ្ឌដែលបានប្រកាសជាសាធារណៈថាជា “ស្នាដៃឯកនៃបេតិកភណ្ឌ អរូបបិយមនុស្សជាតិ” ទៅក្នុងបញ្ជីតំណាង ........................ ៤០

១.៤ កម្មវិធី គម្រោង និងសកម្មភាពដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីគោលការណ៍ និងគោលបំណង នៃអនុសញ្ញានេះ............................................................... ៤៣

*ជំពូកទី II: ជំនួយអន្តរជាតិ និង មូលនិធិបេតិកភណ្ឌវប្បធម៌អរូបិយ............................. ៤៦*

២.១ គោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់ធនធាននៃមូលនិធិ ........................ ៤៦

២.២ ជំនួយអន្តរជាតិ............................................................................ ៤៧

*ជំពូកទី III: ការចូលរួមនៅក្នុងការអនុវត្តអនុសញ្ញា............................................... ៥១*

៣.១ ការចូលរួមរបស់សហគមន៍ ក្រុម និង បើសិនជាអាចចំពោះក្រុមផ្សេងទៀត ដូចជាបុគ្គលអ្នកជំនាញ មជ្ឈមណ្ឌលឯកទេស និងវិទ្យាស្ថាន ស្រាវជ្រាវ............. ៥១

៣.៣ អង្គការក្រៅរដ្ឋាភិបាលនានា និង អនុសញ្ញា ........................................ ៥៣

*ជំពូកទី IV: ការផ្ញើរបាយការណ៍ទៅគណៈកម្មាធិការ............................................ ៥៧*

**ទម្រង់សម្រាប់ការចុះបញ្ជី សំណើ និងការស្នើសុំ......................................................... ៦១**

**មហាសន្និបាតរដ្ឋភាគីនៃអនុសញ្ញាស្ដីអំពីការអភិរក្សបេតិកភណ្ឌ វប្បធម៌ អរូបិយ.......................៧២**

**បញ្ញត្តិនៃនីតិវិធី**

**គណៈកម្មាធិការអន្តររដ្ឋាភិបាលស្ដីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ ..........................៨២**

**បញ្ញត្តិនៃនីតិវិធី**

**បទបញ្ញត្តិហិរញ្ញវត្ថុនៃគណនេយ្យពិសេសសម្រាប់បេតិកភណ្ឌអរូបិយ..................................៩៨**

**បែបបទគំរូនៃការផ្ញើសច្ចាប័ន/ការទទួលយក/ការអនុម័ត/ការយល់ព្រម.............................១០៣**

# សេចក្តីផ្តើម

នៅខណៈដែលខ្ញុំបានឈានជើងចូលមកកាន់អង្គការយូណេស្កូនៅឆ្នាំ១៩៩៩ខ្ញុំបានចាត់ទុកការ អភិរក្ស បេតិកភណ្ឌវប្បធម៌អរូបិយជាអាទិភាពមួយភ្លាមក្នុងចំណោមអាទិភាពទាំងឡាយរបស់អង្គការនេះ។ ជាការពិតណាស់ ខ្ញុំគិតថាវាជាកិច្ចការបន្ទាន់មួយក្នុងការចាត់វិធានការថែរក្សាបេតិកភណ្ឌដែលផុយស្រួយងាយអន្តរាយ និងដែលកំពុងប្រឈមទៅនឹងការបាត់បង់ ហើយដែលរហូតមកដល់ពេលនោះមិនទាន់ទទួលបានការយកចិត្តទុកដាក់ថែរក្សាគ្រប់គ្រាន់ពីអង្គការ យើងខ្ញុំនៅឡើយ។

វិធីសាស្ត្រពីររួមគ្នាត្រូវបានគេផ្តួចផ្តើមបង្កើតឡើង។ ការប្រកាសជាសាធារណៈពីស្នាដៃឯកនៃបេតិកភណ្ឌអរូបបិយមនុស្សជាតិត្រូវបានគេចាត់ទុកថាជាវិធានការដំបូងនិងបន្ទាន់មួយក្នុងការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការអភិរក្សបេតិកភណ្ឌទាំងនេះ។ លើសពីនេះទៀត ដោយយល់ឃើញថាកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់ពាក់ព័ន្ធទៅនឹងបេតិកភណ្ឌវប្បធម៌ និងធម្មជាតិចាំបាច់ត្រូវឱ្យមានការពង្រឹង និងគាំទ្របន្ថែមទៀតប្រកបដោយប្រសិទ្ធិភាពតាមរយៈបញ្ញត្តិថ្មី។ ស្តីពីបេតិកភណ្ឌវប្បធម៌អរូបិយ ទើបមហាសន្និបាតរបស់អង្គការ យូណេស្កូ នៅក្នុងសម័យប្រជុំលើកទី ៣២ របស់ខ្លួននៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៣ បានអនុម័តអនុសញ្ញាមួយស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ។ ការអនុម័តអនុសញ្ញានេះគឺឈានមកដល់ចំណុចបញ្ចប់ដ៏ជោគជ័យនៃការខិតខំប្រឹងប្រែងអស់រយៈពេលយ៉ាងយូររបស់អង្គការ នេះក្នុងការលើកកម្ពស់មុខងារ និងតម្លៃនៃការអនុវត្ត និងវិញ្ញត្តិវប្បធម៌ ក៏ដូចជាចំពោះប្រាង្គប្រាសាទ និងទីតាំងប្រវត្តិសាស្ត្រនានា។

អស់រយៈពេលច្រើនឆ្នាំមកនេះ សហគមន៍អន្តរជាតិបានចាប់ផ្តើមយល់អំពីសារៈសំខាន់នៃអនុសញ្ញានេះតាមរយៈការផ្ញើសច្ចាប័នទៅលើអនុសញ្ញានោះក្នុងរយៈពេលយ៉ាងឆាប់បំផុត ដែលមិនធ្លាប់មានពីមុនមក។ តាមរយៈការចុះកិច្ចសន្យាជាផ្លូវការ រដ្ឋទាំងឡាយបានខិតខំប្រឹងប្រែងធានា ធ្វើការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយដែលមាននៅតាមទឹកដីរបស់ខ្លួន ព្រមទាំងធ្វើអត្តសញ្ញាណ និងកំណត់បេតិកភ័ណ្ឌដែលនៅរស់រានទាំងនេះដោយមានការចូលរួមពីសហគមន៍ ក្រុម និងអង្គការ ក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនានា។ ជាការពិតណាស់ អនុសញ្ញានេះបានបង្ហាញថាបេតិកភណ្ឌវប្បធម៌អរូបិយគឺជាកម្លាំងដ៏សំខាន់នៃភាពចម្រុះនៃវប្បធម៌ និងការធានាដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ សហគមន៍នានា ជាពិសេសសហគមន៍និងក្រុមនៃជនជាតិដើមភាគតិច និងអាចជាបុគ្គលផងដែរ ដើរតួយ៉ាងសំខាន់ក្នុងការបង្កើត ការអភិរក្ស ការថែរក្សា និងការបង្កើតឡើងវិញនូវបេតិកភណ្ឌវប្បធម៌អរូបិយដែលធ្វើឱ្យមានការរីកចម្រើនដល់ភាពចម្រុះនៃវប្បធម៌ និងគំនិតច្នៃប្រឌិតរបស់មនុស្សជាតិ។

ទោះជាយ៉ាងនេះក៏ដោយ អនុសញ្ញានេះក៏បានលើកឡើងដែរថា ដំណើរនៃសកលភាវូបនីយកម្ម និងបំរែបំរួលសង្គម រួមជាមួយនឹងលក្ខខណ្ឌនានាដែលបានបង្កើតឡើងសម្រាប់ធ្វើការពិភាក្សា សារជាថ្មីក្នុងចំណោមសហគមន៍ទាំងឡាយ អាចនឹងធ្វើឱ្យមានការគំរាមកំហែងដល់ការធ្វើឱ្យហិនហោច និងការបាត់បង់នៃបេតិកភណ្ឌវប្បធម៌អរូបិយ ជាពិសេសគឺបណ្តាលមកពីកង្វះធនធានសម្រាប់ធ្វើការអភិរក្សបេតិកភណ្ឌទាំងនេះ។ បេតិកភណ្ឌវប្បធម៌អរូបិយជួយដល់សហគមន៍ក្នុងការទប់ទល់ទៅនឹងឧបសគ្គនៃសកលភាវូបនីយកម្ម មិនត្រឹមតែតាមរយៈការអភិរក្សនូវតម្លៃ និងការប្រតិបត្តិនានាដែលកំណត់ពីអត្តសញ្ញាណរបស់សហគមន៍ទាំងនោះទេ ប៉ុន្តែថែមទាំងជួយលើកកម្ពស់ដល់ការគោរពទំនៀមទម្លាប់វប្បធម៌ដទៃ និងធ្វើឱ្យមានការយល់ដឹងពីវប្បធម៌រវាងគ្នានិងគ្នាទៅវិញទៅមក។ ទាំងវប្បធម៌រូបិយ និងអរូបិយ បានផ្តល់ឱកាសពិសេសប្លែកពីគេមួយក្នុងការដោះស្រាយនិងរស់នៅរួមគ្នានៅក្នុងសង្គមដែលមានគំនិតមតិផ្សេងៗ នៅខណៈដែលវប្បធម៌ទាំងនោះកំពុងធ្វើការកសាងភាពសុខដុមសង្គមទាំងនៅថ្នាក់ ជាតិ និងអន្តរជាតិ។

អនុសញ្ញានេះបានចូលជាធរមាននៅថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៦ ហើយក្នុងរយៈ ពេលដ៏ខ្លីក្រោយមកមហាសន្និបាតនៃរដ្ឋភាគីរបស់អនុសញ្ញានេះបានធ្វើការជួបប្រជុំគ្នា ដើម្បីជ្រើសរើសសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាល ដោយបានចាប់ផ្តើមធ្វើការអនុវត្តប្រកបដោយប្រសិទ្ធិភាពលើអនុសញ្ញានេះនៅថ្នាក់អន្តរជាតិ។ នៅថ្ងៃ ទី ១៩ ខែមិថុនា ឆ្នាំ២០០៨ ទំព័រសេករាជថ្មីមួយបានចាប់ផ្តើមបើកឡើងនៅក្នុងអនុសញ្ញាខ្លីតែមានអត្ថន័យគ្រប់គ្រាន់ ហើយមហាសន្និបាតក៏បានអនុម័តលើសេចក្តីណែនាំ

ប្រតិបត្តិការនេះរួចហើយដែរ។ សេចក្តីណែនាំនេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការក្នុងកិច្ចប្រជុំចំនួន៤លើក ដែលប្រារព្ធឡើងនៅវវាង ខែវិច្ឆិកាឆ្នាំ២០០៦ ដល់ខែកុម្ភៈ ឆ្នាំ២០០៨។ នៅក្នុងកិច្ចប្រជុំទាំងនោះ គណៈកម្មាធិការបានលើកឡើងនូវទំនាក់ទំនងរវាងបេតិកភណ្ឌវប្បធម៌អរូបិយ និងភាពចម្រុះគ្នាពីធម្មជាតិ ហើយបានបញ្ជាក់ថា ការចែករំលែក និងការផ្សព្វផ្សាយ នូវបេតិកភណ្ឌនេះជំរុញឱ្យមានការផ្លាស់ប្តូរវប្បធម៌គ្នា និងការយោគយល់រវាងគ្នានិងគ្នា ដោយបង្កើតបានជាទ្រព្យសម្បត្តិមួយសម្រាប់ធ្វើឱ្យមានភាពសុខដុមនិងសន្តិភាពរវាងមនុស្សជាតិទាំងឡាយ។

សេចក្តីណែនាំទាំងនេះបានបង្ហាញនូវលក្ខណវិនិច្ឆ័យ នីតិវិធី និងកាលវិភាគមួយចំនួនសម្រាប់ការដាក់បញ្ចូលបេតិកភណ្ឌអរូបិយទៅក្នុងបញ្ជីនៃអនុសញ្ញានេះ ការជ្រើសរើសកម្មវិធី គម្រោង និងសកម្មភាពនានាក្នុងការអភិរក្ស ការផ្តល់ជំនួយប្រឹក្សាទៅកាន់គណៈកម្មាធិការ ការផ្តល់ជំនួយអន្តរជាតិ ព្រមទាំងសម្រាប់ការធ្វើរបាយការណ៍របស់រដ្ឋនីមួយៗទៅកាន់គណៈកម្មាធិការ។ សេចក្តីណែនាំប្រតិបត្តិការនេះមិនទាន់បានផ្តល់ឱ្យរដ្ឋភាគីទាំងឡាយ នូវគោលការណ៍ណែនាំសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការអនុវត្តអនុសញ្ញានេះនៅកំរិតថ្នាក់ជាតិនៅឡើយទេ។ ប៉ុន្តែវាពិតជាបានឆ្លុះបញ្ចាំងតាមរយៈសារៈសំខាន់ ដែលផ្តល់ដោយគណៈកម្មាធិការ និងមហាសន្និបាតក្នុងមាត្រាទី ១៥នៃអនុសញ្ញានេះ ដែលអំពាវនាវឱ្យមានការចូលរួមយ៉ាងទូលំទូលាយ និងជាវិជ្ជមាន និងយ៉ាងសកម្មក្នុងការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយរបស់សហគមន៍ ក្រុម និងអាចជាបុគ្គលដែលបានបង្កើតថែរក្សា និងផ្ទេរបេតិកភណ្ឌវប្បធម៌ទាំងនេះ។ ដូចដែលបានលើកឡើងដោយគណៈកម្មាធិការនៅក្នុងសម័យប្រជុំរបស់ខ្លួន សេចក្តីណែនាំទាំងនេះ គឺជាមូលដ្ឋានសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ ដូច្នេះ ហើយទើបវាត្រូវបានយកចិត្តទុកដាក់បំផុតពីអនុសញ្ញានេះ។

ការបោះពុម្ពផ្សាយលើកដំបូង នៃសេចក្តីណែនាំប្រតិបត្តិការនេះ ត្រូវធ្វើឱ្យការកែសំរួលឱ្យបានប្រសើរឡើងដោយផ្អែកទៅតាមតម្រូវការនៃរដ្ឋភាគី នៅពេលដែលធ្វើការអភិរក្សបេតិកភណ្ឌរបស់ពួកគេ និងទៅតាមតម្រូវការនៃបទពិសោធន៍ ដែលទាមទារដោយគណៈកម្មាធិការក្នុងការណែនាំការអនុវត្តនៃអនុសញ្ញានេះ។ ទិដ្ឋភាពវិវឌ្ឍនៃសេចក្តីណែនាំនេះនឹងផ្តល់ឱ្យអនុសញ្ញានេះនូវភាពបត់បែនដ៏ចាំបាច់មួយទៅនឹងការប្រែប្រួល និងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃពិភពលោក និងការវិវឌ្ឍជាដរាបនៃបេតិកភណ្ឌដែលនៅរស់រាន។

នៅខណៈពេលចាប់ផ្តើមសរសេរសេចក្តីផ្តើមនៃសៀវភៅនេះឡើង មានរដ្ឋសមាជិករបស់អង្គការ យូណេស្កូ រហូតដល់ជាង ១០០ ដែលបានផ្តល់សច្ចាប័នមកលើអនុសញ្ញានេះ ហើយនឹងមានសមាជិកជាច្រើនផ្សេងទៀតដែលនឹងចូលរួមក្នុងពេលចាប់ៗខាងមុខនេះ។ រហូតមកដល់ពេលនេះវាទើបតែបានរយៈពេល ៥ឆ្នាំប៉ុណ្ណោះ បន្ទាប់ពីការអនុម័តលើអនុសញ្ញានេះ ប៉ុន្តែបេតិកភណ្ឌអរូបិយ និងការអភិរក្សត្រូវបានគេទទួលស្គាល់ជាថ្មីម្តងទៀតថាជាផ្នែកមួយដ៏សំខាន់នៃបេតិកភណ្ឌវប្បធម៌របស់យើង ដោយវាបានផ្តល់ឱ្យយើងនូវគំនិតនៃអត្តសញ្ញាណ និងភាពស្ថិតស្ថេរ។ ក្នុងនាមជាអគ្គនាយករបស់អង្គការ យូណេស្កូ វាគឺបុព្វសិទ្ធិរបស់ខ្ញុំក្នុងការដឹកនាំការងារនេះឱ្យទទួលបានការទទួលស្គាល់ជាអន្តរជាតិលើវិស័យអាទិភាពនេះ។ ខ្ញុំមានជំនឿចិត្តថាអនុសញ្ញានេះនឹងនៅតែបន្តផ្តល់អត្ថប្រយោជន៍ពីការបង្កើនការគាំទ្រពីរដ្ឋភាគីរបស់ខ្លួន ហើយពីមួយថ្ងៃទៅមួយថ្ងៃវានឹងកាន់តែទទួលបានជោគជ័យចំពោះគោលបំណងរបស់ខ្លួនក្នុងការអភិរក្សភាពចម្រុះនៃបេតិកភណ្ឌដែលនៅរស់រានរបស់ពិភពលោក។

ហត្ថលេខា

Koichiro Matsuura
អគ្គនាយកអង្គការ យូណេស្កូ

# អនុសញ្ញា

# ស្តីពី

# ការការពារបេតិកភណ្ឌវប្បធម៌អរូបី

សន្និសីទទូទៅរបស់អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ដែលហៅកាត់ថា អង្គការយូណេស្កូ បានប្រជុំនៅទីក្រុងប៉ារីស ចាប់ពីថ្ងៃទី ២៩ ខែ កញ្ញា ដល់ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០០៣ នៃសម័យប្រជុំលើកទី ៣២

យោងលិខិតូបករណ៍អន្តរជាតិដែលមានស្រាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ជាពិសេសសេចក្តីថ្លែងការណ៍ ជាសាកលអំពីសិទ្ធិមនុស្សនៅឆ្នាំ ១៩៤៨ កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ នាឆ្នាំ ១៩៦៦ ហើយនិងកតិកាសញ្ញាស្តីពីច្បាប់រដ្ឋប្បវេណី និងនយោបាយនាឆ្នាំ ១៩៦៦

ដោយឃើញនូវសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌អរូបី គឺជាមូលដ្ឋានគ្រឹះនៃវប្បធម៌ចម្រុះ និងជាការធានានូវកិច្ចអភិវឌ្ឍន៍ដោយចីរភាព ដូចបានគូសបញ្ជាក់នៅក្នុងអនុសាសន៍របស់អង្គការយូណេស្កូស្តីពីការការពារវប្បធម៌ប្រពៃណី និងប្រជាជននាឆ្នាំ ១៩៨៩ នៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលរបស់អង្គការយូណេស្កូស្តីពីភាពប្លែកគ្នារបស់វប្បធម៌នាឆ្នាំ ២០០១ ហើយនិងនៅក្នុងសេចក្តីថ្លែងការណ៍នៅទីក្រុងអ៊ីសស្តង់ប៊ុលនាឆ្នាំ ២០០៣ ដែលត្រូវបានអនុម័ត នៅក្នុងកិច្ចប្រជុំតុមូលលើកទី៣ របស់រដ្ឋមន្ត្រីវប្បធម៌នៃប្រទេសទាំងឡាយ

ដោយឃើញនូវទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងជ្រាលជ្រៅ រវាងបេតិកភណ្ឌវប្បធម៌អរូបី ហើយ និងបេតិកភណ្ឌវប្បធម៌រូបីនិងធម្មជាតិ

ដោយទទួលស្គាល់ថាដំណើរការសាកលភាវូបនីយកម្ម និងការប្រែប្រួលរបស់សង្គម ជាមួយនឹងលក្ខខណ្ឌដែលបង្កើតឲ្យមានការពិគ្រោះគ្នាសារជាថ្មីរវាងសហគមន៍នានា ក៏ដូចជាបាតុភូតនៃការមិនចេះយោគយល់គ្នាដែលបានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរក្លាយជាគ្រោះខូចខាត ការបាត់បង់ និងការបំផ្លិចបំផ្លាញទៅលើបេតិកភណ្ឌវប្បធម៌អរូបី ជាពិសេសដោយសារកង្វះខាតមធ្យោបាយសម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះផង

ដោយចាប់អារម្មណ៍ដល់ឆន្ទៈជាសាកល និងការរួមគ្នាយកចិត្តទុកដាក់ដើម្បីការពារបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ

ដោយទទួលស្គាល់ថាបណ្តាសហគមន៍ ជាពិសេសសហគមន៍ជនជាតិដើម ក្រុមមនុស្ស និង បុគ្គលនៅក្នុងករណីចាំបាច់ខ្លះមានតួនាទីយ៉ាងសំខាន់ក្នុងការងារផលិត ការការពារ ការថែទាំ និងការ បង្កើតសារជាថ្មីនូវបេតិកភណ្ឌវប្បធម៌អរូបី ញាំងឲ្យវប្បធម៌ច្រើនបែបកើនឡើងព្រមទាំងការច្នៃប្រឌិត របស់មនុស្សផង

ដោយកត់សម្គាល់នូវលទ្ធភាពធំធេងរបស់សកម្មភាព ដែលដឹកនាំដោយ អង្គការយូណេស្កូ ក្នុងការបង្កើតលិខិតូបករណ៍ដែលមានលក្ខណៈជាបទដ្ឋានសំដៅរក្សាការពារបេតិកភណ្ឌវប្បធម៌ ជា ពិសេសអនុសញ្ញាសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌ពិភពលោក និងបេតិកភណ្ឌវប្បធម៌ធម្មជាតិ នាឆ្នាំ ១៩៧២

ដោយកត់សម្គាល់ម្យ៉ាងទៀតថា រហូតមកដល់បច្ចុប្បន្ននេះនៅមិនទាន់មានលិខិតូបករណ៍ ពហុភាគីដែលមានលក្ខណៈបង្ខិតបង្ខំណាមួយសម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបីនៅឡើយ

ដោយឃើញថាកិច្ចព្រមព្រៀងទាំងឡាយ អនុសាសន៍នានា និងសេចក្តីសម្រេចចិត្តអន្តរជាតិ ដែល កំពុងមានអត្ថិភាពស្តីពីបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិដែលចាំបាច់ត្រូវតែធ្វើឲ្យកាន់ តែសម្បូរឡើង និងបំពេញបន្ថែមប្រកបដោយប្រសិទ្ធភាព តាមមធ្យោបាយបន្ថែមបទប្បញ្ញត្តិថ្មីៗទៀត ពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌អរូបី

ដោយឃើញនូវភាពចាំបាច់ ដើម្បីទាក់ទាញឱ្យមានការចាប់អារម្មណ៍បន្ថែមទៀត ជាពិសេស ក្នុងចំណោមមនុស្សជំនាន់ក្រោយទៅលើសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌អរូបីនិងការពារ បេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ

ដោយឃើញថាសហគមន៍អន្តរជាតិត្រូវតែរួមចំណែកជាមួយរដ្ឋភាគីនៃអនុសញ្ញានេះ ដើម្បី ការពារបេតិកភណ្ឌវប្បធម៌ទាំងនោះ ដោយឈរលើស្មារតីសហប្រតិបត្តិការ និងការជួយគ្នាទៅវិញ ទៅមក

ដោយរំលឹកដល់កម្មវិធីរបស់អង្គការយូណេស្កូ ស្តីពីបេតិកភណ្ឌវប្បធម៌អរូបី ជាពិសេសគឺ ការប្រកាសអំពីស្នាដៃឯកនៃបេតិកភណ្ឌសំដី និងអរូបីរបស់មនុស្សជាតិ

ដោយឃើញនូវតួនាទីមិនអាចកាត់ថ្លៃបានរបស់បេតិកភណ្ឌវប្បធម៌អរូបី ដូចជាកត្តា សម្រាប់ធ្វើឱ្យមនុស្សគ្រប់រូបខិតចូលជិតគ្នា និងផ្លាស់ប្តូរ និងការយោគយល់គ្នារវាងមនុស្សជាតិ

អនុម័តអនុសញ្ញានេះនៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៣។

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា១._ គោលបំណងរបស់អនុសញ្ញា

គោលបំណងរបស់អនុសញ្ញានេះគឺ:

ក_ការពារបេតិកភណ្ឌវប្បធម៌អរូបី

ខ_គោរពចំពោះបេតិកភណ្ឌវប្បធម៌អរូបីរបស់សហគមន៍ ក្រុមមនុស្ស និងបុគ្គលដែលពាក់ព័ន្ធ

គ_ទាក់ទាញឱ្យមានការចាប់អារម្មណ៍ក្នុងកម្រិតនៅនឹងកន្លែង កម្រិតជាតិ និងកម្រិតអន្តរជាតិ ចំពោះសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌អរូបី ហើយការចូលរួមវាយតម្លៃលើបេតិកភណ្ឌវប្បធម៌អរូបីនោះ

ឃ_កិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ។

មាត្រា២._ និយមន័យ

សម្រាប់អនុសញ្ញានេះ:

១.ពាក្យ "បេតិកភណ្ឌវប្បធម៌អរូបី " មានន័យថា ការប្រតិបត្តិ ការសម្តែង ការនិយាយ ចំណេះដឹង ចំណេះធ្វើ ព្រមទាំងឧបករណ៍វត្ថុ វត្ថុដែលមានប្រភពសិប្បនិម្មិត និងលំហវប្បធម៌ បញ្ចូលគ្នា ដែលសហគមន៍ ក្រុមមនុស្ស និងក្នុងករណីខ្លះ បុគ្គលទទួលស្គាល់ថាជាផ្នែកមួយនៃបេតិកភណ្ឌវប្បធម៌របស់ពួកគេ ។ បេតិកភណ្ឌវប្បធម៌អរូបីនេះត្រូវបានបន្តវេនពីជំនាន់មួយទៅជំនាន់មួយ ហើយដែលត្រូវបានបង្កើតថ្មីឡើងវិញ ជាអចិន្ត្រៃយ៍ដោយសហគមន៍និងក្រុមមនុស្សផ្អែកទៅតាមកន្លែងនិងបរិស្ថានដែលគេរស់នៅ ទៅនឹងអន្តរកម្មរបស់ពួកគេជាមួយនឹងធម្មជាតិ ព្រមទាំងជាមួយនឹងប្រវត្តិសាស្ត្ររបស់ពួកគេហើយបានផ្តេរនូវមនោសញ្ចេតនានៃអត្តសញ្ញាណ និងនិរន្តរភាពសម្រាប់រួមចំណែកក្នុងការជំរុញឱ្យមានការគោរពវប្បធម៌ប្លែកៗគ្នា និងភាពចេះបង្កើតថ្មីរបស់មនុស្ស ។ ក្នុងអនុសញ្ញានេះ អាចចាត់ទុកវាជាបេតិកភណ្ឌវប្បធម៌អរូបី គឺរបស់ដែលសមស្របជាមួយនឹងលិខិតូបករណ៍អន្តរជាតិកំពុងអត្ថិភាពទាក់ទងជាមួយនិងសិទ្ធិមនុស្សជាធរមាន ក៏ដូចជាការតម្រូវឱ្យមានការគោរពគ្នាទៅវិញទៅមកក្នុងរវាងសហគមន៍ រវាងក្រុមមនុស្ស បុគ្គល និងការអភិវឌ្ឍ ប្រកបដោយចីរភាព។

២.ពាក្យ "បេតិកភណ្ឌវប្បធម៌អរូបី " តាមនិយមន័យក្នុងកថាខណ្ឌទី១ខាងលើត្រូវបានស្តែងឡើងជាពិសេសនៅក្នុងវិស័យដូចខាងក្រោម:

ក_ប្រពៃណីនិងសំដីនិយាយ រួមមាន ភាសា ជាយាននៃបេតិកភណ្ឌវប្បធម៌អរូបី

ខ_សិល្បៈទស្សនីយភាព

គ_ការប្រតិបត្តិសង្គម សាសនា និងព្រឹត្តិការណ៍សម្រាប់ពិធីបុណ្យ

ឃ.ចំណេះដឹង និងការប្រតិបត្តិស្តីអំពីធម្មជាតិ និងសាកលលោក

ង.ចំណេះធ្វើផ្សារភ្ជាប់ជាមួយនឹងសិប្បកម្មប្រពៃណី។

៣.ពាក្យ "ការពារ" មានន័យថា វិធានការសំដៅធានាភាពគង់វង្សនៃបេតិកភណ្ឌវប្បធម៌អរូបី រួមទាំងការឱ្យអត្តសញ្ញាណ ការទុកឯកសារ ការស្រាវជ្រាវ ការថែរក្សាការពារ ការលើកតម្កើង ការធ្វើឱ្យមានតម្លៃ ការផ្ទេរបន្ត ជាពិសេសតាមរយៈការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ក៏ដូចជាការធ្វើឱ្យមានជីវិតឡើងវិញនូវទិដ្ឋភាពនានានៃបេតិកភណ្ឌវប្បធម៌ទាំងនោះ។

៤.ពាក្យ "រដ្ឋភាគី " គឺរដ្ឋទាំងឡាយដែលផ្សារភ្ជាប់ជាមួយអនុសញ្ញានេះ ហើយរដ្ឋទាំងនោះធ្វើឱ្យអនុសញ្ញានេះចូលជាធរមាន។

៥.អនុសញ្ញានេះអនុវត្តស្របតាមគោលការណ៍ផ្លាស់ប្តូរជាចាំបាច់ mutatis mutandis នៅលើទឹកដីតាមខ្លឹមសារមាត្រា ៣៣ ដែលក្លាយជាភាគីនៃអនុសញ្ញា សមស្របតាម លក្ខខណ្ឌដូចបានបញ្ជាក់នៅក្នុងមាត្រានោះ។ ក្នុងករណីនេះពាក្យថា រដ្ឋភាគី មានន័យថាទឹកដី ទាំងនោះដូចគ្នា។

មាត្រា ៣._ ទំនាក់ទំនងជាមួយលិខិតូបករណ៍អន្តរជាតិផ្សេងទៀត

ប្រការដែលមានចែងនៅក្នុងអនុសញ្ញានេះហើយមិនអាចបកស្រាយបាន:

ក. ការធ្វើឱ្យខូចខាតដល់លក្ខន្តិក: ឬការបន្ថយនូវកម្រិតនៃការការពារទ្រព្យដែលត្រូវបានប្រកាសថាជាបេតិកភណ្ឌវប្បធម៌ពិភពលោកនៅក្នុងក្របខណ្ឌនៃអនុសញ្ញាឆ្នាំ ១៩៧២ ស្តីពី ការការពារបេតិកភណ្ឌវប្បធម៌ពិភពលោក និងបេតិកភណ្ឌវប្បធម៌ធម្មជាតិដែលនៅក្នុងនោះកត្តាមួយនៃបេតិកភណ្ឌវប្បធម៌អរូបីមានការទាក់ទងដោយផ្ទាល់ ឬ

ខ. ការផ្តល់សិទ្ធិនិងកាតព្វកិច្ចឱ្យរដ្ឋមួយភាគីនូវអ្វីដែលលិខិតូបករណ៍អន្តរជាតិបានកំណត់ទាក់ទងជាមួយសិទ្ធិលើកម្មសិទ្ធិបញ្ញា ឬទាក់ទងជាមួយការប្រើប្រាស់ប្រភពធនធានខាងជីវសាស្ត្រ និងបរិស្ថានដែលរដ្ឋទាំងនោះជាភាគី។

## ជំពូកទី២

## អង្គការរបស់អនុសញ្ញា

មាត្រា ៤._ មហាសន្និបាតរបស់រដ្ឋភាគី

១.ត្រូវបានបង្កើតមហាសន្និបាតរបស់រដ្ឋភាគីហៅថា" មហាសន្និបាត" ។មហាសន្និបាតនេះគឺជា អង្គការអធិបតេយ្យរបស់អនុសញ្ញានេះ។

២.មហាសន្និបាតត្រូវបើកអង្គប្រជុំសាមញ្ញរៀងរាល់២ឆ្នាំម្តង ។ មហាសន្និបាតនេះអាចបើកអង្គប្រជុំវិសាមញ្ញនៅពេលដែលមហាសន្និបាតសម្រេច ឬក៏តាមការស្នើសុំរបស់គណៈកម្មាធិការ អន្តររដ្ឋាភិបាលសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌អរូបី ឬយ៉ាងហោចណាស់មានសំឡេងតាមការ ស្នើសុំពីចំនួន១ភាគ៣ យ៉ាងតិចនៃរដ្ឋភាគី។

៣.មហាសន្និបាតអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

មាត្រា ៥.- គណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់ការការពារ បេតិកភណ្ឌវប្បធម៌អរូបី

១.ត្រូវបានបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបីមួយនៅជាមួយអង្គការយូណេស្កូ នេះហៅថា " គណៈកម្មាធិការ " ។ សមាសភាពគណៈកម្មាធិការនេះមានតំណាងមកពី១៨រដ្ឋភាគីដែលជ្រើសតាំងឡើងដោយមហាសន្និបាតនៃរដ្ឋជាភាគី បន្ទាប់ពីអនុសញ្ញានេះចូលជាធរមានស្របតាមមាត្រា ៣៤។

២.ចំនួនរដ្ឋជាសមាជិករបស់គណៈកម្មាធិការនេះអាចឡើងទៅដល់ចំនួន ២៤ នៅពេលដែលចំនួនរដ្ឋភាគីទាំងអស់របស់អនុសញ្ញានេះកើនឡើងដល់ចំនួន ៥០។

មាត្រា ៦.- ការបោះឆ្នោត និងអាណត្តិរបស់រដ្ឋជាសមាជិករបស់គណៈកម្មាធិការ

១.ការបោះឆ្នោតជ្រើសតាំងរដ្ឋសមាជិករបស់គណៈកម្មាធិការ ត្រូវគោរពតាមគោលការណ៍បែងចែកភូមិសាស្ត្រ និងការផ្លាស់វេនគ្នាដោយសមធម៌។

២.រដ្ឋសមាជិករបស់គណៈកម្មាធិការ ត្រូវបានជ្រើសតាំងឡើងសម្រាប់អាណត្តិ៤ឆ្នាំដោយរដ្ឋភាគីរបស់អនុសញ្ញានៅក្នុងមហាសន្និបាត។

៣.ជានិច្ចកាល អាណត្តិរបស់ចំនួនពាក់កណ្តាលរដ្ឋសមាជិករបស់គណៈកម្មាធិការដែលត្រូវបានជ្រើសតាំងនៅក្នុងការបោះឆ្នោតលើកទី១ ត្រូវបានកម្រិតត្រឹម ២ឆ្នាំ ។ រដ្ឋទាំងនោះត្រូវបានចាត់តាំងតាមការចាប់ឆ្នោតនៅក្នុង ឱកាសបោះឆ្នោតលើកទី១នោះ។

៤.រៀងរាល់រយៈពេល២ឆ្នាំ មហាសន្និបាតត្រូវរៀបចំផ្លាស់ប្តូរជាថ្មីនូវរដ្ឋសមាជិកចំនួនពាក់កណ្តាលនៃគណៈកម្មាធិការ។

៥.មហាសន្និបាតបោះឆ្នោតជ្រើសតាំងរដ្ឋសមាជិករបស់គណៈកម្មាធិការ ទៅតាមចំនួនដទៃទៀតចាំបាច់សម្រាប់បំពេញតំណែងដែលនៅទំនេរ។

៦.រដ្ឋសមាជិកមួយរបស់គណៈកម្មាធិការអាចត្រូវបានជ្រើសតាំង សម្រាប់តែរយៈពេល២អាណត្តិជាប់ៗគ្នា។

៧.រដ្ឋសមាជិករបស់គណៈកម្មាធិការជ្រើសរើសអ្នកមានជំនាញដើម្បីជាតំណាងនៅក្នុងវិស័យផ្សេងៗ នៃ បេតិកភណ្ឌវប្បធម៌អរូបី។

មាត្រា ៧._ មុខងាររបស់គណៈកម្មាធិការ

ដោយពុំប៉ះពាល់ដល់ភារកិច្ចដទៃទៀត ដែលបច្ចុប្បន្នអនុសញ្ញាបានប្រគល់មុខងារឱ្យ គណៈកម្មាធិការមានដូចតទៅ:

ក. បំផុសគោលដៅរបស់អនុសញ្ញា លើកទឹកចិត្ត និងធានាការតាមដានដំណើរការអនុវត្ត អនុសញ្ញានេះ

ខ. ផ្តល់យោបល់ចំពោះប្រតិបត្តិការល្អ និងបង្កើតជាអនុសាសន៍លើវិធានការនានាដើម្បី ការពារ បេតិកភណ្ឌវប្បធម៌អរូបី

គ. រៀបចំនិងដាក់ជូនមហាសន្និបាតអនុម័តនូវគម្រោងផែនការសម្រាប់ការប្រើប្រាស់ ប្រភពមូលនិធិស្របតាមមាត្រា ២៥

ឃ. ខិតខំរិះរកមធ្យោបាយដើម្បីបង្កើនធនធាន និងចាត់វិធានការសមស្របទាំងឡាយដើម្បី សម្រេចគោលដៅនេះស្របតាមមាត្រា ២៥

ង. រៀបចំនិងដាក់ជូនមហាសន្និបាតអនុម័តនូវការណែនាំប្រតិបត្តិទាំងឡាយសម្រាប់ ដំណើរការអនុវត្តអនុសញ្ញានេះ

ច. ពិនិត្យ ដោយផ្អែកលើមាត្រា២៩ នូវរបាយការណ៍ដែលរដ្ឋភាគីបានផ្ញើមក ហើយនិង សង្ខេបរបាយការណ៍ទាំងនោះ ដាក់ជូនមហាសន្និបាត

ឆ. ពិនិត្យរាល់សំណើដែលរដ្ឋភាគីទាំងអស់ស្នើសុំ ហើយសម្រេចអនុលោមតាម គោលការណ៍សក្យានុម័តនៃការជ្រើសរើស ហើយដែលបានទទួលការយល់ព្រមពីមហាសន្និបាត:

១.ចុះក្នុងបញ្ជី និងសេចក្តីស្នើដូចមានចែងនៅក្នុងមាត្រា ១៦. ១៧ និង ១៨

២.ផ្តល់ជំនួយឧបត្ថម្ភអន្តរជាតិស្របតាមមាត្រា ២២។

មាត្រា ៨._ របៀបធ្វើការរបស់គណៈកម្មាធិការ

១.គណៈកម្មាធិការទទួលខុសត្រូវចំពោះមុខមហាសន្និបាត ។ គណៈកម្មាធិការត្រូវរាយការណ៍ជូន មហាសន្និបាតនូវរាល់សកម្មភាពនិងការសម្រេចរបស់ខ្លួន។

២.គណៈកម្មាធិការអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយសំឡេង ២ភាគ៣ នៃចំនួនសមាជិករបស់ ខ្លួន។

៣.គណៈកម្មាធិការអាចបង្កើតជាបណ្តោះអាសន្ននូវអង្គការពិគ្រោះយោបល់អាដហុក " Ad hoc " ចំពោះកិច្ចការ ដែលខ្លួនយល់ឃើញថាចាំបាច់ សម្រាប់ការបំពេញមុខងាររបស់ខ្លួន។

៤.គណៈកម្មាធិការអាចអញ្ជើញអង្គការសាធារណៈដទៃទៀត ឬឯកជនក៏ដូចជារូបវន្តបុគ្គលដែលមាន សមត្ថភាព ហើយត្រូវបានគេទទួលស្គាល់នៅក្នុងវិស័យនៃបេតិកភណ្ឌវប្បធម៌អរូបី ឱ្យចូលរួមប្រជុំ ជាមួយដើម្បីសុំយោបល់ចំពោះបញ្ហាពិសេសដោយឡែកនានា។

មាត្រា ៩._ ការតែងតាំងអង្គការពិគ្រោះយោបល់

១.គណៈកម្មាធិការស្នើទៅមហាសន្និបាត សុំតែងតាំងអង្គការក្រៅរដ្ឋាភិបាលនានាដែលមាន សមត្ថភាពហើយគេទទួលស្គាល់ នៅក្នុងវិស័យនៃបេតិកភណ្ឌវប្បធម៌អរូបី អង្គការទាំងនោះមាន មុខងារ ជាអ្នកផ្តល់យោបល់ដល់គណៈកម្មាធិការ។

២.គណៈកម្មាធិការស្នើទៅមហាសន្និបាតអំពីលក្ខខណ្ឌ និងបែបបទនៃការតែងតាំងអង្គការខាងលើនេះ។

មាត្រា ១០._ អគ្គលេខាធិការដ្ឋាន

១.គណៈកម្មាធិការមាន អគ្គលេខាធិការដ្ឋាននៃអង្គការយូណេស្កូជួយធ្វើការ។

២.អគ្គលេខាធិការដ្ឋានត្រៀមរៀបចំឯកសាររបស់មហាសន្និបាតនិងរបស់គណៈកម្មាធិការក៏ដូចជាធ្វើ សេចក្តីព្រាងរបៀបវារៈនៃការប្រជុំទាំងឡាយ និងធានាការអនុវត្តសេចក្តីសម្រេចនៃការប្រជុំទាំងនោះ។

## ជំពូកទី ៣
## ការការពារបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងកម្រិតថ្នាក់ជាតិ

មាត្រា ១១._ តួនាទីរបស់រដ្ឋភាគី

តួនាទីនេះគឺជារបស់រដ្ឋភាគីនីមួយៗ:

ក. ចាត់វិធានការចាំបាច់ ដើម្បីពង្រឹងនឹងធានាការការពារបេតិកភណ្ឌវប្បធម៌អរូបី ដែលមាននៅក្នុង ទឹកដីរបស់ខ្លួន

ខ. នៅក្នុងចំណោម វិធានការការពារទាំងឡាយ ដូចមានចែងក្នុងមាត្រា ២ កថាខ័ណ្ឌទី៣ រដ្ឋភាគីត្រូវ កំណត់អត្តសញ្ញាណ និងកំណត់កត្តាជុំទាំងឡាយនៃបេតិកភណ្ឌវប្បធម៌អរូបី ដែលមាននៅក្នុងទឹកដី របស់ខ្លួន ដោយមានការចូលរួមពីសហគមន៍ ក្រុមមនុស្ស និង អង្គការក្រៅរដ្ឋាភិបាលដែលមានការ ពាក់ព័ន្ធផ្ទាល់។

មាត្រា ១២._ បញ្ជីសារពើភណ្ឌ

១.ដើម្បីធានាឱ្យមានការកំណត់អត្តសញ្ញាណសម្រាប់ការការពារនេះ រដ្ឋភាគីនីមួយៗ ដោយផ្អែកលើស្ថានភាពផ្ទាល់របស់បេតិកភណ្ឌវប្បធម៌អរូបី នោះ ត្រូវធ្វើបញ្ជីសារពើភណ្ឌមួយ ឬច្រើននៃបេតិកភណ្ឌវប្បធម៌អរូបីដែលមាននៅក្នុងទឹកដីរបស់ខ្លួន។ ត្រូវធ្វើបញ្ជីសារពើភណ្ឌទាំងនោះជាប្រចាំ។

២.នៅពេលដែលរដ្ឋភាគីនីមួយៗផ្ញើរបាយការណ៍របស់ខ្លួនតាមពេលកំណត់ទៅជូនគណៈកម្មាធិការស្របតាមមាត្រា២៩ រដ្ឋភាគីទាំងនោះត្រូវផ្តល់ព័ត៌មានពិតប្រាកដទាក់ទងទៅនឹងបញ្ជីសារពើភណ្ឌទាំងនោះ។

មាត្រា ១៣.-វិធានការសម្រាប់ការការពារផ្សេងទៀត

ដើម្បីធានាការការពារ ការអភិវឌ្ឍ និងការឱ្យមានតម្លៃចំពោះបេតិកភណ្ឌវប្បធម៌អរូបី រដ្ឋភាគីនីមួយៗត្រូវខិតខំ :

ក. អនុម័តនយោបាយជាទូទៅមួយសម្រាប់ធ្វើឱ្យមានតម្លៃនូវតួនាទីរបស់បេតិកភណ្ឌវប្បធម៌អរូបីនោះនៅក្នុងសង្គមនិងបញ្ចូលការការពារបេតិកភណ្ឌវប្បធម៌នោះ ទៅក្នុងកម្មវិធីនៃផែនការកម្ម។

ខ. ចាត់តាំង ឬបង្កើតស្ថាប័នមានសមត្ថកិច្ចមួយ ឬច្រើន ដើម្បីការពារបេតិកភណ្ឌវប្បធម៌អរូបី ដែលមាននៅក្នុងទឹកដីរបស់ខ្លួន។

គ. លើកទឹកចិត្តការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស និង សិល្បសាស្ត្រ ក៏ដូចជាការស្រាវជ្រាវវិធីសាស្ត្រទាំងឡាយ សំដៅការពារដោយមានប្រសិទ្ធភាពនូវបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ ជាពិសេសគឺចំពោះបេតិកភណ្ឌវប្បធម៌អរូបីដែលកំពុងឋិតនៅចំពោះមុខគ្រោះថ្នាក់។

ឃ. អនុម័តវិធានការគតិយុត្ត បច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុសមស្របសំដៅ :

១.ជំរុញការបង្កើតថ្មី ឬពង្រឹងស្ថាប័នបណ្តុះបណ្តាលផ្នែកគ្រប់គ្រងបេតិកភណ្ឌវប្បធម៌អរូបី ហើយនិងការផ្ទេរបន្តនូវបេតិកភណ្ឌទាំងនោះ តាមរយៈវេទិកានិងលំហដើម្បីសំដែងបង្ហាញ ឬការនិយាយអំពី បេតិកភណ្ឌវប្បធម៌ទាំងនោះ។

២.ធានាការបញ្ចូលទៅក្នុងបេតិកភណ្ឌវប្បធម៌អរូបី ដោយគោរពតាមការប្រតិបត្តិតាមទំនៀមទម្លាប់ដែលគ្រប់គ្រងការរួមបញ្ចូលជាមួយទិដ្ឋភាពដោយឡែកនៃបេតិកភណ្ឌវប្បធម៌ទាំងនោះ។

៣.បង្កើតស្ថាប័នតម្កល់ឯកសារនានាខាងផ្នែកបេតិកភណ្ឌវប្បធម៌អរូបី និងផ្តល់ភាពងាយស្រួលដល់ទំនាក់ទំនងជាមួយស្ថាប័នទាំងនោះ។

មាត្រា ១៤. ការអប់រំ ការបំផុសចំណាប់អារម្មណ៍ និងការបង្កើនសមត្ថភាព

តាមមធ្យោបាយសមស្រប រដ្ឋភាគីនីមួយៗត្រូវខិតខំ :

ក. ធានាឱ្យមានការទទួលស្គាល់ ការគោរព និងការធ្វើឱ្យមានតម្លៃនូវបេតិកភណ្ឌវប្បធម៌អរូបី នៅក្នុងសង្គម ជាពិសេសដោយសារ :

១.កម្មវិធីអប់រំ បំផុសឱ្យមានចំណាប់អារម្មណ៍ និងកម្មវិធីផ្សព្វផ្សាយពត៌មាន ចំពោះសាធារណជនពិសេសគឺយុវជន ។

២.កម្មវិធីអប់រំ និងបណ្តុះបណ្តាលដោយឡែកនៅក្នុងសហគមន៍ និងក្រុមមនុស្សដែលមានការពាក់ព័ន្ធ។

៣.ធ្វើសកម្មភាពពង្រឹងសមត្ថភាពខាងផ្នែកការពារបេតិកភណ្ឌវប្បធម៌អរូបី ជាពិសេសគឺការគ្រប់គ្រង និងការស្រាវជ្រាវវិទ្យាសាស្ត្រ។

៤.ផ្ទេរចំណេះដឹងតាមមធ្យោបាយក្រៅផ្លូវការ ។

ខ. ជូនដំណឹងជាប្រចាំដល់សាធារណជនអំពីការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរទៅលើបេតិកភណ្ឌវប្បធម៌ទាំងនេះក៏ដូចជាធ្វើ សកម្មភាពទាំងឡាយ ឈានទៅអនុវត្តតាមអនុសញ្ញានេះ ។

គ. ជំរុញការអប់រំ អំពីការការពារលំហធម្មជាតិ និងទីកន្លែងអនុស្សាវរីយ៍ដែលអត្ថិភាពរបស់វា គឺជាប្រការ ចាំបាច់ សម្រាប់និយាយអំពីបេតិកភណ្ឌវប្បធម៌អរូបី ទាំងនោះ ។

មាត្រា ១៥. ការចូលរួមរបស់សហគមន៍ ក្រុមមនុស្ស និង បុគ្គល

នៅក្នុងក្របខណ្ឌនៃសកម្មភាពការពារបេតិកភណ្ឌវប្បធម៌អរូបីនេះ រដ្ឋភាគីនីមួយៗត្រូវខិតខំធានាឱ្យមានការចូលរួមដ៏ទូលំទូលាយរបស់សហគមន៍ ពីក្រុមមនុស្ស ហើយពីបុគ្គលជាយថាហេតុ ដែលបានបង្កើត ថែទាំ និងផ្ទេរបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ ព្រមទាំងបញ្ចូលពួកគេឱ្យចូលរួមយ៉ាងសកម្មក្នុងសកម្មភាពគ្រប់គ្រង បេតិកភណ្ឌវប្បធម៌អរូបី នោះ ។

## ជំពូកទី ៤

## ការការពារបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងកម្រិតអន្តរជាតិ

មាត្រា ១៦. បញ្ជីបេតិកភណ្ឌវប្បធម៌អរូបី របស់មនុស្សជាតិ

១.ដើម្បីធានាឱ្យមានការមើលឃើញកាន់តែច្បាស់ថែមទៀតអំពីបេតិកភណ្ឌវប្បធម៌អរូបី និងដើម្បីធ្វើឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត លើសារៈសំខាន់របស់បេតិកភណ្ឌវប្បធម៌ទាំងនោះ ហើយនឹងដើម្បីជួយឱ្យមានការ សន្ទនាទាំងឡាយនៅក្នុងស្មារតីគោរពដល់វប្បធម៌ចម្រុះ គណៈកម្មាធិការត្រូវបង្កើត ធ្វើជាប្រចាំ ព្រមទាំងបោះពុម្ពផ្សាយ នូវបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី របស់មនុស្សជាតិមួយតាមការស្នើរបស់រដ្ឋភាគី ។

២.គណៈកម្មាធិការត្រូវចងក្រងហើយដាក់ជូនសុំការអនុម័តនូវលក្ខខណ្ឌចម្បងសម្រាប់ការបង្កើត ការធ្វើជាប្រចាំនិង បោះពុម្ពផ្សាយ នូវបញ្ជីតំណាងបេតិកភណ្ឌវប្បធម៌អរូបី របស់មនុស្សជាតិនេះ។

មាត្រា ១៧.- បញ្ជីបេតិកភណ្ឌវប្បធម៌អរូបី ចាំបាច់សម្រាប់ទទួលការពារជាបន្ទាន់

១.ដើម្បីចាត់វិធានការការពារឱ្យបានសមស្រប គណៈកម្មាធិការត្រូវធ្វើជាប្រចាំនិងបោះពុម្ពផ្សាយនូវបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី ដែលត្រូវទទួលការការពារជាបន្ទាន់ ហើយត្រូវចុះបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះតាមសំណើរបស់រដ្ឋភាគីសាមី។

២.គណៈកម្មាធិការចងក្រងលក្ខខណ្ឌចម្បង ហើយដាក់ជូនសុំការអនុម័តរបស់មហាសន្និបាត សម្រាប់ការធ្វើជាប្រចាំ និងការបោះពុម្ពផ្សាយនូវបញ្ជីទាំងនេះ។

៣.នៅក្នុងករណីបន្ទាន់បំផុតដែលលក្ខខណ្ឌសត្យានុម័តត្រូវបានទទួលការយល់ព្រមពីមហាសន្និបាត តាមសំណើរបស់គណៈកម្មាធិការ នោះគណៈកម្មាធិការត្រូវចុះឈ្មោះបេតិកភណ្ឌវប្បធម៌នោះនៅក្នុងបញ្ជីដូចបានរៀបរាប់នៅក្នុងកថាខណ្ឌទី១ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋភាគីសាមីដែលពាក់ព័ន្ធ។

មាត្រា ១៨.- កម្មវិធី គម្រោង និងសកម្មភាពក្នុងការការពារ បេតិកភណ្ឌវប្បធម៌អរូបី

១.ឈរលើមូលដ្ឋាននៃសំណើរបស់រដ្ឋភាគី និងអនុលោមទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយ គណៈកម្មាធិការ និងអនុម័តដោយមហាសន្និបាត នោះគណៈកម្មាធិការត្រូវជ្រើសរើសក្នុងរយៈពេលជាកំណត់និងជំរុញការអនុវត្តកម្មវិធី គម្រោងនិងសកម្មភាពមានលក្ខណៈជាតិ អនុតំបន់ ឬថ្នាក់តំបន់ក្នុងការការពារ បេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ ដែលគណៈកម្មាធិការប៉ាន់ប្រមាណថាសមស្របបំផុតទៅនឹងគោលការណ៍ និង គោលដៅរបស់អនុសញ្ញា និងដោយនៅរក្សាតម្រូវការជាពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍន៍។

២.ដើម្បីសម្រេចគោលដៅនេះគណៈកម្មាធិការទទួល ពិនិត្យ និងអនុម័តលើសំណើសុំជំនួយឧបត្ថម្ភជាអន្តរជាតិ ដែលរដ្ឋភាគីបានផ្តួចផ្តើមដើម្បីតាក់តែងសំណើទាំងនោះ។

៣.គណៈកម្មាធិការជួយដំណើរការអនុវត្តកម្មវិធី គម្រោង និងសកម្មភាពទាំងនោះ ដោយធ្វើការផ្សព្វផ្សាយនូវការប្រតិបត្តិដ៏ប្រសើរតាមបែបបទដែលគណៈកម្មាធិការជាអ្នកកំណត់។

## ជំពូកទី៥

## កិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ

មាត្រា ១៩.- កិច្ចសហប្រតិបត្តិការ

១.ដើម្បីសម្រេចគោលដៅរបស់អនុសញ្ញានេះ កិច្ចសហប្រតិបត្តិការអន្តរជាតិ រួមមានការផ្លាស់ប្តូរព័ត៌មាននិងបទពិសោធ ការផ្តួចផ្តើមគំនិតរួម ព្រមទាំងការបង្កើតឱ្យមានយន្តការ ជាអ្នកផ្តល់ជំនួយទៅឱ្យរដ្ឋភាគីដើម្បីជួយដល់ការខិតខំការពារបេតិកភណ្ឌវប្បធម៌អរូបីរបស់រដ្ឋភាគីនោះ។

២.ដោយមិនឱ្យប៉ះពាល់ដល់បទប្បញ្ញត្តិនៃច្បាប់ជាតិ និងប៉ះពាល់ដល់សិទ្ធិព្រមទាំងការប្រតិបត្តិតាមទំនៀមទម្លាប់របស់ខ្លួននោះ រដ្ឋភាគីទទួលស្គាល់ថាការការពារបេតិកភណ្ឌវប្បធម៌អរូបី គឺដើម្បីជាផលប្រយោជន៍ទូទៅរបស់មនុស្សជាតិ ហើយសុខចិត្តធ្វើសហប្រតិបត្តិការកម្រិតទ្វេភាគី កម្រិតអនុតំបន់ កម្រិតតំបន់ និងថ្នាក់អន្តរជាតិ។

មាត្រា២០._ គោលដៅរបស់ជំនួយអន្តរជាតិ

ជំនួយអន្តរជាតិអាចត្រូវបានផ្តល់ឱ្យសម្រាប់គោលដៅដូចខាងក្រោម:

ក.ការការពារបេតិកភណ្ឌដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី ដែលទាមទារឱ្យមានការការពារជាបន្ទាន់

ខ.ការរៀបចំបញ្ជីសារពើភណ្ឌតាមមាត្រា ១១ និង ១២

គ.ការគាំទ្រដល់កម្មវិធី គម្រោង និងសកម្មភាព ដែលដឹកនាំនៅថ្នាក់ជាតិ ថ្នាក់អនុតំបន់ និងថ្នាក់តំបន់ គឺជាគោលដៅនៃការការពារបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ

ឃ.គោលដៅផ្សេងទៀតរបស់គណៈកម្មាធិការយល់ឃើញថាចាំបាច់។

មាត្រា២១. រូបភាពនៃជំនួយអន្តរជាតិ

ជំនួយដែលគណៈកម្មាធិការផ្តល់ទៅឱ្យរដ្ឋភាគី ត្រូវកំណត់ដោយសេចក្តីណែនាំប្រតិបត្តិដូចមានចែងក្នុងមាត្រា៧និងតាមការព្រមព្រៀងដូចមានចែងក្នុងមាត្រា ២៤ ហើយអាចមានរូបភាពដូចខាងក្រោម:

ក.ការសិក្សាអំពីទិដ្ឋភាពនានានៃការការពារ

ខ.ការផ្តល់អ្នកជំនាញការ និងអ្នកហ្វឹកហាត់

គ.ការបណ្តុះបណ្តាលបុគ្គលិកទាំងអស់ដែលចាំបាច់

ឃ.ការរៀបរៀងបណ្តាវិធានការច្បាប់ និងវិធានការដទៃទៀត

ង.ការបង្កើតនិងការធ្វើអាជីវកម្មផ្នែកហេដ្ឋារចនាសម្ព័ន្ធ

ច.ការផ្តល់ឱ្យនូវគ្រឿងបរិក្ខារ និងចំណេះធ្វើ

ឆ.រូបភាពដទៃទៀតនៃជំនួយខាងហិរញ្ញវត្ថុ និងបច្ចេកទេសរួមទាំងការផ្តល់អំណោយ និងប្រាក់កម្ចីដោយយកអត្រាការប្រាក់ទាបបំផុតនៅក្នុងករណីចាំបាច់។

មាត្រា ២២.- លក្ខខណ្ឌនៃជំនួយអន្តរជាតិ

១.គណៈកម្មាធិការត្រូវបង្កើតនីតិវិធីសម្រាប់ពិនិត្យសំណើសុំជំនួយអន្តរជាតិ ហើយត្រូវបញ្ជាក់ច្បាស់តើព័ត៌មានអ្វីដែលត្រូវបញ្ចូលនៅក្នុងសំណើទាំងនោះ ដូចជាមធ្យោបាយដែលបានគិតគូរ អន្តរាគមន៍ជាចាំបាច់ហើយនិងការប៉ាន់ប្រមាណអំពីតម្លៃ។

២.ក្នុងករណីបន្ទាន់ គណៈកម្មាធិការត្រូវពិនិត្យសំណើសុំជំនួយជាអាទិភាព។

៣.ដើម្បីឈានដល់ការសម្រេចសេចក្តី គណៈកម្មាធិការត្រូវធ្វើការសិក្សានិងធ្វើការពិគ្រោះគ្នាតាមការចាំបាច់។

មាត្រា ២៣.- សំណើសុំជំនួយអន្តរជាតិ

១.រដ្ឋភាគីនីមួយៗអាចធ្វើសំណើសុំជំនួយអន្តរជាតិទៅគណៈកម្មាធិការ សម្រាប់ការការពារ បេតិកភណ្ឌវប្បធម៌អរូបីដែលមាននៅក្នុងទឹកដីរបស់ខ្លួន។

២.សំណើបែបនេះក៏អាចដាក់ជូនរួមគ្នាដោយរដ្ឋភាគីពីរ ឬច្រើនក៏បានដែរ។

៣.សំណើសុំនេះត្រូវបញ្ចូលទាំងព័ត៌មានដូចមានចែងនៅក្នុងមាត្រា២២ កថាខណ្ឌទី១ដោយភ្ជាប់ជាមួយនូវឯកសារចាំបាច់។

មាត្រា ២៤.- តួនាទីរបស់រដ្ឋភាគីដែលទទួលជំនួយ

១.សមស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ ជំនួយអន្តរជាតិដែលផ្តល់ឱ្យត្រូវគ្រប់គ្រងដោយកិច្ចព្រមព្រៀងទទួលជំនួយជាមួយនិងគណៈកម្មាធិការ។

២.តាមវិធានទូទៅ រដ្ឋភាគីទទួលជំនួយត្រូវរួមចំណែកតាមកម្រិតនៃមធ្យោបាយរបស់ខ្លួន ក្នុងចំណោមថ្លៃការពារបន្ទាន់ពីទទួលបាននូវជំនួយអន្តរជាតិ។

៣.រដ្ឋភាគីទទួលជំនួយផ្ញើជូនគណៈកម្មាធិការវិញ នូវរបាយការណ៍ស្តីពីការប្រើប្រាស់ជំនួយ ដែលទទួលបានសម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបី។

## **ជំពូកទី ៦**
## **មូលនិធិនៃបេតិកភណ្ឌវប្បធម៌អរូបី**

មាត្រា ២៥.- ប្រភេទ និងប្រភពមូលនិធិ

១.មូលនិធិសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌អរូបី ត្រូវបានបង្កើតឡើងហើយបន្ទាប់មកត្រូវបានគេហៅថា" មូលនិធិ" ។

២."មូលនិធិ" ក្លាយជាមូលនិធិតម្កល់ស្របតាមបទប្បញ្ញត្តិនៃបទបញ្ជាហិរញ្ញវត្ថុរបស់អង្គការយូណេស្កូ។

៣.ប្រភពរបស់មូលនិធិនេះបានមកពី:

ក.វិភាគទានរបស់រដ្ឋភាគីទាំងអស់

ខ.មូលនិធិសម្រាប់គម្រោងនេះត្រូវបានផ្តល់ឱ្យដោយមហាសន្និបាតរបស់អង្គការយូណេស្កូ

គ.វិភាគទាន អំណោយ ឬអច្ច័យទានដែលបានមកពី:

១.រដ្ឋដទៃទៀត

២.អង្គការ និងកម្មវិធីរបស់ប្រព័ន្ធនៃអង្គការសហប្រជាជាតិ ជាពិសេសកម្មវិធីរបស់អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍ ក៏ដូចជាអង្គការអន្តរជាតិដទៃទៀត

៣.អង្គការសាធារណៈ ឬឯកជន ឬបុគ្គលឯកជនទាំងឡាយ

ឃ.ការប្រាក់បានមកពីប្រភពធនធានរបស់មូលនិធិ

ង.ផលនៃការរៃអង្គាសនិងចំណូលដែលទទួលបានពីពិធីសំដែងនានាដែលធ្វើឡើងសម្រាប់ជាប្រយោជន៍ដល់មូលនិធិ

ច.ធនធានផ្សេងទៀត ដែលបានមកតាមការអនុញ្ញាតដោយបទបញ្ញានៃមូលនិធិ ដែលរៀបចំឡើងដោយគណៈកម្មាធិការ ។

៤.ការប្រើប្រាស់ធនធានដោយគណៈកម្មាធិការត្រូវសម្រេចដោយឈរលើមូលដ្ឋាននៃការតម្រង់ទិសរបស់មហាសន្និបាត ។

៥.គណៈកម្មាធិការអាចទទួលយកនូវវិភាគទាន និងជំនួយតាមរូបភាពផ្សេងៗទៀត ដែលគេផ្តល់ឱ្យសម្រាប់សេចក្តីត្រូវការជាទូទៅ និងគោលដៅសម្រាប់គោលបំណងទូទៅ និង ជាក់លាក់សម្រាប់គំរោងណាមួយជាកំណត់ ប្រសិនបើគម្រោងទាំងនោះត្រូវបានទទួលការ ឯកភាពពីគណៈកម្មាធិការរួចហើយ។

៦.វិភាគទានសម្រាប់មូលនិធិពុំអាចធ្វើឡើងតាមលក្ខខណ្ឌនយោបាយ សេដ្ឋកិច្ចដែលមានវិសមិតភាពជាមួយនឹងវត្ថុបំណងរបស់អនុសញ្ញានេះទេ ។

មាត្រា២៦._វិភាគទានរបស់រដ្ឋភាគីទៅក្នុងមូលនិធិ

១.ដោយមិនឱ្យប៉ះពាល់ដល់វិភាគទានស្ម័គ្រចិត្តជាបន្ថែមនោះ រដ្ឋភាគីនៃអនុសញ្ញាជាអ្នករ៉ាប់រងបង់វិភាគទានចូលក្នុងមូលនិធិតាមអត្រាភាគរយឯកភាព សម្រាប់រដ្ឋភាគីទាំងអស់រៀងរាល់២ឆ្នាំម្តងយ៉ាងតិច ហើយចំនួនទឹកប្រាក់នៃវិភាគទាននោះត្រូវកំណត់ដោយមហាសន្និបាត ។ សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកតាមសំឡេងភាគច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតដែលមិនបានប្រកាស

ដូចមានចែងក្នុងកថាខណ្ឌទី២របស់មាត្រានេះ ។ ពុំមានករណីដែលវិភាគទានរបស់រដ្ឋភាគីលើសពី ១ភាគរយនៃវិភាគទានរបស់ខ្លួន ចូលក្នុងថវិកាទៀងទាត់របស់អង្គការយូណេស្កូទេ ។

២.ជានិច្ចកាល រដ្ឋទាំងអស់ដូចបានកំណត់នៅក្នុងមាត្រា៣២ឬមាត្រា៣៣នៃអនុសញ្ញានេះ នៅពេល តម្កល់លិខិតូបករណ៍ឱ្យសច្ចាប័ន ការទទួលយកការយល់ព្រម ឬចូលជាសមាជិកអាចប្រកាសថាពុំ មានអ្វីទាក់ទងជាមួយបទប្បញ្ញត្តិនៃកថាខណ្ឌទី១ នៃអនុសញ្ញានេះទេ ។

៣.រដ្ឋភាគីមួយរបស់អនុសញ្ញានេះ ដែលបានធ្វើសេចក្តីប្រកាសស្របតាមកថាខណ្ឌទី២នៃមាត្រានេះ នឹងត្រូវខិតខំ ដកយកសេចក្តីប្រកាសនោះមកវិញ ដោយគ្រាន់តែជូនដំណឹងទៅអគ្គនាយក អង្គការ យូណេស្កូ ។ ទោះជាយ៉ាងណាក៏ដោយ ការដកយកសេចក្តីប្រកាសមកវិញនេះ នឹងពុំមានផលប៉ះពាល់ ដល់ការបាត់បង់វិភាគទាន ដែលរដ្ឋភាគីនោះត្រូវបង់ទេ ចាប់ពីកាលបរិច្ឆេទនៃការបើកសម័យប្រជុំ បន្ទាប់ទៀតរបស់មហាសន្និបាត ។

៤.ដើម្បីឱ្យគណៈកម្មាធិការបានត្រៀមលក្ខណៈរៀបចំប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព វិភាគទាន របស់រដ្ឋភាគីនៃអនុសញ្ញានេះ ដែលបានធ្វើសេចក្តីប្រកាស ហើយដូចមានចែងនៅក្នុងកថាខណ្ឌទី២នៃ មាត្រានេះ វិភាគទានទៀងទាត់ គឺយ៉ាងហោចណាស់ក៏ត្រូវបង់នៅរៀងរាល់២ឆ្នាំម្តង ហើយត្រូវឱ្យជិត ស្មើនឹងវិភាគទានដែលរដ្ឋទាំងនោះត្រូវបង់ ប្រសិនបើគេឋិតនៅក្នុងស្ថានភាព ដូចមានចែងក្នុង កថាខណ្ឌទី១នៃមាត្រានេះ ។

៥.រដ្ឋភាគីទាំងអស់នៃអនុសញ្ញានេះ ដែលយឺតយ៉ាវមិនទាន់បានបង់វិភាគទានជាកំហិត ឬដោយ ស្ម័គ្រចិត្តសម្រាប់ឆ្នាំហើយនិងឆ្នាំចាស់ដែលទើបនឹងផុតទៅ រដ្ឋនោះមិនត្រូវបានចាត់ទុកជាសមាជិក ដែលមានសិទ្ធិបោះឆ្នោតជ្រើសរើសចូលក្នុងគណៈកម្មាធិការបានឡើយ បញ្ញត្តិនេះនឹងមិនយកទៅ អនុវត្តចំពោះការបោះឆ្នោតលើកទី១ទេ ។ អាណត្តិរបស់រដ្ឋភាគីណាមួយដែលបានក្លាយជាសមាជិក របស់គណៈកម្មាធិការរួចហើយ នឹងត្រូវបញ្ចប់នៅពេលបោះឆ្នោតដូចមានចែងក្នុងមាត្រា ៦ របស់ អនុសញ្ញានេះ ។

មាត្រា២៧.‐ វិភាគទានដោយស្ម័គ្រចិត្តបន្ថែមទៅក្នុងមូលនិធិ

រដ្ឋភាគីដែលមានបំណងផ្តល់វិភាគទានបន្ថែមទៅលើវិភាគទាន ដូចដែលមានចែងនៅក្នុង មាត្រា២៦នោះ ត្រូវជូនដំណឹងទៅគណៈកម្មាធិការឱ្យបានឆាប់បំផុតដែលអាចធ្វើបាន ដើម្បីឱ្យ គណៈកម្មាធិការរៀបចំប្រតិបត្តិការរបស់ខ្លួនឱ្យបានសមស្របទៅតាមនោះ ។

មាត្រា២៨.‐ យុទ្ធនាការនៃការរៃអង្គាសមូលនិធិអន្តរជាតិ

រដ្ឋភាគីត្រូវផ្តល់ជំនួយឱ្យបានច្រើនដែលអាចធ្វើបានដល់យុទ្ធនាការអន្តរជាតិដែលរៀបចំដើម្បីជាប្រយោជន៍ដល់មូលនិធិ ក្រោមការចាត់ចែងរបស់អង្គការយូណេស្កូ។

## ជំពូកទី៧

## របាយការណ៍

មាត្រា ២៩._ របាយការណ៍របស់រដ្ឋភាគី

រដ្ឋភាគីត្រូវផ្ញើជូនគណៈកម្មាធិការតាមរូបភាព និងរយៈពេលដែលកំណត់ដោយគណៈកម្មាធិការនូវរបាយការណ៍ស្តីពីបញ្ញត្តិច្បាប់ បទបញ្ញា និងវិធានការផ្សេងៗទៀត សម្រាប់ការប្រតិបត្តិតាមអនុសញ្ញានេះ។

មាត្រា ៣០._ របាយការណ៍របស់គណៈកម្មាធិការ

១.ដោយឈរលើមូលដ្ឋាននៃសកម្មភាពរបស់គណៈកម្មាធិការ និងរបាយការណ៍របស់រដ្ឋភាគីដូចមានចែងក្នុង មាត្រា២៩ គណៈកម្មាធិការត្រូវផ្ញើរបាយការណ៍ទៅជូនរាល់សម័យប្រជុំមហាសន្និបាត។

២.របាយការណ៍នេះនឹងត្រូវដាក់ជូនមហាសន្និបាតរបស់អង្គការយូណេស្កូ។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

មាត្រា ៣១._ ទំនាក់ទំនងទៅនឹងការប្រកាសស្នាដៃឯក នៃបេតិកភណ្ឌសំដី និងអរូបីរបស់មនុស្សជាតិ

១.គណៈកម្មាធិការបញ្ចូលទៅក្នុងបញ្ជីនៃបេតិកភណ្ឌវប្បធម៌អរូបី របស់មនុស្សជាតិ នូវអ្វីដែលបានប្រកាស ថាជា"ស្នាដៃឯកនៃបេតិកភណ្ឌសំដីនិងអរូបីរបស់មនុស្សជាតិ " មុនពេលអនុសញ្ញានេះចូលជាធរមាន។

២.ការបញ្ចូលនូវស្នាដៃទាំងនេះ ទៅក្នុងបញ្ជីរាយឈ្មោះនៃបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ នោះមិនត្រូវខុសពីលក្ខខណ្ឌសម្រាប់ការចុះបញ្ជីដែលបានកំណត់ ស្របតាមមាត្រា ១៦ កថាខណ្ឌទី២ទេ។

៣.គ្មានសេចក្តីប្រកាសណាមួយទៀតដែលត្រូវធ្វើឡើង បន្ទាប់ពីអនុសញ្ញានេះចូលជាធរមានបានឡើយ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

មាត្រា ៣២.- ការផ្ដល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម

១.អនុសញ្ញាត្រូវដាក់ជូនសុំសច្ចាប័ន ទទួលយក ឬយល់ព្រមដោយរដ្ឋសមាជិក អង្គការយូណេស្កូ ស្រប តាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ។

២.លិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ត្រូវតម្កល់ទុកនៅជាមួយ អគ្គនាយក នៃអង្គការយូណេស្កូ។

មាត្រា ៣៣.- ការចូលជាសមាជិកនៃអនុសញ្ញា

១.អនុសញ្ញានេះបើកចំហសម្រាប់ការចូលរួមជាសមាជិករបស់រដ្ឋទាំងអស់ ដែលមិនមែនជាសមាជិក របស់អង្គការយូណេស្កូ ហើយដែលត្រូវបានមហាសន្និបាតរបស់អង្គការយូណេស្កូ អំពាវនាវសុំឱ្យចូលរួម ក្នុងអនុសញ្ញានេះ។

២.អនុសញ្ញានេះបើកចំហសម្រាប់ការចូលរួមជាសមាជិករបស់ទឹកដីដែលមានស្វ័យភាពផ្ទៃក្នុង ពេញលេញ ហើយដែលត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ប៉ុន្តែមិនទាន់បានទទួល ឯករាជពេញលេញតាម សេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ១៥១៤(XV) ហើយដែលមានសមត្ថកិច្ច ចំពោះរឿងដែល អនុសញ្ញានេះបានកំណត់ព្រមទាំងមាន សមត្ថភាពគ្រប់គ្រាន់សម្រាប់ចុះហត្ថលេខាស្ដីពីបញ្ហានេះ។

៣.លិខិតូបករណ៍នៃការចូលរួមក្នុងអនុសញ្ញាត្រូវតម្កល់ទុកនៅជាមួយអគ្គនាយកនៃអង្គការយូណេស្កូ។

មាត្រា ៣៤. ការចូលជាធរមាន

អនុសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេល ៣ខែ ចាប់ពីកាលបរិច្ឆេទនៃការតម្កល់ លិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ការទទួកយក ការយល់ព្រម ឬការចូលរួមក្នុងអនុសញ្ញាទី៣០ ប៉ុន្តែ ចំពោះតែរដ្ឋទាំងឡាយណាដែលបានតម្កល់លិខិតូបករណ៍ផ្ដល់សច្ចាប័នការទទួលយក ការយល់ព្រម ឬការចូលរួមរបស់ខ្លួន នៅមុន ឬចំកាលបរិច្ឆេទនេះប៉ុណ្ណោះ។ អនុសញ្ញានេះនឹងចូលជាធរមាន ចំពោះ រដ្ឋភាគីដទៃទៀត ក្នុងរយៈពេល ៣ ខែបន្ទាប់ពីការតម្កល់លិខិតូបករណ៍ផ្ដល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលរួមក្នុងអនុសញ្ញា របស់រដ្ឋទាំងនោះ។

មាត្រា ៣៥.- របបរដ្ឋធម្មនុញ្ញសហព័ន្ធ ឬមិនមែនរដ្ឋទោល

បទប្បញ្ញត្តិដូចខាងក្រោមនេះ នឹងយកមកអនុវត្តចំពោះរដ្ឋ ដែលប្រកាន់រដ្ឋធម្មនុញ្ញ សហព័ន្ធ ឬមិនមែនរដ្ឋទោល ៖

ក. ចំពោះបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលការអនុវត្តឋិតនៅក្រោមសមត្ថកិច្ចនៃនីតិប្បញ្ញត្តិសហព័ន្ធ ឬអំណាចនីតិប្បញ្ញត្តិកណ្តាល នោះកាតព្វកិច្ចរបស់រដ្ឋាភិបាលសហព័ន្ធ ឬរដ្ឋាភិបាលកណ្តាលដូចគ្នានឹងកាតព្វកិច្ចរបស់រដ្ឋភាគី ដែលមិនមែនជារដ្ឋសហព័ន្ធ។

ខ. ចំពោះបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលការអនុវត្តឋិតនៅក្រោមសមត្ថកិច្ចនៃរដ្ឋនីមួយៗ ប្រទេស ខេត្ត ឬតំបន់នីមួយៗដែលមិនឋិតនៅក្រោមរបបរដ្ឋធម្មនុញ្ញសហព័ន្ធ ត្រូវចាត់វិធានការច្បាប់ទាំងឡាយនោះ រដ្ឋាភិបាលសហព័ន្ធត្រូវជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋប្រទេស ខេត្ត ឬតំបន់ទាំងនោះ អំពី យោបល់ឯកភាពរបស់ខ្លួនលើអនុសញ្ញានេះសម្រាប់ឱ្យអាជ្ញាធរទាំងនោះធ្វើការអនុម័ត។

មាត្រា ៣៦.- ការដកខ្លួនចេញ

១.រដ្ឋភាគីនីមួយៗអាចដកខ្លួនចេញពីអនុសញ្ញានេះបាន។

២.ការដកខ្លួនចេញត្រូវជូនដំណឹងជាលិខិតូបករណ៍លាយលក្ខណ៍អក្សរ ទៅតម្កល់ទុកនៅជាមួយអគ្គនាយក នៃអង្គការយូណេស្កូ។

៣.ការដកខ្លួនចេញ នឹងមានប្រសិទ្ធភាពក្នុងរយៈពេល ១២ខែ បន្ទាប់ពីការទទួលលិខិតូបករណ៍នៃការដកខ្លួននេះ ។ ការដកខ្លួនចេញនេះនឹងមិនធ្វើឱ្យប្រែប្រួលដល់កាតព្វកិច្ចផ្នែកហិរញ្ញវត្ថុរបស់រដ្ឋភាគីដែលធ្វើបណ្តឹងរហូតដល់កាលបរិច្ឆេទនៃការដកខ្លួនចេញមានអនុភាពតាមច្បាប់។

មាត្រា ៣៧.- តួនាទីរបស់អ្នកតម្កល់ឯកសារ

អគ្គនាយកនៃអង្គការយូណេស្កូ នៅក្នុងឋានៈជាអ្នកតម្កល់អនុសញ្ញានេះ ត្រូវជូនដំណឹងទៅរដ្ឋសមាជិករបស់អង្គការ ទៅរដ្ឋមិនមែនជាសមាជិករបស់អង្គការដូចមានចែងក្នុងមាត្រា ៣៣ ព្រមទាំងទៅអង្គការសហប្រជាជាតិ អំពីការដាក់តម្កល់ លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយកការយល់ព្រម ឬការចូលរួមក្នុងអនុសញ្ញាដូចមានចែងក្នុង មាត្រា ៣២ និង ៣៣ និងអំពីការដកខ្លួនចេញដូចមានចែងក្នុងមាត្រា ៣៦ ។

មាត្រា ៣៨.- ការធ្វើវិសោធនកម្ម

១.រដ្ឋភាគីទាំងអស់អាចស្នើសុំធ្វើវិសោធនកម្មអនុសញ្ញានេះ ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយក ។ អគ្គនាយកត្រូវបញ្ជូនសេចក្តីជូនដំណឹងទៅរដ្ឋភាគីទាំងអស់នោះ ហើយមានរដ្ឋភាគីមិនតិចជាងពាក់កណ្តាលឆ្លើយតបគាំទ្រសំណើនោះ លោកអគ្គនាយកត្រូវដាក់សំណើនេះ ជូនសម័យប្រជុំបន្ទាប់របស់មហាសន្និបាតសម្រាប់ធ្វើការពិភាក្សានិងការអនុម័តជាយថាហេតុ។

២.ការធ្វើវិសោធនកម្មត្រូវបានអនុម័តដោយសំឡេងភាគច្រើន ២/៣ នៃចំនួនរដ្ឋដែលវត្តមាននិងបោះឆ្នោត ។

៣.វិសោធនកម្មនៃអនុសញ្ញាបន្ទាប់ពីបានអនុម័តរួចហើយនឹងត្រូវផ្ញើជូនទៅរដ្ឋភាគីទាំងអស់ដើម្បីផ្តល់សច្ចាប័នទទួលយក យល់ព្រម ឬចូលរួម។

៤.ចំពោះរដ្ឋភាគីទាំងឡាយដែលបានផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលរួមវិសោធនកម្មនៃអនុសញ្ញានេះ នឹងចូលជាធរមានក្នុងអំឡុងពេល៣ខែ បន្ទាប់ពីការដាក់តម្កល់លិខិតូបករណ៍ដូចមានចែងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រានេះដោយរដ្ឋភាគីចំនួន២ភាគ៣ ។ បន្ទាប់មក ចំពោះរដ្ឋសមាជិកនីមួយៗ ដែលបានផ្តល់សច្ចាប័នទទួលយក យល់ព្រម ឬចូលរួមធ្វើវិសោធនកម្ម វិសោធនកម្មនេះនឹងចូលជាធរមាន ក្នុងអំឡុងពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតូបករណ៍សំរាប់ការផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬការចូលរួមរបស់រដ្ឋភាគីនោះ។

៥.នីតិវិធីដូចមានចែងនៅក្នុងកថាខណ្ឌទី៣និងទី៤មិនយកមកអនុវត្តចំពោះការធ្វើវិសោធនកម្មទៅលើមាត្រា ៥ ដែលទាក់ទងទៅនឹងចំនួនរដ្ឋសមាជិករបស់គណៈកម្មាធិការឡើយ ។ វិសោធនកម្មទាំងនេះនឹងចូលជាធរមាននិងត្រូវបានអនុម័ត។

៦.រដ្ឋមួយដែលនឹងក្លាយទៅជាភាគីរបស់អនុសញ្ញានេះបន្ទាប់ពីការចូលជាធរមាននៃវិសោធនកម្មដូចមានចែងនៅក្នុងកថាខណ្ឌទី៤ នៃមាត្រានេះ ហើយមិនបានបង្ហាញនូវបំណងផ្សេងពីនេះ និងត្រូវចាត់ទុកថា:

ក.ជាភាគីរបស់អនុសញ្ញាដូចដែលបានធ្វើវិសោធនកម្មនេះហើយ

ខ.ជាភាគីរបស់អនុសញ្ញាដែលមិនទាន់បានធ្វើវិសោធនកម្ម ចំពោះរដ្ឋភាគីទាំងអស់ដែលមិនជាប់ពាក់ព័ន្ធនឹង ធ្វើវិសោធនកម្មនេះ។

មាត្រា ៣៩._ អត្ថបទដែលអាចប្រើការបានដូចគ្នា

អនុសញ្ញានេះត្រូវបានបកប្រែជាភាសា អង់គ្លេស អារ៉ាប់ ចិន អេស្ប៉ាញ បារាំង និង រុស្ស៊ី ដែលអត្ថបទបកប្រែជាភាសាទាំង ៦នេះអាចប្រើការបានដូចគ្នា។

មាត្រា ៤០._ ការចុះបញ្ជីការ

អនុលោមតាមមាត្រា១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ អនុសញ្ញានេះត្រូវចុះបញ្ជីការនៅអគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ តាមរយៈការស្នើសុំរបស់ អគ្គនាយកនៃអង្គការយូណេស្កូ។

# សេចក្តីណែនាំប្រតិបត្តិស្តីពីការអនុវត្តអនុសញ្ញាស្តីពីការអភិរក្ស បេតិកភណ្ឌវប្បធម៌អរូបិយ

អនុម័តដោយមហាសន្និបាតនៅសម័យប្រជុំសាមញ្ញលើកទី២

*(នៅទីក្រុងប៉ារីស ប្រទេសបារាំង ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៨)*

## មាតិកា


**ជំពូកទី I: ការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ ........ ៣០**

១.១. ការចុះឈ្មោះចូលទៅក្នុងបញ្ជីអភិរក្សបន្ទាន់ ........ *៣០*

១.២ ការចុះឈ្មោះចូលទៅក្នុងបញ្ជីតំណាង ........ *៣៦*

១.៣ ការដាក់បញ្ចូលបេតិកភណ្ឌដែលបានប្រកាសជាសាធារណៈថាជា “ស្នាដៃឯកនៃបេតិកភណ្ឌ អរូបិយមនុស្សជាតិ” ទៅក្នុងបញ្ជីតំណាង ........ *៤០*

១.៤ កម្មវិធី គម្រោង និងសកម្មភាពដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីគោលការណ៍ និងគោលបំណង នៃអនុសញ្ញានេះ ........ *៤៣*

**ជំពូកទី II: ជំនួយអន្តរជាតិ និង មូលនិធិបេតិកភណ្ឌវប្បធម៌អរូបិយ ........ ៤៦**

២.១ គោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់ធនធាននៃមូលនិធិ ........ *៤៦*

២.២ ជំនួយអន្តរជាតិ ........ *៤៧*

**ជំពូកទី III: ការចូលរួមនៅក្នុងការអនុវត្តអនុសញ្ញា ........ ៥១**

៣.១ ការចូលរួមរបស់សហគមន៍ ក្រុម និង បើសិនជាអាចចំពោះក្រុមផ្សេងទៀតដូចជាបុគ្គលអ្នកជំនាញ មជ្ឈមណ្ឌលឯកទេស និងវិទ្យាស្ថាន ស្រាវជ្រាវ ........ *៥១*

៣.២ អង្គការក្រៅរដ្ឋាភិបាលនានា និង អនុសញ្ញា ........ *៥៣*

**ជំពូកទី IV: ការធ្វើរបាយការណ៍ទៅគណៈកម្មាធិការ ........ ៥៧**

## អក្សរកាត់

**មាត្រា** ៖ មាត្រានៃអនុសញ្ញានេះ ហើយប្រសិនបើមិនមានបញ្ជាក់ច្បាស់លាស់ទេនោះវានឹងមិនអាចប្រើប្រាស់បានទេ

**គណៈកម្មាធិការ** ៖ គណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ

**អនុសញ្ញា** ៖ អនុសញ្ញាស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ

**អគ្គនាយក** ៖ អគ្គនាយករបស់អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌

**មូលនិធិ** ៖ មូលនិធិរបស់បេតិកភណ្ឌវប្បធម៌អរូបិយ

**មហាសន្និបាត** ៖ មហាសន្និបាតរបស់រដ្ឋភាគីនៃអនុសញ្ញានេះ

**ICH** ៖ បេតិកភណ្ឌវប្បធម៌អរូបិយ

**ស្នាដៃឯក** ៖ ស្នាដៃឯកនៃបេតិកភណ្ឌវប្បធម៌អរូបិយមនុស្សជាតិ

**បញ្ជីតំណាង** ៖ បញ្ជីតំណាងនៃបេតិកភណ្ឌវប្បធម៌អរូបិយមនុស្សជាតិ

**សមាជិក** ៖ រដ្ឋដែលជាសមាជិកនៃអនុសញ្ញាស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ

**យូណេស្កូ** ៖ អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌

**បញ្ជីនៃការអភិរក្សបន្ទាន់** ៖ បញ្ជីនៃបេតិកភណ្ឌវប្បធម៌អរូបិយដែលត្រូវការ អភិរក្សជាបន្ទាន់

**1.COM** ៖ សម័យប្រជុំលើកដំបូងរបស់គណៈកម្មាធិការ

**1.EXT.COM** ៖ សម័យប្រជុំវិសាមញ្ញលើកដំបូងរបស់គណៈកម្មាធិការ

**1.GA** ៖ សម័យប្រជុំលើកដំបូងរបស់មហាសន្និបាត

**2.COM** ៖ សម័យប្រជុំលើកទីពីររបស់គណៈកម្មាធិការ

**2.EXT.COM** ៖ សម័យប្រជុំវិសាមញ្ញលើកទីពីរ របស់គណៈកម្មាធិការ

## ១.១ ការចុះឈ្មោះចូលទៅក្នុងបញ្ជីអភិរក្សបន្ទាន់ លក្ខណវិនិច្ឆ័យសម្រាប់ការចុះបញ្ជី

មាត្រា៧ (g)(i) និង ១៧

1.EXT.COM 6

១. នៅក្នុងសំណុំឯកសារចុះបញ្ជី រដ្ឋភាគីដែលបានដាក់ពាក្យសុំ ឬ ក្នុងករណីដែលមានភាពបន្ទាន់ខ្លាំង អ្នកចុះបញ្ជីត្រូវបានគេស្នើឱ្យបង្ហាញថា បេតិកភណ្ឌដែលបានស្នើសុំដាក់ បញ្ចូលទៅក្នុងបញ្ជីនៃការអភិរក្សបន្ទាន់នេះបំពេញទៅតាមលក្ខណវិនិច្ឆ័យដូចខាងក្រោម:

U.១ បេតិកភណ្ឌនេះគឺជាបេតិកភណ្ឌវប្បធម៌អរូបិយដូចដែលបានចែងនៅក្នុងមាត្រា ២ នៃអនុសញ្ញានេះ។

U.២ ក. បេតិកភណ្ឌនេះកំពុងស្ថិតក្នុងស្ថានភាព តម្រូវអោយមានការអភិរក្សបន្ទាន់ ដោយសារតែភាពរស់រានរបស់វាកំពុងប្រឈមទៅនឹងហានិភ័យ បើទោះជាមានការខិតខំប្រឹងប្រែងអភិរក្សពីសហគមន៍ ក្រុម ឬ បុគ្គល និងរដ្ឋភាគីដែល ពាក់ព័ន្ធ ក៏ដោយ។ ឬ

ខ. បេតិកភណ្ឌនេះកំពុងស្ថិតក្នុង ស្ថានភាព តម្រូវអោយមានការអភិរក្សបន្ទាន់ ដោយសារតែវាកំពុងប្រឈមទៅនឹងការគំរាមកំហែងដ៏ធ្ងន់ធ្ងរ ដែលធ្វើឱ្យគេមិន រំពឹងថាបេតិកភណ្ឌទាំងនេះ អាចរស់រានបានដោយគ្មានការអភិរក្សជាបន្ទាន់ នោះទេ។

U.៣ មានវិធានការអភិរក្សដែលអាចធ្វើឱ្យសហគមន៍ ក្រុម ឬ បុគ្គលដែលពាក់ព័ន្ធបន្តអនុវត្ត និងផ្ទេរនូវបេតិកភណ្ឌទាំងនេះត្រូវបានគេចាត់ឡើង។

U.៤ ជាបេតិកភណ្ឌដែលបានជ្រើសរើសបន្ទាប់ពីមានការចូលរួមជាវិជ្ជមាន និងដ៏ទូលំទូលាយពីសហគមន៍ ក្រុម ឬ បុគ្គលដែលពាក់ព័ន្ធ និងដោយមានការព្រមព្រៀងជាមុនដោយសេរី និងដោយ មានការជូនដំណឹងជាមុន។

U.៥ ជាបេតិកភណ្ឌដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីសារពើភណ្ឌនៃបេតិកភណ្ឌវប្បធម៌អរូបិយដែលមាននៅក្នុងទឹកដីនៃរដ្ឋភាគីដូចដែលបានចែងនៅក្នុងមាត្រា ១១ និង ១២នៃអនុសញ្ញានេះ។

U.៦ ក្នុងករណីដែលមានភាពបន្ទាន់ខ្លាំង រដ្ឋភាគីដែលពាក់ព័ន្ធបានពិភាក្សាយ៉ាងត្រឹមត្រូវទាក់ទិនទៅនឹងការដាក់បញ្ចូលបេតិកភណ្ឌនេះទៅក្នុងបញ្ជីអភិរក្សបន្ទាន់ស្របតាមមាត្រា ១៧.៣ នៃ អនុសញ្ញា។

## នីតិវិធីនៃការតែងតាំង

2.COM 6

២. រដ្ឋភាគីដែលដាក់ពាក្យស្នើសុំទាំងឡាយត្រូវបានគេស្នើឱ្យប្រើពាក្យសុំធ្វើការចុះបញ្ជីដែលភ្ជាប់មកជាមួយនឹងសេចក្តីណែនាំប្រតិបត្តិការនេះ និងធ្វើយ៉ាងណាឱ្យសហគមន៍ ក្រុម និងបុគ្គលដែលពាក់ព័ន្ធទាំងឡាយចូលរួមក្នុងការរៀបចំការចុះបញ្ជីរបស់ពួកគេនេះ។

៣. រដ្ឋភាគីទាំងឡាយ ត្រូវបានគេលើកទឹកចិត្តឱ្យរួមគ្នា ដាក់ពាក្យស្នើសុំការចុះបញ្ជីចម្រុះជាតិសាសន៍នៅពេលដែលបេតិកភណ្ឌមួយត្រូវបានគេរកឃើញនៅលើទឹកដីនៃរដ្ឋភាគីច្រើនជាងមួយ។

៤. រដ្ឋភាគីមួយអាចដកពាក្យសុំធ្វើការចុះបញ្ជីដែលខ្លួនបានដាក់ ស្នើមកវិញបានគ្រប់ពេលវេលាទាំងអស់មុនពេលដែលគណៈកម្មាធិការធ្វើការវាយតម្លៃ ដោយការដកពាក្យនេះគឺមិនជះឥទ្ធិពលអាក្រក់លើសិទ្ធិរបស់ខ្លួនក្នុងការទទួលបានផលប្រយោជន៍ពីជំនួយអន្តរជាតិដែលស្ថិតក្រោមអនុសញ្ញានេះ ឡើយ។

## ការត្រួតពិនិត្យទៅលើការចុះបញ្ជី

៥. មុននឹងគណៈកម្មាធិការធ្វើការវាយតម្លៃ ការចុះបញ្ជីត្រូវបានពិនិត្យជាដំបូងដោយស្ថាប័នផ្តល់ប្រឹក្សាលើសពីមួយដែលទទួលស្គាល់ស្របទៅតាមមាត្រា៩.១ នៃអនុសញ្ញានេះ។ អនុលោមទៅតាមមាត្រា ៨.៤ គណៈកម្មាធិការអាចអញ្ជើញស្ថាប័នឯកជន ឬសាធារណៈ និង/ឬបុគ្គលឯកជនដែលគេទទួលស្គាល់ថាមានសមត្ថភាពនៅក្នុងវិស័យបេតិកភណ្ឌវប្បធម៌អរូបិយមកធ្វើការពិភាក្សាលើបញ្ហាជាក់លាក់ទាំងឡាយ។ មិនមានការចុះបញ្ជីណាមួយនឹងត្រូវបានត្រួតពិនិត្យដោយប្រជាជាតិនៃរដ្ឋភាគីដែលបានដាក់ពាក្យស្នើសុំការចុះបញ្ជីនោះឡើយ។

៦. ការត្រួតពិនិត្យនេះត្រូវមានបញ្ចូលទាំងការវាយតម្លៃលើភាពស្របគ្នាទៅនឹងលក្ខណវិនិច្ឆ័យនៃការចុះឈ្មោះចូលទៅក្នុងបញ្ជីនៃការចុះបញ្ជីនេះ។

៧. ការត្រួតពិនិត្យត្រូវបញ្ចូលទាំងការវាយតម្លៃទៅលើភាពរស់រាននៃបេតិកភណ្ឌ និងភាពដែលអាចសម្រេចបាន និងភាពគ្រប់គ្រាន់នៃផែនការអភិរក្ស។ លើសពីនេះទៀត ការត្រួតពិនិត្យនេះក៏ត្រូវមានបញ្ចូលផងដែរ នូវការវាយតម្លៃលើហានិភ័យនៃការបាត់បង់បេតិកភណ្ឌនេះដែលបណ្តាលមកពីកង្វះមធ្យោបាយក្នុងការថែរក្សា និង អភិរក្ស ឬ ដោយសារដំណើរការសកលភាវូបនីយកម្ម និងបំរែបំរួលសង្គម និងបរិស្ថាន។

៨. របាយការណ៍ត្រួតពិនិត្យទាំងនេះត្រូវមានអនុសាសន៍ដែលផ្តល់ទៅឱ្យគណៈកម្មាធិការដើម្បីធ្វើការចុះឈ្មោះ ឬមិនចុះឈ្មោះបេតិកភណ្ឌដែលបានចុះបញ្ជីចូលទៅក្នុងបញ្ជី។

**ការវាយតម្លៃ និងការសម្រេចរបស់គណៈកម្មាធិការ**

៩. ដើម្បីធ្វើការចុះបញ្ជី លេខាធិការដ្ឋាននឹងបញ្ជូនទៅឱ្យគណៈកម្មាធិការនូវសេចក្តីសង្ខេបរបាយការណ៍ត្រួតពិនិត្យ និងរាល់ប្រតិកម្មរបស់រដ្ឋភាគីដែលពាក់ព័ន្ធទាំងឡាយ។ សំណុំឯកសារចុះបញ្ជី និងរបាយកាណ៍ត្រួតពិនិត្យទាំងនេះក៏នឹងត្រូវផ្តល់ទៅឱ្យរដ្ឋភាគីទាំងឡាយផងដែរសម្រាប់ធ្វើការពិភាក្សា។

១០. បន្ទាប់ពីធ្វើការវាយតម្លៃ គណៈកម្មាធិការនឹងធ្វើការសម្រេចថាតើបេតិកភណ្ឌមួយគួរតែដាក់បញ្ចូល ឬមិនគួរដាក់បញ្ចូលទៅក្នុងបញ្ជីអភិរក្សបន្ទាន់។

**ការចុះបញ្ជីដែលធ្វើឡើងក្នុងលក្ខខណ្ឌបន្ទាន់បំផុត** 2.COM 6

១១. ក្នុងករណីដែលមានភាពបន្ទាន់ខ្លាំង ហើយយោងទៅតាមលក្ខណវិនិច្ឆ័យ U.៦ គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគីដែលពាក់ព័ន្ធទាំងឡាយឱ្យដាក់ពាក្យស្នើសុំការចុះបញ្ជី ទៅតាមកាលវិភាគដែលបានពន្លឿន។ ដោយធ្វើការពិភាក្សាជាមួយរដ្ឋភាគីដែលពាក់ព័ន្ធ គណៈកម្មាធិការត្រូវធ្វើការវាយតម្លៃលើការចុះបញ្ជីឱ្យបានឆាប់បំផុតបន្ទាប់ពីទទួលបានពាក្យស្នើសុំដោយធ្វើឱ្យស្របទៅតាមនីតិវិធីដែលបង្កើតឡើងដោយគណៈកម្មាធិការទៅតាមករណីនីមួយៗ។

១២. ករណីដែលមានភាពបន្ទាន់ខ្លាំង ការចុះបញ្ជីអាចនឹងនាំទៅដល់ការយកចិត្តទុកដាក់ពីគណៈកម្មាធិការតាមរយៈរដ្ឋសមាជិកទាំងឡាយ ដែលបេតិកភណ្ឌនោះស្ថិតនៅ តាមរយៈរដ្ឋភាគី

ផ្សេងទៀត តាមរយៈសហគមន៍ដែលពាក់ព័ន្ធ ឬ តាមរយៈស្ថាប័នផ្តល់ប្រឹក្សាណាមួយ។ រដ្ឋភាគីដែល ពាក់ព័ន្ធទាំងឡាយនឹងត្រូវបានគេផ្តល់ព័ត៌មានជូនយ៉ាងទាន់ពេលវេលា។

**ការដកបេតិកភណ្ឌមួយចេញពីបញ្ជីអភិរក្សបន្ទាន់**

១៣. គណៈកម្មាធិការអាចដកបេតិកភណ្ឌមួយចេញពីបញ្ជីអភិរក្សបន្ទាន់ក្រោយពីការវាយតម្លៃលើការអនុវត្តផែនការអភិរក្សនេះបង្ហាញថា បេតិកភណ្ឌនេះមិនបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យមួយ ឬ ច្រើនសម្រាប់ការដាក់ បញ្ចូលទៅក្នុងបញ្ជីអភិរក្សនេះ។

**ការផ្ទេរបេតិកភណ្ឌពីបញ្ជីមួយទៅកាន់បញ្ជីមួយផ្សេងទៀត**

១៤. គេមិនអាចដាក់បេតិកភណ្ឌមួយភ្លាមៗចូលទៅក្នុងបញ្ជីតំណាង និងបញ្ជីអភិរក្សបន្ទាន់ឡើយ។ រដ្ឋភាគីអាចស្នើសុំផ្ទេរបេតិកភណ្ឌមួយ ពីបញ្ជីមួយទៅកាន់បញ្ជីមួយទៀតបាន។ ដើម្បីធ្វើការផ្ទេរ បេតិកភណ្ឌនោះត្រូវតែបំពេញទៅតាមលក្ខណវិនិច្ឆ័យរបស់បញ្ជីដែលបេតិកភណ្ឌនេះស្នើសុំធ្វើការផ្ទេរទៅ និងត្រូវដាក់ស្នើឱ្យស្របទៅនឹងនីតិវិធីដែលបានបង្កើត និងពេលវេលា ដែលបានកំណត់សម្រាប់ការចុះបញ្ជី។

**ការធ្វើបច្ចុប្បន្នកម្ម និងការបោះពុម្ពផ្សាយនៃការចុះបញ្ជីបន្ទាន់**

១៥. សំណុំឯកសារស្នើសុំការចុះបញ្ជី និងរបាយការណ៍ត្រួតពិនិត្យនៃបេតិកភណ្ឌដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីនេះ ត្រូវមាននៅលេខាធិការដ្ឋានសម្រាប់ធ្វើការពិភាក្សា និងប្រសិនបើអាចគឺត្រូវឱ្យមាននៅតាមប្រព័ន្ធអ៊ិនធឺណិត ដើម្បីធ្វើឱ្យទទួលបានព័ត៌មានជាទូទៅ។

១៦. ក្រោយពីទទួលបានការស្នើសុំពីគណៈកម្មាធិការ លេខាធិការដ្ឋានធ្វើការចេញផ្សាយនូវបញ្ជីតំណាងដែលបានធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ជាទូទៅគឺតាមរយៈគេហទំព័ររបស់អនុសញ្ញានេះ។ កំណែថ្មីដែលបានបោះពុម្ពនឹងត្រូវបានគេចេញផ្សាយរៀងរាល់ពីរឆ្នាំម្តងនៅក្នុងសម័យប្រជុំមហាសន្និបាតសាមញ្ញ។

**កាលវិភាគ និងសេចក្តីសង្ខេបនៃនីតិវិធី**[1] 2.COM 6

១៧. ***ដំណាក់កាលទី ១ : ការរៀបចំ និងការដាក់ពាក្យ***

០១ កញ្ញា_ឆ្នាំ០ ជាពេលកំណត់ដែលត្រូវស្នើសុំជំនួយការរៀបចំពីគណៈកម្មាធិការ។

៣១ មិនា_ឆ្នាំទី១ ជាពេលកំណត់ ដែលលេខាធិការដ្ឋានទទួលបានឯកសារចុះបញ្ជីដែលដាក់ជូន។ ការតែងតាំងទាំងឡាយណាដែលដាក់ជូនក្រោយកាលកំណត់នេះ នឹងត្រូវពិនិត្យនៅឆ្នាំក្រោយតាមកាលបរិច្ឆេទដូចគ្នា។

០១មិថុនា_ឆ្នាំទី១ ជាពេលកំណត់ ដែលលេខាធិការដ្ឋាននឹងពិនិត្យមើលលើដំណើរការនៃការតែងតាំង ដែលរួមទាំងការចុះឈ្មោះចូលទៅក្នុងបញ្ជី និងការទទួលស្គាល់លើការតែងតាំងដែលបានដាក់ជូន។ ប្រសិនបើគេមើលឃើញថា ការតែងតាំងមួយមិនមានលក្ខណៈពេញលេញ រដ្ឋភាគីនោះនឹងត្រូវបានគេណែនាំឱ្យបំពេញបន្ថែមលើការតែងតាំងនេះ។

០១ កញ្ញា_ឆ្នាំទី១ ជាពេលកំណត់ ដែលរដ្ឋសមាជិកត្រូវដាក់ជូនទៅលេខាធិការដ្ឋាននូវព័ត៌មានបន្ថែមទាំងឡាយ ដែលត្រូវការសម្រាប់បំពេញបន្ថែមលើការតែងតាំងនេះប្រសិនបើមាន។ ការតែងតាំងដែលមិនមានលក្ខណៈពេញលេញ អាចបំពេញបន្ថែមនៅឆ្នាំក្រោយ តាមកាលបរិច្ឆេទដូចគ្នា។

១. មហាសន្និបាតបានធ្វើការអនុម័តទៅលើប្រតិទិនអន្តរកាលសម្រាប់ការដាក់បញ្ចូលដំបូង ទៅក្នុងបញ្ជីនេះ (សូមមើលកថាខ័ណ្ឌទី ១៨ខាងក្រោម)

### ដំណាក់កាលទី ២: ការត្រួតពិនិត្យ

ខែកញ្ញា_ឆ្នាំទី១ ជាពេលដែលគណៈកម្មាធិការ ធ្វើការជ្រើសរើសស្ថាប័នផ្ដល់ប្រឹក្សា ស្ថាប័នស្រាវជ្រាវ និង/ឬ អ្នកជំនាញ ដែលទទួលខុសត្រូវលើការត្រួតពិនិត្យឯកសារចុះ បញ្ជីនីមួយៗ មួយ ឬ ច្រើន។

ខែ តុលា_ឆ្នាំទី១ ការត្រួតពិនិត្យ

ខែ មេសា_ឆ្នាំទី២

៣១ មិនា_ឆ្នាំទី២ ជាពេលកំណត់ ដែលរដ្ឋភាគីទាំងឡាយត្រូវដាក់ជូនទូវព័ត៌មានបន្ថែមទៅតាមសំណើរបស់អ្នកត្រួតពិនិត្យ ដើម្បីធ្វើការពិនិត្យឡើងវិញឱ្យបានត្រឹមត្រូវលើការចុះបញ្ជីមួយ។

០១ ឧសភា_ឆ្នាំទី២ លេខាធិការដ្ឋានបញ្ជូនរបាយការណ៍ត្រួតពិនិត្យ ដែលពាក់ព័ន្ធទៅកាន់រដ្ឋភាគីដែលត្រូវចុះបញ្ជី។

០១ សីហា_ឆ្នាំទី២ លេខាធិការដ្ឋានបញ្ជូនរបាយការណ៍ត្រួតពិនិត្យ ទៅកាន់សមាជិកគណៈកម្មាធិការ ។ សំណុំឯកសារស្នើសុំការចុះបញ្ជី និងរបាយការណ៍ត្រួតពិនិត្យ ក៏ត្រូវឱ្យមាននៅតាមប្រព័ន្ធអ៊ិនធឺណិតផងដែរ ដើម្បីឱ្យរដ្ឋភាគីទាំងឡាយ ធ្វើការពិភាក្សា។

**ដំណាក់កាលទី ៣: ការវាយតម្លៃ**

ខែ កញ្ញា_ឆ្នាំទី២ គណៈកម្មាធិការ វាយតម្លៃលើការចុះបញ្ជី និងធ្វើការ សម្រេច។

១៨. **កាលវិភាគអន្តរកាលសម្រាប់កាចុះឈ្មោះដំបូងទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបិយដែលត្រូវការការអភិរក្សជាបន្ទាន់** 2.COM 6

០១ តុលា ២០០៨ ជាពេលកំណត់ ដែលត្រូវស្នើសុំជំនួយការរៀបចំសម្រាប់ការរៀបចំការចុះបញ្ជីនេះ។

ខែ វិច្ឆិកា ២០០៨ ជាពេលដែលត្រូវធ្វើការវាយតម្លៃលើសំណើសុំជំនួយ ការរៀបចំ។

១៥ មិនា ២០០៩ ជាពេលកំណត់ ដែលលេខាធិការដ្ឋានទទួលបានការចុះបញ្ជីដែលដាក់ជូន។

១៥ មេសា ២០០៩ ជាពេលកំណត់ ដែលរដ្ឋភាគីទាំងឡាយត្រូវដាក់ជូនទៅកាន់លេខាធិការដ្ឋានទូវព័ត៌មានបន្ថែម សម្រាប់បំពេញទៅលើការចុះបញ្ជី

នេះប្រសិនបើមាន។ ការចុះបញ្ជីដែលមិនមានលក្ខណៈពេញលេញនឹងត្រូវបំពេញនៅឆ្នាំក្រោយតាមកាលបរិច្ឆេទដូចគ្នា (សម្រាប់ឆ្នាំ ២០១០)។

| | |
|---|---|
| ខែ មេសា ២០០៩ | ជាពេល ដែលគណៈកម្មាធិការធ្វើសេចក្ដីសម្រេចទៅលើអ្នកត្រួតពិនិត្យ ដែលនឹងត្រូវធ្វើការត្រួតពិនិត្យលើសំណុំឯកសារចុះបញ្ជីនីមួយៗ។ |
| ខែ មេសា_២០មិថុនា | ជាពេលដែលអ្នកត្រួតពិនិត្យការចុះបញ្ជីឆ្នាំ ២០០៩ ធ្វើការត្រួតពិនិត្យដើម្បីចុះឈ្មោះចូលទៅក្នុងបញ្ជី។ |
| ២៥ មិថុនា ២០០៩ | ជាពេលកំណត់ ដែលរដ្ឋភាគីទាំងឡាយត្រូវដាក់ជូននូវព័ត៌មានបន្ថែមទៅតាមការទាមទាររបស់អ្នកត្រួតពិនិត្យ ដើម្បីធ្វើការពិនិត្យឡើងវិញឱ្យបានត្រឹមត្រូវលើការចុះបញ្ជីនេះ។ |
| ០១ កក្កដា ២០០៩ | ជាពេល ដែលលេខាធិការដ្ឋានបញ្ជូននូវរបាយការណ៍ត្រួតពិនិត្យដែលពាក់ព័ន្ធទាំងឡាយទៅកាន់រដ្ឋភាគីដែលបានចុះបញ្ជី។ |
| ខែ សីហា ២០០៩ | ជាពេល ដែលលេខាធិការដ្ឋានបញ្ជូនរបាយការណ៍ត្រួតពិនិត្យទៅកាន់សមាជិកគណៈកម្មាធិការ។ រដ្ឋសមាជិកត្រូវទទួលបាននូវសំណុំឯកសារចុះបញ្ជី និងរបាយការណ៍ត្រួតពិនិត្យតាមរយៈព័ត៌មាននៅលើគេហទំព័ររបស់អនុសញ្ញានេះ។ |
| ខែ កញ្ញា ២០០៩ | ជាពេល ដែលគណៈកម្មាធិការធ្វើការវាយតម្លៃលើការចុះបញ្ជីដើម្បីចុះឈ្មោះជាលើកដំបូងចូលទៅក្នុងបញ្ជីអភិរក្សបន្ទាន់។ |

## ១.២ ការចុះឈ្មោះចូលទៅក្នុងបញ្ជីតំណាង

មាត្រា៧ (g)(i) និង ១៦

1.EXT.COM (

### លក្ខណវិនិច្ឆ័យសម្រាប់ការចុះឈ្មោះ

១៩. នៅក្នុងឯកសារចុះបញ្ជី រដ្ឋភាគីទាំងឡាយដែលបានដាក់ពាក្យសុំ ត្រូវបង្ហាញថាបេតិកភណ្ឌដែលបានស្នើសុំដាក់បញ្ចូលទៅក្នុងបញ្ជីតំណាងនេះ បានបំពេញទៅតាមលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

**R.១** បេតិកភណ្ឌនេះគឺជាបេតិកភណ្ឌវប្បធម៌អរូបិយ ដូចដែលបានចែង នៅក្នុងមាត្រា២នៃអនុសញ្ញានេះ។

**R.២** ការដាក់បញ្ចូលនូវបេតិកភណ្ឌនេះនឹងរួមចំណែកដល់ការធានានូវ ភាពរស់រាន និងការយល់ដឹងពីសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ អរូបិយ និងរួមចំណែកជំរុញឱ្យមានការពិភាក្សា ដែលទាំងនេះឆ្លុះពាំងពីភាពចម្រុះនៃវប្បធម៌ទូទាំងពិភពលោក និងការគាំទ្រដល់ គំនិតច្នៃប្រឌិតរបស់មនុស្សជាតិ។

**R.៣** វិធានការណ៍អភិរក្សដែលបង្កើតឡើងអាចអភិរក្ស និងលើកកម្ពស់ បេតិកភណ្ឌនេះ។

**R.៤** បេតិកភណ្ឌនេះត្រូវបានគេចុះបញ្ជីក្រោយពីមានការចូលរួមដ៏វិជ្ជមាន និងយ៉ាងទូលំទូលាយពីសហគមន៍ ក្រុម ឬ បុគ្គលដែលពាក់ព័ន្ធ និងដោយមានការព្រមព្រៀងជាមុនដោយសេរី និងដោយបានជូនដំណឹងជាមុនពីអ្នកចូលរួមទាំងនោះ។

**R.៥** សមាសធាតុនេះមានបញ្ចូលនូវបញ្ជីសារពើភណ្ឌ អំពីបេតិកភណ្ឌវប្បធម៌អរូបិយដែលមាននៅក្នុងទឹកដីរបស់រដ្ឋភាគី ដែលបានដាក់ពាក្យស្នើសុំដូចដែលបានចែងនៅក្នុងមាត្រា ១១ និង ១២នៃអនុសញ្ញានេះ។

## នីតិវិធីក្នុងការចុះបញ្ជី

២០. រដ្ឋភាគីទាំងឡាយ ត្រូវបានគេលើកទឹកចិត្តឱ្យរួមគ្នាដាក់ពាក្យស្នើសុំការចុះបញ្ជីចម្រុះជាតិសាសន៍នៅពេលដែលបេតិកភណ្ឌមួយត្រូវបានគេរកឃើញនៅលើទឹកដីនៃរដ្ឋភាគីច្រើនជាងមួយ។

២១. រដ្ឋភាគីដែលបានដាក់ពាក្យសុំ ត្រូវបានគេស្នើឱ្យប្រើពាក្យស្នើសុំការចុះបញ្ជីដែលភ្ជាប់មកជាមួយនឹងសេចក្តីណែនាំប្រតិបត្តិការនេះ និងធ្វើយ៉ាងណាឱ្យសហគមន៍ ក្រុម និងបុគ្គលដែលពាក់ព័ន្ធទាំងឡាយចូលរួមក្នុងការរៀបចំសម្រាប់ការចុះបញ្ជីនេះ។

២២. រដ្ឋភាគីមួយអាចដកពាក្យស្នើសុំការចុះបញ្ជីដែលខ្លួនបានដាក់មកវិញបាន គ្រប់ពេលវេលាទាំងអស់មុនពេលគណៈកម្មាធិការធ្វើការវាយតម្លៃ។

### ការត្រួតពិនិត្យលើការចុះបញ្ជី

2.COM 6

២៣. ការត្រួតពិនិត្យលើការចុះបញ្ជី ត្រូវធ្វើឡើងដោយស្ថាប័នរងរបស់គណៈកម្មាធិការនេះដែលបានបង្កើតឡើងស្របទៅតាមបញ្ញត្តិ ២១ នៃនីតិវិធីរបស់គណៈកម្មាធិការនេះ។

២៤. ការត្រួតពិនិត្យដែលធ្វើឡើងដោយស្ថាប័នរងត្រូវរាប់បញ្ចូលទាំងការវាយតម្លៃលើការគោរពទៅតាមលក្ខណវិនិច្ឆ័យនៃការដាក់ចូលទៅក្នុង បញ្ជីនៃការចុះបញ្ជីផងដែរ។

២៥. របាយការណ៍ត្រួតពិនិត្យត្រូវមានអនុសាសន៍ដែលផ្តល់ឱ្យគណៈកម្មាធិការ ដើម្បីឱ្យធ្វើការកំណត់ថាតើត្រូវដាក់បញ្ចូល ឬ មិនដាក់បញ្ចូលទៅក្នុងបញ្ជីនៃបេតិកភណ្ឌ ដែលបានចុះបញ្ជីនេះ ឬ យ៉ាងណា។

### ការវាយតម្លៃ និងការសម្រេចរបស់គណៈកម្មាធិការ

2.COM 6

២៦. ស្ថាប័នរងនឹងផ្តល់នូវសំណុំឯកសារចុះបញ្ជី និងរបាយការណ៍នៃការត្រួតពិនិត្យរបស់ពួកគេទាំងអស់ទៅឱ្យគណៈកម្មាធិការ ហើយឯកសារទាំងនេះក៏នឹងត្រូវផ្តល់ជូនដល់រដ្ឋភាគីទាំងឡាយដោយលេខាធិការដ្ឋាន ដើម្បីធ្វើការពិភាក្សាផងដែរ។

២៧. បន្ទាប់ពីធ្វើការវាយតម្លៃ គណៈកម្មាធិការធ្វើការសម្រេចថា តើត្រូវដាក់បញ្ចូល ឬ មិនត្រូវដាក់បញ្ចូលបេតិកភណ្ឌមួយទៅក្នុងបញ្ជីតំណាងនេះ។

២៨. ប្រសិនបើគណៈកម្មាធិការសម្រេចថាបេតិកភណ្ឌនេះមិនគួរដាក់បញ្ចូលទៅក្នុងបញ្ជីតំណាងទេនោះ ការចុះបញ្ជីនេះមិនអាចត្រូវបានគេដាក់ពាក្យសារជាថ្មីទៅកាន់គណៈកម្មាធិការ ដើម្បីស្នើសុំការចុះឈ្មោះចូលទៅក្នុង បញ្ជីនេះមុនរយៈពេល ៤ឆ្នាំក្រោយឡើយ។

### ការដកបេតិកភណ្ឌមួយចេញពីបញ្ជីតំណាង

2.COM 6

២៩.	គេអាចដកបេតិកភណ្ឌមួយចេញពីបញ្ជីតំណាងបាន នៅពេលដែលគណៈកម្មាធិការនេះកំណត់ថា បេតិកភណ្ឌនោះមិនបានបំពេញទៅតាមលក្ខណវិនិច្ឆ័យសម្រាប់ការចុះឈ្មោះចូលទៅក្នុងបញ្ជីនេះ។

**ការផ្ទេរបេតិកភណ្ឌពីបញ្ជីមួយទៅកាន់បញ្ជីមួយទៀត** 2.COM 6

៣០.	គេមិនអាចដាក់បេតិកភណ្ឌមួយក្លាមៗចូលទៅក្នុងបញ្ជីតំណាង និងបញ្ជីអភិរក្សបន្ទាន់ឡើយ។ រដ្ឋភាគីអាចស្នើសុំផ្ទេរបេតិកភណ្ឌមួយពីបញ្ជីមួយទៅកាន់បញ្ជីមួយទៀតបាន។ ដើម្បីធ្វើការផ្ទេរបេតិកភណ្ឌនោះត្រូវតែបំពេញទៅតាមលក្ខណវិនិច្ឆ័យរបស់បញ្ជី ដែលបេតិកភណ្ឌនេះស្នើសុំធ្វើការផ្ទេរទៅ និងត្រូវដាក់ស្នើឱ្យស្របទៅនឹងនីតិវិធីដែលបានបង្កើត និងពេលវេលាដែលបានកំណត់សម្រាប់ការចុះបញ្ជី។

**ការធ្វើបច្ចុប្បន្នកម្ម និងការបោះពុម្ពផ្សាយបញ្ជីតំណាង** 2.COM 6

៣១.	សំណុំឯកសារចុះបញ្ជី និងរបាយការណ៍ត្រួតពិនិត្យនៃបេតិកភណ្ឌដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីនេះត្រូវតែមាននៅលេខាធិការដ្ឋានសម្រាប់ធ្វើការពិភាក្សា និងប្រសិនបើអាចត្រូវធ្វើឱ្យមាននៅតាមប្រព័ន្ធអ៊ិនធឺណិត ដើម្បីធ្វើឱ្យមានការទទួលបានព័ត៌មានជាទូទៅ។

៣២.	ក្រោយពីទទួលបានការស្នើសុំពីគណៈកម្មាធិការ លេខាធិការដ្ឋានធ្វើការចេញផ្សាយនូវបញ្ជីតំណាងដែលបានធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ជាទូទៅគឺតាមរយៈគេហទំព័ររបស់អនុសញ្ញានេះ។

**កាលវិភាគ_សេចក្តីសង្ខេបនៃនីតិវិធី** 2.COM 6

៣៣.	**ដំណាក់កាលទី ១ ៖ ការរៀបចំ និងការដាក់ពាក្យ**

៣១សីហា_ឆ្នាំទី១[២]	ជាពេលកំណត់ ដែលការចុះបញ្ជីត្រូវដាក់ជូនទៅលេខាធិការដ្ឋាន។ ការចុះបញ្ជីដែលដាក់ជូនក្រោយកាលបរិច្ឆេទនេះ នឹងត្រូវបានពិនិត្យនៅឆ្នាំក្រោយតាមកាលបរិច្ឆេទដូចគ្នា។

០១ វិច្ឆិកា_ឆ្នាំទី២ ជាពេលកំណត់ ដែលលេខាធិការដ្ឋាននឹងបានដំណើរការលើការចុះបញ្ជីដែលរួមទាំងការចុះឈ្មោះចូលទៅក្នុងបញ្ជី និងការទទួលស្គាល់លើការតែងតាំងដែលបានដាក់ជូន។ ប្រសិនបើគេមើលឃើញថា ការចុះបញ្ជីមួយមិនមានលក្ខណៈពេញលេញ រដ្ឋភាគីនោះនឹងត្រូវបានគេណែនាំឱ្យបំពេញបន្ថែមលើការតែងតាំងនេះ។

១៥ មករា_ឆ្នាំទី២ ជាពេលកំណត់ ដែលរដ្ឋភាគីត្រូវដាក់ជូនទៅលេខាធិការដ្ឋាននូវព័ត៌មានបន្ថែមទាំងឡាយ ដែលត្រូវការសម្រាប់បំពេញបន្ថែមលើការចុះបញ្ជីនេះប្រសិនបើមាន។ ការតែងតាំងដែលមានលក្ខណៈមិនពេញលេញ អាចបំពេញបន្ថែមនៅឆ្នាំក្រោយតាមកាលបរិច្ឆេទដូចគ្នា។

**ដំណាក់កាលទី ២: ការត្រួតពិនិត្យ**

ខែ ឧសភា_ឆ្នាំទី២ ជាកាលបរិច្ឆេទដែលស្ថាប័នរងធ្វើការត្រួតពិនិត្យ

០១ កក្កដា_ឆ្នាំទី២ លេខាធិការដ្ឋានបញ្ជូនរបាយការណ៍ត្រួតពិនិត្យទៅកាន់រដ្ឋភាគីទាំងឡាយតាមរយៈស្ថាប័នរង។

០១ សីហា_ឆ្នាំទី២ លេខាធិការដ្ឋានបញ្ជូនរបាយការណ៍ត្រួតពិនិត្យ ទៅកាន់សមាជិកគណៈកម្មាធិការ។ សំណុំឯកសារចុះបញ្ជី និងរបាយការណ៍ត្រួតពិនិត្យត្រូវឱ្យមាននៅតាមប្រព័ន្ធអ៊ិនធឺណិត សម្រាប់ឱ្យរដ្ឋភាគីទាំងឡាយធ្វើការពិភាក្សា។

**ដំណាក់កាលទី ៣: ការវាយតម្លៃ**

កញ្ញា_ឆ្នាំទី២ គណៈកម្មាធិការវាយតម្លៃលើការចុះបញ្ជី និងធ្វើការ សម្រេច។

## ១.៣ ការដាក់បញ្ចូលបេតិកភណ្ឌដែលបានប្រកាសជាសាធារណៈថាជា “ស្នាដៃឯកនៃបេតិកភណ្ឌអរូបិយមនុស្សជាតិ” ទៅក្នុងបញ្ជីតំណាង

មាត្រា ៣១
2.EXT.COM 7

៣៤. ដោយអនុលោមទៅតាមមាត្រា៣១.១នៃអនុសញ្ញានេះ គណៈកម្មាធិការត្រូវដាក់បញ្ចូលដោយស្វ័យប្រវត្តិនូវបេតិកភណ្ឌទាំងអស់ដែលបានប្រកាសថាជា “ស្នាដៃឯកនៃបេតិកភណ្ឌអរូបិយ

មនុស្សជាតិ” ទៅក្នុងបញ្ជីនៅក្នុងមាត្រា ១៦ មុននឹងអនុសញ្ញានេះចូលជាធរមាន បន្ទាប់ពីមហាសន្និបាតធ្វើការអនុម័តទៅលើសេចក្តីណែនាំប្រតិបត្តិការនាពេលបច្ចុប្បន្ន។

៣៥. ការដាក់បញ្ចូលនេះអាចអនុវត្តបានទៅលើរដ្ឋទាំងអស់ដែលនៅលើទឹកដីរបស់គេ មានបេតិកភណ្ឌមួយ ឬ ច្រើនត្រូវបានប្រកាសទទួលស្គាល់ថាជាស្នាដៃឯក មិនថារដ្ឋទាំងនោះជាសមាជិក ឬ មិនមែនជាសមាជិកនៃអនុសញ្ញានេះឡើយ។ រដ្ឋមិនមែនជាសមាជិកទាំងឡាយដែលបេតិកភណ្ឌរបស់ពួកគេបានប្រកាសថាជាស្នាដៃឯក និងបានដាក់បញ្ចូលទៅក្នុងបញ្ជីនេះ អាចទទួលបានសិទ្ធិ និងកាតព្វកិច្ចទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ តែក្នុងករណីដែលបេតិកភណ្ឌទាំងនោះស្ថិតនៅក្នុងទឹកដីរបស់ពួកគេប៉ុណ្ណោះ (នៅលើលក្ខខណ្ឌដែលពួកគេបានព្រមព្រៀងជាលាយ លក្ខណ៍អក្សរ)។ គេទទួលស្គាល់ថាសិទ្ធិ និងកាតព្វកិច្ចទាំងនោះមិនអាច ប្រើប្រាស់ ឬ អនុវត្តដោយឡែកពីគ្នាបានឡើយ។

៣៦. រដ្ឋមិនមែនជាសមាជិកទាំងអស់ដែលបេតិកភណ្ឌនៅលើទឹកដីរបស់ខ្លួន ត្រូវបានប្រកាសថាជាស្នាដៃឯកត្រូវតែទទួលបានការជូនដំណឹងជាផ្លូវការ ពីអគ្គនាយកស្តីពីការអនុម័តទៅលើសេចក្តីណែនាំប្រតិបត្តិការនាពេលបច្ចុប្បន្ន ដែលតម្រូវឱ្យបេតិកភណ្ឌនេះស្ថិតនៅក្នុងមូលដ្ឋានស្មើភាពគ្នាមួយ ជាមួយនឹងបេតិកភណ្ឌផ្សេងទៀតដែលនឹងដាក់បញ្ចូលទៅក្នុងបញ្ជីនេះនៅពេលអនាគត ដោយអនុលោមទៅតាមមាត្រា ១៦.២ ។ លើសពីនេះទៀត បេតិកភណ្ឌនេះត្រូវស្ថិតក្រោមរបបគតិយុត្តសម្រាប់ការត្រួតពិនិត្យ ការផ្ទេរ ពីបញ្ជីមួយទៅកាន់បញ្ជីមួយផ្សេងទៀត ឬ ការដកចេញដោយយោងទៅតាមបែបបទនិតិវិធីដែលដឹងមុនដោយសេចក្តីណែនាំប្រតិបត្តិការនេះ។

៣៧. តាមរយៈសេចក្តីជូនដំណឹងដែលបានលើកឡើងខាងលើ អគ្គនាយកនឹងអញ្ជើញរដ្ឋដែលមិនមែនជាសមាជិកទាំងឡាយក្នុងពេលតំណាលគ្នា ទៅតាមសេចក្តីបង្គាប់របស់គណៈកម្មាធិការឱ្យបង្ហាញពីការព្រមព្រៀងយ៉ាងច្បាស់លាស់ជាលាយលក្ខណ៍អក្សររបស់ពួកគេ ក្នុងកាទទួលយកនូវសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងអនុសញ្ញានេះ ស្របទៅតាមបែបបទដែលដឹងមុននៅក្នុងកថាខ័ណ្ឌ ៣៥ និង ៣៦ ខាងលើ ក្នុងរយៈពេលមួយឆ្នាំ។

៣៨. សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីការព្រមព្រៀងទទួលយករបស់រដ្ឋមិនមែនជាសមាជិក ត្រូវដាក់ជូនទៅអគ្គនាយក ក្នុងនាមជាអ្នកថែរក្សាទុកនូវឯកសារនៃអនុសញ្ញានេះ ហើយចងក្រងសំណុំឯកសារបេតិកភណ្ឌដែលបានប្រកាសថាជាស្នាដៃឯកដែលពាក់ព័ន្ធ ឱ្យវាក្លាយទៅជាឯកសារគតិយុត្តិឆ្លើយតបពេញលេញទៅនឹងលក្ខខណ្ឌនៃអនុសញ្ញានេះ។

៣៩. ក្នុងករណីដែលរដ្ឋមិនមែនជាសមាជិករបស់អនុសញ្ញានេះ បដិសេធមិនផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរក្នុងរយៈពេលមួយឆ្នាំក្នុងការទទួលយកសិទ្ធិ និងកាតព្វកិច្ចដែលស្ថិតក្រោមអនុសញ្ញាដែលពាក់ព័ន្ធទៅនឹងបេតិកភណ្ឌដែលមាននៅក្នុងទឹកដីរបស់ខ្លួន និងដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីតំណាង គណៈកម្មាធិការមានសិទ្ធិគ្រប់គ្រាន់ក្នុងការដកបេតិកភណ្ឌទាំងនេះចេញពីបញ្ជី។

៤០. ក្នុងករណីដែលរដ្ឋមិនមែនជាសមាជិករបស់អនុសញ្ញានេះ មិនបានធ្វើការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹង ឬ មានបំណងរក្សាភាពស្ងៀមស្ងាត់មិនធ្វើការឆ្លើយតប ឬ ក្នុងករណីដែលមិនមានការបញ្ជាក់ពីការព្រមព្រៀងច្បាស់លាស់ក្នុងរយៈពេលមួយឆ្នាំ ដោយអនុលោមទៅតាមកថាខណ្ឌទី ៣៩ ខាងលើ គណៈកម្មាធិការនឹងចាត់ទុកថារដ្ឋទាំងនោះបានប្រានចោលមិនព្រមទទួលយកសិទ្ធិ និងកាតព្វកិច្ចនេះ លើកលែងតែក្នុងករណីដែលរដ្ឋទាំងនោះស្ថិតក្នុងស្ថានការណ៍មួយដែលមិនអាចគ្រប់គ្រងបាន ដែលរារាំងពួកគេពីការជូនដំណឹងស្តីពីការទទួលយក ឬ មិនទទួលយកនូវសិទ្ធិ និង កាតព្វកិច្ច នេះ។

៤១. ប្រសិនបើបេតិកភណ្ឌមួយដែលប្រកាសថាជាស្នាដៃឯក និងដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីត្រូវបានគេរកឃើញទាំងនៅក្នុងទឹកដីរបស់រដ្ឋសមាជិក និងនៅក្នុងទឹកដីរបស់រដ្ឋមិនមែនជាសមាជិកនៃអនុសញ្ញានេះ បេតិកភណ្ឌនេះត្រូវបានគេចាត់ទុកថាទទួលបានផលប្រយោជន៍ពីរបបគតិយុត្តពេញលេញដែលបានបង្កើតឡើងដោយអនុសញ្ញានេះ ហើយអគ្គនាយកត្រូវអញ្ជើញរដ្ឋដែលមិនមែនជាសមាជិក ទៅតាមសេចក្តីបង្គាប់របស់គណៈកម្មាធិការ ឱ្យធ្វើការព្រមព្រៀងទៅលើកាតព្វកិច្ចដែលដឹងដោយអនុសញ្ញានេះ។ ក្នុងករណីដែលមិនមានការបញ្ជាក់ពីការព្រមព្រៀងច្បាស់លាស់ពីរដ្ឋមិនមែនជាសមាជិកទេនោះ គណៈកម្មាធិការមាន

សិទ្ធិផ្ដល់ជាយោបល់មិនឱ្យមានការចាត់វិធានការណាមួយ ដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់ស្នាដៃឯកដែលបានប្រកាសនោះឡើយ។

៤២. គណៈកម្មាធិការត្រូវធ្វើការរាយការណ៍ទៅកាន់មហាសន្និបាត ស្ដីពីវិធានការដែលបានចាត់ឡើងស្របទៅតាមបែបបទ និងទម្រង់ការដែលដឹងមុន ដោយសេចក្ដីណែនាំបច្ចុប្បន្ន។

## ១.៤ កម្មវិធី គម្រោង និងសកម្មភាពដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីគោលការណ៍ និងគោលបំណង នៃអនុសញ្ញានេះ — មាត្រា ១៨

### *សំណើ និងនីតិវិធីក្នុងការជ្រើសរើស* — 2.COM 12

៤៣. រដ្ឋភាគីត្រូវបានគេលើកទឹកចិត្តឱ្យដាក់សំណើនូវកម្មវិធី គម្រោង និង សកម្មភាពជាតិ អនុតំបន់ ឬ តំបន់ស្ដីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយទៅកាន់គណៈកម្មាធិការ ដើម្បីធ្វើការជ្រើសរើស និងផ្សព្វផ្សាយ ដោយសារតែវាឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់នូវគោលការណ៍ និងគោលបំណងនៃអនុសញ្ញានេះ។ — មាត្រា ១៨.១

៤៤. នៅក្នុងការជ្រើសរើស និងលើកកម្ពស់កម្មវិធី គម្រោង និងសកម្មភាពអភិរក្ស គណៈកម្មាធិការត្រូវយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការនៃប្រទេសកំពុងអភិវឌ្ឍ និងទៅលើគោលការណ៍បែងចែកស្មើគ្នាទៅតាមភូមិសាស្ត្រ នៅខណៈដែលធ្វើការពង្រឹងសហប្រតិបត្តិការ ខាងត្បូង_ខាងត្បូង និង ខាងជើង_ខាងត្បូង_ខាងត្បូង ។

៤៥. កម្មវិធី គម្រោង និងសកម្មភាពទាំងនេះអាចនឹងត្រូវបានគេបង្កើតរួចរាល់ហើយ ឬ កំពុងដំណើរការបង្កើត ឬ ត្រូវបានគេធ្វើផែនការនៅពេលដែលដាក់ស្នើទៅគណៈកម្មាធិការ ដើម្បីធ្វើការជ្រើសរើស និងផ្សព្វផ្សាយ។

៤៦. រដ្ឋភាគីអាចដាក់សំណើដាច់ដោយឡែក ឬ រួមគ្នាទៅកាន់គណៈកម្មាធិការ។ គណៈកម្មាធិការលើកទឹកចិត្តឱ្យរដ្ឋសមាជិកដាក់ស្នើនូវកម្មវិធី គម្រោង និង សកម្មភាពតំបន់ ឬ អនុតំបន់ព្រមទាំងឱ្យការដាក់សំណើនេះធ្វើឡើងរួមគ្នាដោយរដ្ឋភាគីទាំងឡាយនៅតាមតំបន់ដែលមានទីតាំងភូមិសាស្ត្រដាច់ពីគ្នា។

៤៧. រដ្ឋសមាជិក អាចស្នើសុំជំនួយការរៀបចំដើម្បីធ្វើការដាក់សំណើឱ្យស្របទៅតាមបញ្ញត្តិ ស្តីពីជំនួយការអន្តរជាតិ គឺមាត្រា ២០_២៤ នៃអនុសញ្ញានេះ។ មាត្រា ១៨.៣

៤៨. រដ្ឋភាគីដែលដាក់ពាក្យសុំត្រូវប្រើទម្រង់ដែលភ្ជាប់មកជាមួយនឹងសេចក្តីណែនាំនេះ ហើយត្រូវដាក់ជូននូវសំណើរបស់ខ្លួនទៅវៀងរាល់ខែមិនា នៃឆ្នាំនីមួយៗ ដែលនៅខែនេះគណៈកម្មាធិការនឹងត្រូវបានគេស្នើសុំឱ្យធ្វើ ការវាយតម្លៃលើសំណើនេះ។

៤៩. ការពិនិត្យលើសំណើនេះជាលើកដំបូង នឹងត្រូវធ្វើឡើងដោយក្រុមការងាររបស់គណៈកម្មាធិការដែលបានបង្កើតឡើងដោយគណៈកម្មាធិការនេះនៅក្នុងសម័យប្រជុំមួយ។ ក្រុមការងារនេះត្រូវផ្តល់ឱ្យគណៈកម្មាធិការនូវមតិយោបល់របស់ខ្លួន ទៅលើគុណសម្បត្តិនៃសំណើនេះ និងអនុសាសន៍សង្ខេបមួយ។

៥០. គណៈកម្មាធិការធ្វើការសម្រេចថា តើត្រូវជ្រើសរើស ឬ មិនត្រូវជ្រើសរើស កម្មវិធីគម្រោង ឬ សកម្មភាពមួយ។

៥១. នៅក្នុងសម័យប្រជុំនីមួយៗ គណៈកម្មាធិការអាចនឹងធ្វើការអំពាវនាវដោយបើកចំហឱ្យមានការកំណត់លក្ខណៈទៅលើសំណើដោយសហប្រតិបត្តិការអន្តរជាតិដូចដែលមានចែងនៅក្នុងមាត្រា ១៩ និង/ឬ ដោយផ្តោតទៅលើទិដ្ឋភាពជាអាទិភាពជាក់លាក់ណាមួយនៃការអភិរក្ស។

## លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស 2.COM 12

៥២. ក្នុងចំណោមកម្មវិធី គម្រោង ឬ សកម្មភាពដែលបានស្នើ គណៈកម្មាធិការត្រូវជ្រើសរើសសំណើណាដែលបំពេញបានល្អបំផុតទៅតាមលក្ខណវិនិច្ឆ័យដូចខាងក្រោម:

ក. ជាកម្មវិធី គម្រោង និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងការអភិរក្ស ដូចដែលមានចែងនៅក្នុងមាត្រា ២.៣ នៃអនុសញ្ញានេះ។

ខ. កម្មវិធី គម្រោង និងសកម្មភាពនេះជួយលើកកម្ពស់ដល់ការសម្របសម្រួលនៃកិច្ចខិតខំប្រឹងប្រែងធ្វើការអភិរក្សបេតិកភណ្ឌវប្បធម៌ អរូបិយនៅថ្នាក់តំបន់ អនុតំបន់ និង/ឬ អន្តរជាតិ។

គ. កម្មវិធី គម្រោង និងសកម្មភាពនេះឆ្លុះបញ្ចាំងពីគោលការណ៍ និង គោលបំណងនៃអនុសញ្ញានេះ។

ឃ. ប្រសិនបើកម្មវិធី គម្រោង និងសកម្មភាពទាំងនេះត្រូវបានធ្វើឡើង ហើយវានឹងបានបង្ហាញនូវប្រសិទ្ធភាព ក្នុងការរួមចំណែកដល់ភាពដែលអាចសម្រេចទៅបាននៃបេតិកភណ្ឌវប្បធម៌អរូបិយដែលពាក់ព័ន្ធ។ ប្រសិនបើ កម្មវិធី គម្រោង និងសកម្មភាពនេះកំពុងតែដំណើរការ ឬ ធ្វើផែនការ គេអាចរំពឹងទុកយ៉ាងសមហេតុផលថាវានឹងរួមចំណែកជានិរន្តដល់ភាព ដែលអាចសម្រេចទៅបាននៃបេតិកភណ្ឌវប្បធម៌អរូបិយដែលពាក់ព័ន្ធ។

ង. ជាកម្មវិធី គម្រោង ឬ សកម្មភាពដែលបានអនុវត្ត ឬ ដែលនឹងត្រូវអនុវត្តដោយមានការចូលរួមពីសហគមន៍ ក្រុម ឬ បុគ្គលនានាដែលពាក់ព័ន្ធ និងដោយមានការព្រមព្រៀងជាមុនដោយសេរី និងដោយបានជូនដំណឹងពីអ្នកចូលរួមទាំងនេះ។

ច. ប្រសិនបើអាច កម្មវិធី គម្រោង ឬ សកម្មភាពនេះអាចធ្វើជាគំរូថ្នាក់ អនុតំបន់ ឬ តំបន់ និងថ្នាក់អន្តរជាតិសម្រាប់សកម្មភាពអភិរក្សនានា។

ឆ. រដ្ឋភាគីដែលបានដាក់ពាក្យសុំ ស្ថាប័នអនុវត្ត និង សហគមន៍ ក្រុម ឬ បុគ្គលនានាដែលពាក់ព័ន្ធមានឆន្ទៈធ្វើសហប្រតិបត្តិការ ក្នុងការផ្សព្វផ្សាយនូវគោលការណ៍ដែលល្អបំផុត ប្រសិនបើកម្មវិធី គម្រោង ឬ សកម្មភាពរបស់ពួកគេត្រូវបានជ្រើសរើស។

ជ. កម្មវិធី គម្រោង ឬ សកម្មភាពនេះបង្ហាញនូវបទពិសោធន៍ដែលងាយវង់នូវឥទ្ធិពលនៃការវាយតម្លៃនៃលទ្ធផលរបស់ពួកគេ។

ឈ. កម្មវិធី គម្រោង ឬ សកម្មភាពនេះអាចប្រើប្រាស់បានជាគោលទៅលើតម្រូវការជាក់លាក់ទាំងឡាយនៃប្រទេសកំពុងអភិវឌ្ឍ។

## ការលើកកម្ពស់ និង ការផ្សព្វផ្សាយ 2.COM 12

៥៣. គណៈកម្មាធិការត្រូវលើកទឹកចិត្តដល់ការស្រាវជ្រាវ ការរៀបចំឯកសារ ការបោះពុម្ពផ្សាយ និង ការផ្សព្វផ្សាយនៃគំរូ និង ការប្រតិបត្តិល្អ ជាមួយកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការបង្កើតវិធានការអភិរក្ស និងការបង្កើតល័ក្ខខ័ណ្ឌអំណោយផលសម្រាប់វិធានការទាំងនោះដែលត្រូវបានរដ្ឋភាគីធ្វើឱ្យមានការវិវត្តនៅក្នុងការអនុវត្តកម្មវិធី គម្រោង និង សកម្មភាពដែលបានជ្រើសរើស ដោយមាន ឬ គ្មានជំនួយ។

៥៤. គណៈកម្មាធិការត្រូវបង្កើត ធ្វើបច្ចុប្បន្នភាពកម្ម និង បោះពុម្ពផ្សាយនូវបញ្ជី ឈ្មោះកម្ម វិធី គម្រោង និងសកម្មភាពដែលខ្លួនបានសម្រិតសម្រាំងឡើង ដើម្បីឆ្លុះបញ្ចាំងពីគោលការណ៍ និងកម្មវត្ថុរបស់អនុសញ្ញា។

៥៥. គណៈកម្មាធិការត្រូវលើកទឹកចិត្តដល់រដ្ឋភាគី ដើម្បីបង្កើតល័ក្ខខ័ណ្ឌអំណោយផលសម្រាប់ការអនុវត្តកម្មវិធី គម្រោង និង សកម្មភាពទាំងនោះ។

៥៦. បន្ថែមទៅលើបញ្ជីឈ្មោះកម្មវិធី គម្រោង និងសកម្មភាពដែលបានសម្រិតសម្រាំង គណៈកម្មាធិការត្រូវចងក្រង និងធ្វើឱ្យព័ត៌មានអាចរកបានអំពី វិធានការ និងវិធីសាស្ត្រទាំងឡាយដែលបានប្រើប្រាស់ ឬ ដើម្បីប្រើប្រាស់ រួមជាមួយបទពិសោធន៍ដែលទទួលបាននានាប្រសិនបើមាន។

៥៧. គណៈកម្មាធិការត្រូវលើកទឹកចិត្តដល់ការស្រាវជ្រាវ និងការវាយតម្លៃទៅលើប្រសិទ្ធភាពនៃវិធានការអភិរក្សដែលបានដាក់បញ្ចូលទៅក្នុងកម្មវិធី គម្រោង និង សកម្មភាពដែលខ្លួនបានសម្រិតសម្រាំង និងត្រូវលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងការស្រាវជ្រាវ និង ការវាយតម្លៃនោះ។

៥៨. ដោយផ្អែកលើមូលដ្ឋាននៃបទពិសោធន៍ និង មេរៀនដែលទទួលបានពីកម្មវិធី គម្រោង និងសកម្មភាពអភិរក្សនានា គណៈកម្មាធិការត្រូវផ្តល់ការណែនាំទៅលើការប្រតិបត្តិល្អបំផុត និង ផ្តល់អនុសាសន៍ទៅលើវិធានការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ (មាត្រា ៧ (ខ))។

## ជំពូកទី II: ជំនួយអន្តរជាតិ និង មូលនិធិបេតិកភណ្ឌវប្បធម៌អរូបិយ

### ២.១ គោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់ធនធាននៃមូលនិធិ

មាត្រា ៧ (C), (D), ២៥ - ២៧ និង ២៨

1.EXT.COM 9
2.COM 9

៥៩. ធនធាននៃមូលនិធិ ដែលត្រូវបានរៀបចំជាគណនីពិសេសដោយអនុលោមទៅតាមមាត្រា ១.១ នៃបទបញ្ញត្តិហិរញ្ញវត្ថុ ត្រូវបានប្រើប្រាស់ជាសំខាន់សម្រាប់ផ្តល់ជាជំនួយអន្តរជាតិដូចដែលមានចែងនៅក្នុងជំពូកទី៥នៃអនុសញ្ញា។

៦០. ធនធានអាចត្រូវបានប្រើប្រាស់បន្ថែមទៀតសម្រាប់:

ក. ជាការបំពេញបន្ថែមទៅលើមូលនិធិបម្រុងដែលបានកំណត់នៅក្នុង មាត្រា ៦នៃបទបញ្ញត្តិហិរញ្ញវត្ថុ។

ខ. ឧបត្ថម្ភដំណើរការជ្រើសរើសទៀតរបស់គណៈកម្មាធិការដូចដែលមានចែងក្នុងមាត្រា៧ រួមទាំងដំណើរការទាក់ទងទៅនឹងសំណើដែលមានចែង ក្នុងមាត្រា១៨។

គ. ថ្លៃចំណាយទៅលើការចូលរួមនៅក្នុងអង្គប្រជុំរបស់គណៈកម្មាធិការ របស់អ្នកតំណាងនៃរដ្ឋសមាជិកមកពីប្រទេសកំពុងអភិវឌ្ឍ របស់គណៈកម្មាធិការប៉ុន្តែការផ្តល់បែបនេះសម្រាប់តែអ្នកដែលមានជំនាញខាងបេតិកភណ្ឌវប្បធម៌អរូបិយប៉ុណ្ណោះ។ ប្រសិនបើមានថវិកាគ្រប់គ្រាន់ ដោយផ្អែកលើមូលដ្ឋានដោយឈរលើករណីមួយទៅករណីមួយទៀត ធនធានអាចត្រូវបានប្រើប្រាស់ សម្រាប់ថ្លៃចំណាយទៅលើការចូលរួមរបស់អ្នកតំណាងដែលជាអ្នកជំនាញខាងបេតិកភណ្ឌវប្បធម៌អរូបិយ មកពីប្រទេសកំពុងអភិវឌ្ឍ ដែលជាភាគីនៃអនុសញ្ញាតែមិនមែនជា សមាជិករបស់គណៈកម្មាធិការ ។

ឃ. ថ្លៃចំណាយទៅលើសេវាប្រឹក្សាតាមសំណើរបស់គណៈកម្មាធិការ ដែលត្រូវផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល និង អង្គការមិនស្វែងរកប្រាក់ចំណេញ ស្ថាប័នសាធារណៈ ឬ ឯកជន និងបុគ្គលឯកជន។

ង. ថ្លៃចំណាយទៅលើការចូលរួមពីសំណាក់ស្ថាប័នសាធារណៈ ឬ ឯកជន ព្រមទាំងបុគ្គលឯកជន ជាពិសេសសមាជិកក្រុម ឬ សហគមន៍នានា ដែលត្រូវបានគណៈកម្មាធិការអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំ ដើម្បី ពិភាក្សាលើបញ្ហាជាក់លាក់មួយចំនួន។

## ២.២ ជំនួយអន្តរជាតិ

### គោលបំណង និង ទម្រង់នៃជំនួយអន្តរជាតិ

មាត្រា ២០ -២១
២៤.២-១៨
2.COM 11

៦១. ជំនួយអន្តរជាតិត្រូវបានផ្តល់ទៅឱ្យរដ្ឋភាគី សម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ គឺជាការបន្ថែមទៅលើកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ សម្រាប់ការអភិរក្សនេះ។

៦២. គណៈកម្មាធិការអាចទទួលវាយតម្លៃ និងយល់ព្រមលើសំណើសុំសម្រាប់គោលបំណង និង ទម្រង់ណាមួយនៃជំនួយអន្តរជាតិដែលមានចែងក្នុងមាត្រា ២០ និង ២១ នៃអនុសញ្ញា ដោយ អាស្រ័យទៅលើធនធានដែលមាន។ អាទិភាពត្រូវផ្តល់ទៅលើសំណើជំនួយអន្តរជាតិដែល ពាក់ព័ន្ធទៅនឹង:

ក. ការអភិរក្សបេតិកភណ្ឌដែលបានបញ្ចូលទៅក្នុងបញ្ជីការអភិរក្សបន្ទាន់។ មាត្រា ២០ (a)

ខ. ការរៀបចំបញ្ជីសារពើភ័ណ្ឌទៅតាមខ្លឹមសារមាត្រា១១ និង ១២។ មាត្រា ២០ (b)

គ. ឧបត្ថម្ភសម្រាប់កម្មវិធី គម្រោង និង សកម្មភាពដែលបានអនុវត្តនៅថ្នាក់ ជាតិ អនុតំបន់ និង តំបន់ក្នុងគោលបំណងអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ។ មាត្រា ២០ (c)

ឃ. ជំនួយក្នុងការរៀបចំ

៦៣. ជំនួយអន្តរជាតិដែលមានចែងក្នុងមាត្រា២០ និង ២១ អាចផ្តល់សម្រាប់ស្ថានភាពបន្ទាន់ ដូចមាន ចែងក្នុងមាត្រា២២ (ជំនួយសង្គ្រោះបន្ទាន់)។

៦៤. គណៈកម្មាធិការអាចទទួលវាយតម្លៃ និងយល់ព្រមទៅលើសំណើសុំជំនួយក្នុងការត្រៀម រៀបចំក្នុងគោលដៅជួយបកស្រាយបំភ្លឺសំណើ សម្រាប់ការសុំបញ្ចូលទៅក្នុងបញ្ជីអភិរក្សបន្ទាន់ ដោយស្របទៅតាមមាត្រា១៧ និង សំណើទាំងឡាយដែលស្របទៅនឹងមាត្រា១៨ (ជំនួយ ក្នុងការរៀបចំ)។

## លក្ខណគ្រប់គ្រាន់ និង លក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើស

៦៥. រដ្ឋភាគីទាំងអស់មានសិទ្ធិធ្វើសំណើសុំជំនួយអន្តរជាតិ។

៦៦. នៅពេលធ្វើការវាយតម្លៃទៅលើសំណើសុំជំនួយអន្តរជាតិ គណៈកម្មាធិការត្រូវធ្វើការពិចារ ណាទៅលើគោលការណ៍សមធម៌ និងភូមិសាស្ត្រនៃការបែងចែក និងតម្រូវការពិសេសរបស់ ប្រទេសកំពុងអភិវឌ្ឍ។ គណៈកម្មាធិការ ក៏ត្រូវធ្វើការពិចារណាផងដែរថាតើ៖

ក. សំណើអនុវត្តទៅលើកិច្ចសហប្រតិបត្តិការកម្រិតទ្វេភាគី តំបន់ ឬ អន្តរជាតិ និង/ឬ

ខ. ជំនួយអាចមានឥទ្ធិពលកើនឡើង និង អាចជំរុញលើកទឹកចិត្តឱ្យមានវិភាគទានហិរញ្ញវត្ថុ និងបច្ចេកទេសពីប្រភពផ្សេងៗទៀត។

៦៧. គណៈកម្មាធិការនឹងធ្វើការសម្រេចផ្តល់ជំនួយ ដោយផ្អែកលើលក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖ មាត្រា២៤.២

ក. សហគមន៍ ក្រុម និង/ឬ បុគ្គលទាំឡាយដែលពាក់ព័ន្ធចូលរួមក្នុងការរៀបចំសំណើ ហើយនឹងត្រូវពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពដែលត្រូវបានស្នើសុំ និង ការវាយតម្លៃ និងតាមដានដោយទូលំទូលាយតាមដែលអាច ធ្វើទៅបាន

ខ. ចំនួនទឹកប្រាក់ជំនួយដែលស្នើសុំត្រូវសមរម្យ

គ. សកម្មភាពដែលបានស្នើត្រូវតែមានភាពច្បាស់លាស់ និងអាចធ្វើបាន។

ឃ. គម្រោងអាចនឹងមានលទ្ធផលយូរអង្វែង។

ង. រដ្ឋភាគីដែលជាអត្ថគាហក រួមចំណែកទៅលើថ្លៃចំណាយសម្រាប់សកម្មភាពដែលជំនួយអន្តរជាតិបានផ្តល់ឱ្យទៅតាមកំរិតធនធានដែលខ្លួនមាន។

ច. ជំនួយនេះមានគោលដៅបង្កើន និងពង្រឹងសមត្ថភាព ក្នុងវិស័យអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ

ឆ. ប្រសិនបើមានរដ្ឋភាគីដែលជាអត្ថគាហក បានអនុវត្តសកម្មភាពហិរញ្ញវត្ថុកន្លងមក ដោយស្របទៅតាមបទបញ្ញត្តិ និងលក្ខខណ្ឌទាំងអស់ដែលត្រូវអនុវត្តតាម។

**នីតិវិធីសម្រាប់ការដាក់សំណើសុំជំនួយអន្តរជាតិ**

៦៨. រដ្ឋភាគីអាចដាក់សំណើសុំជំនួយអន្តរជាតិទៅគណៈកម្មាធិការ ដើម្បីស្នើសុំជំនួយអន្តរជាតិ។ សំណើទាំងនោះអាចដាក់រួមគ្នាដោយរដ្ឋ ភាគីពីរ ឬច្រើន។

៦៩. សំណើសុំជំនួយអន្តរជាតិត្រូវតែដាក់ជូនលេខាធិការដ្ឋាន ដោយប្រើប្រាស់ទម្រង់សមស្របដែលមានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសេចក្តីណែនាំប្រតិបត្តិ ការទាំងនេះ។

៧០. សំណើសុំជំនួយក្នុងការរៀបចំបែបបទ នឹងត្រូវបានទទួលដោយលេខាធិការដ្ឋាននៅមុនថ្ងៃ ទី ១ ខែកញ្ញា ក្នុងរយៈពេលពីរឆ្នាំ មុននឹងគណៈកម្មាធិការធ្វើការវាយតម្លៃទៅលើសំណើសុំបញ្ចូលទៅក្នុងបញ្ជីការអភិរក្សបន្ទាន់ដូចមានចែងនៅក្នុងមាត្រា១៧នៃអនុសញ្ញា ឬ នៅមុនថ្ងៃទី១ ខែ កញ្ញា ក្នុងរយៈពេលមួយឆ្នាំ មុននឹងគណៈកម្មាធិការធ្វើការវាយតម្លៃទៅលើសំណើកម្មវិធី គម្រោង និងសកម្មភាពផ្សេងៗដូចមានចែងក្នុងមាត្រា១៨។

៧១. លេខាធិការដ្ឋានត្រូវធ្វើការវាយតម្លៃទៅលើភាពពេញលេញនៃសំណើ និង អាចសុំព័ត៌មានបន្ថែមទៀតបាន។ លេខាធិការដ្ឋានត្រូវជូនដំណឹងទៅរដ្ឋភាគីដែលស្នើសុំអំពីកាលបរិច្ឆេទធ្វើការវាយតម្លៃទៅលើសំណើ ដែលអាច ធ្វើទៅបាន។

៣២. លេខាធិការដ្ឋានត្រូវធ្វើការត្រួតពិនិត្យសម្រាប់សំណើពេញលេញណាដែលមានទំហំទឹកប្រាក់ប្រមាណចាប់ពីជាង ២៥ ០០០ដុល្លារសហរដ្ឋ អាមេរិកឡើងទៅ។

៣៣. លេខាធិការដ្ឋាន ត្រូវដាក់សំណើពេញលេញទៅអាជ្ញាធរដែលពាក់ព័ន្ធ ដើម្បីធ្វើការវាយតម្លៃ និង អនុម័ត:

*(នៅក្នុងតារាងខាងក្រោម ពាក្យ "ជំនួយផ្សេងទៀត" សំដៅទៅលើជំនួយទាំងអស់ដែលក្រៅពីជំនួយសង្គ្រោះបន្ទាន់ និងជំនួយក្នុងការរៀបចំបែបបទ)*

| ថវិកា | ប្រភេទជំនួយ | ថ្ងៃផុតកំណត់ ដាក់សំណើ | ស្ថាប័នទទួល សិទ្ធិអនុម័ត |
|---|---|---|---|
| តិចជាង ២៥.០០០ ដុល្លារ អាមេរិក | ជំនួយសង្គ្រោះបន្ទាន់ | គ្រប់ពេលវេលា | ការិយាល័យ របស់គណៈ កម្មាធិការ |
| | ជំនួយក្នុងការរៀបចំបែបបទ | ថ្ងៃទី ១ ខែ កញ្ញា | |
| | ជំនួយផ្សេងទៀត | គ្រប់ពេលវេលា | |
| ២៥.០០០ដុល្លារ អាមេរិក ឬ ច្រើនជាង | ជំនួយសង្គ្រោះបន្ទាន់ | គ្រប់ពេលវេលា | គណៈកម្មាធិការ |
| | ជំនួយផ្សេងទៀត | ថ្ងៃទី១ខែឧសភា | |

៣៤. លេខាធិការដ្ឋានត្រូវជូនដំណឹងអំពីសេចក្តីសម្រេចទាក់ទងទៅនឹងការផ្តល់ជំនួយទៅរដ្ឋភាគីដែលស្នើសុំក្នុងអំឡុងពេលពីរសប្តាហ៍បន្ទាប់ពីការធ្វើសេចក្តីសម្រេច។ លេខាធិការដ្ឋានត្រូវមានការព្រមព្រៀងគ្នាជាមួយភាគីដែលស្នើសុំអំពីព័ត៌មានលំអិតនៃជំនួយ។

៣៥. ជំនួយនេះជាកម្មវត្ថុនៃការអង្កេតការធ្វើរបាយការណ៍ និង ការវាយតម្លៃ។

## ជំពូកទី III: ការចូលរួមនៅក្នុងការអនុវត្តអនុសញ្ញា

### ៣.១ ការចូលរួមរបស់សហគមន៍ ក្រុម និង បើសិនជាអាចចំពោះក្រុមផ្សេងទៀតដូចជាបុគ្គល អ្នកជំនាញ មជ្ឈមណ្ឌលឯកទេស និងវិទ្យាស្ថាន ស្រាវជ្រាវ 2.EXT.COM 6

៧៦. យោងទៅលើមាត្រា១១(ខ) និងខ្លឹមសារនៃមាត្រា១៥ គណៈកម្មាធិការលើកទឹកចិត្តរដ្ឋភាគីទាំងឡាយឱ្យបង្កើតសហប្រតិបត្តិការមុខងារ និង សហប្រតិបត្តិការបន្ថែមក្នុងចំណោមសហគមន៍ ក្រុម និង ក្រុមផ្សេងទៀត ដូចជាបុគ្គលដែលជាអ្នកបង្កើត រក្សាទុក និងផ្ទេរបេតិកភណ្ឌវប្បធម៌អរូបិយ ព្រមទាំងអ្នកជំនាញ មជ្ឈមណ្ឌលជំនាញ និង វិទ្យាស្ថានស្រាវជ្រាវផងដែរ។

៧៧. រដ្ឋភាគីទាំងឡាយត្រូវបានលើកទឹកចិត្តឱ្យបង្កើតស្ថាប័នប្រឹក្សាយោបល់ ឬ ក៏យន្តការសហប្រតិបត្តិការ ដើម្បីសម្រួលដល់ការចូលរួមរបស់សហគមន៍ ក្រុម និងក្រុមផ្សេងទៀតដូចជាបុគ្គល ព្រមទាំងអ្នកជំនាញ មជ្ឈមណ្ឌល ជំនាញ និងវិទ្យាស្ថានស្រាវជ្រាវ ជាពិសេស នៅក្នុង៖

- អត្តសញ្ញាណ និងនិយមន័យនៃធាតុខុសៗគ្នានៃបេតិកភណ្ឌវប្បធម៌អរូបិយ ដែលមានវត្តមាននៅលើទឹកដីនៃរដ្ឋសមាជិក។
- ធ្វើព្រាងបញ្ជីសារពើភ័ណ្ឌ
- ការពន្យល់លំអិត និងការអនុវត្តកម្មវិធី គម្រោង និងសកម្មភាពនានា។
- ការរៀបចំសំណុំឯកសារចុះបញ្ជីសម្រាប់ដាក់បញ្ចូលទៅក្នុងបញ្ជី ដោយអនុលោមទៅតាមកថាខណ្ឌដែលពាក់ព័ន្ធនៃជំពូកទី១ នៃសេចក្តីណែនាំប្រតិបត្តិការនេះ។
- ការលុបសមាសធាតុមួយនៃបេតិកភណ្ឌវប្បធម៌អរូបិយចេញពីបញ្ជីមួយ ឬ ការផ្ទេរទៅក្នុងបញ្ជីផ្សេងទៀត ដោយយោងទៅលើកថាខណ្ឌទី ១៣, ១៤, ២៩, និង ៣០ នៃសេចក្តីណែនាំប្រតិបត្តិការនេះ។

៧៨. រដ្ឋភាគីត្រូវចាត់វិធានការចាំបាច់ដើម្បីធ្វើឱ្យសហគមន៍ ក្រុម និង ក្រុមផ្សេងទៀតដូចជាបុគ្គលឱ្យបានយល់ដឹងពីសារៈសំខាន់ និងគុណតម្លៃនៃបេតិកភណ្ឌវប្បធម៌អរូបិយ ព្រមទាំង

សន្ធិសញ្ញា ដើម្បីឱ្យម្ចាស់បេតិកភណ្ឌនេះអាចទទួលបានពេញលេញពីលិខិតុបករណ៍ ស្រប តាមលក្ខណៈបទដ្ឋាន ដែលបានកំណត់នេះ។

៧៩. ដោយអនុលោមទៅតាមបទបញ្ញត្តិនៃមាត្រា១១ ដល់១៥ នៃអនុសញ្ញា រដ្ឋភាគីត្រូវចាត់វិធាន ការសមស្របដើម្បីធានាការកសាងសមត្ថភាព សហគមន៍ ក្រុម និង ក្រុមផ្សេងទៀតដូចជា បុគ្គល បើសិនជាអាច។

៨០. រដ្ឋភាគីត្រូវបានលើកទឹកចិត្តឱ្យបង្កើត និង ធ្វើបច្ចុប្បន្នកម្មជាអចិន្ត្រៃយ៍ទៅតាមស្ថានភាព ផ្ទាល់របស់ពួកគេ សេចក្តីណែនាំរបស់អ្នកជំនាញ មជ្ឈមណ្ឌលជំនាញ វិទ្យាស្ថានស្រាវជ្រាវ និងមជ្ឈមណ្ឌលក្នុងតំបន់ដែលសកម្មនៅក្នុងវិស័យដែលគ្របដណ្តប់ដោយអនុសញ្ញា ដែលអាច ធ្វើការសិក្សាដូចបានលើកឡើងក្នុងមាត្រា១៣(គ)។

៨១. ក្នុងចំណោមស្ថាប័នសាធារណៈ និង ឯកជនដែលបានលើកឡើងក្នុងកថាខណ្ឌ៥នៃសេចក្តី ណែនាំប្រតិបត្តិការនេះ គណៈកម្មាធិការអាចធ្វើឱ្យអ្នកជំនាញ មជ្ឈមណ្ឌលជំនាញ វិទ្យាស្ថាន ស្រាវជ្រាវ ព្រមទាំងមជ្ឈមណ្ឌលក្នុងតំបន់ សកម្មក្នុងវិស័យដែលគ្របដណ្តប់ដោយអនុសញ្ញា ដើម្បីពិគ្រោះយោបល់ជាមួយអ្នកទាំងនោះទៅលើបញ្ហាជាក់លាក់មួយចំនួន។

៨២. រដ្ឋភាគីត្រូវខិតខំប្រឹងប្រែងជួយសម្រួលដល់សហគមន៍ ក្រុម និង បុគ្គល ឱ្យទទួលបានលទ្ធផល នៃការស្រាវជ្រាវដែលធ្វើឡើងក្នុងចំណោមពួកគេ ព្រមទាំងធ្វើឱ្យមានការគោរពចំពោះការ អនុវត្តដែលគ្រប់គ្រងទៅលើការទទួលបានព័ត៌មានក្នុងផ្នែកជាក់លាក់មួយចំនួននៃបេតិកភណ្ឌ វប្បធម៌អរូបិយ ដោយអនុលោមតាមមាត្រា ១៣ (ឃ)។

៨៣. រដ្ឋសមាជិកត្រូវបានលើកទឹកចិត្តឱ្យអភិវឌ្ឍរួមគ្នានៅថ្នាក់តំបន់ និង អនុតំបន់ បណ្តាញ សហគមន៍ អ្នកជំនាញ មជ្ឈមណ្ឌលជំនាញ វិទ្យាស្ថានស្រាវជ្រាវ ដើម្បីអភិវឌ្ឍវិធីសាស្ត្ររួម ជាពិសេសទាក់ទងទៅនឹងសមាសធាតុនៃបេតិកភ័ណ្ឌវប្បធម៌អរូបិយ ដែលមានលក្ខណៈរួម ព្រមទាំងវិធីសាស្ត្រអន្តរវិស័យ។

៨៤. រដ្ឋភាគី ដែលមានការរៀបចំឯកសារ ពាក់ព័ន្ធទៅនឹងសមាសធាតុនៃបេតិកភណ្ឌវប្បធម៌ អរូបិយ ដែលមានវត្តមាននៅលើទឹកដីរបស់រដ្ឋភាគីផ្សេងទៀត ត្រូវបានលើកទឹកចិត្តឱ្យចែក រំលែកអំពីការរៀបចំឯកសារនោះជាមួយរដ្ឋផ្សេងទៀត ដែលនឹងធ្វើឱ្យព័ត៌មានអាចទៅដល់

សហគមន៍ ក្រុម និង ក្រុមផ្សេងទៀត ដូចជា បុគ្គលដែលពាក់ព័ន្ធ ព្រមទាំងអ្នកជំនាញ មជ្ឈមណ្ឌលជំនាញ និងវិទ្យាស្ថានស្រាវជ្រាវជាដើម។

៨៥. រដ្ឋភាគីត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងសកម្មភាពទាក់ទងនឹងសហប្រតិបត្តិការ ដោយរាប់បញ្ចូលទាំងសកម្មភាពនៅក្នុងផ្នែកទី២ មជ្ឈមណ្ឌលសម្រាប់បេតិកភណ្ឌវប្បធម៌អរូបិយ ដែលត្រូវបានបង្កើត ឬ នឹងត្រូវបង្កើត ឡើងដោយមានការឧបត្ថម្ភពីអង្គការ យូណេស្កូ និងត្រូវបានលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការប្រកបដោយសមត្ថភាពខ្ពស់បំផុត ទៅតាមខ្លឹមសារនៃមាត្រា១៩នៃអនុសញ្ញា ដោយរួមជាមួយការចូលរួមរបស់សហគមន៍ ក្រុម និងផ្នែកផ្សេងទៀតដូចជា បុគ្គល អ្នកជំនាញ មជ្ឈមណ្ឌល ជំនាញ និងវិទ្យាស្ថានស្រាវជ្រាវ។

៨៦. ដោយសារតែប្រភពធនធានមានកំរិត គណៈកម្មាធិការអាចអញ្ជើញ ស្ថាប័នឯកជន ឬសាធារណៈណាមួយ (រួមមានមជ្ឈមណ្ឌលជំនាញ និង វិទ្យាស្ថានស្រាវជ្រាវ) ព្រមទាំងបុគ្គលឯកជន ដែលត្រូវបានទទួល ស្គាល់ថា មានសមត្ថភាព នៅក្នុងវិស័យបេតិកភណ្ឌវប្បធម៌អរូបិយ (រួមមាន សហគមន៍ ក្រុម និង អ្នកជំនាញផ្សេងៗ) ឱ្យចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការនេះ ដើម្បីធ្វើឱ្យមានទិន្នភាពនូវអន្តរពិភាក្សា និងដើម្បីពិគ្រោះយោបល់ជាមួយអ្នកទាំងនោះដោយអនុលោមទៅតាមមាត្រា ៨.៤នៃអនុសញ្ញា។

## ៣.៣ អង្គការក្រៅរដ្ឋាភិបាលនានា និង អនុសញ្ញា

### ៣.២.១ ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលនានានៅថ្នាក់ជាតិ

៨៧. ដោយអនុលោមតាមមាត្រា១១(១) រដ្ឋភាគីត្រូវធ្វើយ៉ាងណាឱ្យអង្គការក្រៅរដ្ឋាភិបាលនានាដែលពាក់ព័ន្ធមានការជាប់ទាក់ទងទៅនឹងការអនុវត្តអនុសញ្ញា ហើយក៏ត្រូវធ្វើយ៉ាងណាជួយបង្កលក្ខណៈឱ្យអង្គការទាំងនោះចូលរួមពាក់ព័ន្ធទៅនិងងការកំណត់អត្តសញ្ញាណ និងកំណត់អត្ថន័យបេតិកភណ្ឌវប្បធម៌អរូបិយ និងក្នុងវិធានការអភិរក្សដែលសមស្របផ្សេងទៀត ដោយធ្វើសហប្រតិបត្តិការ និងសម្របសម្រួលជាមួយអង្គការដទៃទៀតដែលពាក់ព័ន្ធក្នុងការអនុវត្តអនុសញ្ញា។

### ៣.២.២ ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលនានាដែលមានការទទួលស្គាល់

### លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់អង្គការក្រៅរដ្ឋាភិបាល 1.EXT.COM 10

៨៨. អង្គការក្រៅរដ្ឋាភិបាលត្រូវ:

ក. មានសមត្ថភាព មានជំនាញ និង បទពិសោធន៍ដោយមានការបញ្ជាក់អះអាងនៅក្នុងការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ(ដូចកំណត់នៅក្នុងមាត្រា២.៣) ដែលជាកម្មសិទ្ធិ របស់ដែនកំណត់មួយ ឬ ច្រើន។ មាត្រា២.២

ខ. មានលក្ខណៈបែបក្នុងស្រុក ថ្នាក់ជាតិ ក្នុងតំបន់ ឬ អន្តរជាតិ ដែលសមស្រប។

គ. មានកម្មវត្ថុស្របទៅនឹងខ្លឹមសារនៃអនុសញ្ញា និង មានលក្ខន្តិកៈ ឬ បទបញ្ញាផ្ទៃក្នុងដែលស្របទៅនឹងកម្មវត្ថុទាំងនោះ។

ឃ. មានកិច្ចសហប្រតិបត្តិការក្នុងស្មារតីគោរពគ្នាទៅវិញទៅមក ជាមួយ សហគមន៍ ក្រុម និងផ្នែកផ្សេងទៀតដូចជា បុគ្គល ដែលបង្កើត អនុវត្ត និងផ្ទេរបេតិកភណ្ឌវប្បធម៌អរូបិយ។

ង. ត្រូវមានសមត្ថភាពប្រតិបត្តិការ ដែលរួមមាន:

(i) សមាជិកភាពសកម្មអចិន្ត្រៃយ៍ដែលបង្កើតសហគមន៍ដែលមានបំណងដើម្បីសម្រេចកម្មវត្ថុដែលបានបង្កើតឡើង។

(ii) មានទីលំនៅស្របច្បាប់ និងនីតិបុគ្គលភាពដែលមានការទទួលស្គាល់ស្របទៅនឹងច្បាប់ក្នុងស្រុក។

(iii) មានសកម្មភាពសមស្រប និង បានបន្តសកម្មភាពទាំងនោះ យ៉ាងហោចណាស់៤ឆ្នាំ នៅពេលត្រូវបានពិចារណាទទួលស្គាល់។

### បែបបទនិង ការពិនិត្យឡើងវិញលើការទទួលស្គាល់ មាត្រា៩

៨៩. គណៈកម្មាធិការស្នើឱ្យលេខាធិការដ្ឋានទទួលសំណើពីអង្គការក្រៅរដ្ឋាភិបាល ហើយដាក់ជូនជាអនុសាសន៍មកខ្លួនដែលទាក់ទងទៅនឹងការទទួលស្គាល់ ការរក្សា ឬការបញ្ចប់ទំនាក់ទំនង របស់ខ្លួនជាមួយអង្គការក្រៅរដ្ឋាភិបាលទាំងនោះ។ 1EXT.COM 10

៩០. គណៈកម្មាធិការដាក់អនុសាសន៍របស់ខ្លួនជូនមហាសន្និបាត ដើម្បីសម្រេចដោយអនុលោមទៅតាមមាត្រា៩នៃអនុសញ្ញា។ នៅក្នុងការទទួល និង វាយតម្លៃទៅលើសំណើនោះ គណៈកម្មាធិការត្រូវយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវទៅលើគោលការណ៍ភាពជាតំណាងសមធម៌ និង ភូមិសាស្ត្រ

ដោយផ្អែកទៅលើព័ត៌មានដែលលេខាធិការដ្ឋានផ្តល់ឱ្យ។ អង្គការក្រៅរដ្ឋាភិបាលដែលត្រូវបានទទួលស្គាល់ ត្រូវអនុវត្តទៅតាមបទដ្ឋានសីលធម៌ និង ច្បាប់ទាំងក្នុងស្រុក និង អន្តរជាតិ។

៩១. គណៈកម្មាធិការធ្វើការត្រួតពិនិត្យឡើងវិញទៅលើការរួមវិភាគទាន និង ការប្តេជ្ញារបស់អង្គការប្រឹក្សាយោបល់ និងទំនាក់ទំនងរបស់អង្គការនេះជាមួយគណៈកម្មាធិការរៀងរាល់៤ឆ្នាំម្តង បន្ទាប់ពីការទទួលស្គាល់ និង ធ្វើការពិចារណាទៅលើទស្សនវិស័យរបស់អង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ។

៩២. ការបញ្ចប់ទំនាក់ទំនងអាចត្រូវបានសម្រេចនៅពេលធ្វើការត្រួតពិនិត្យឡើង វិញ ប្រសិនបើគណៈកម្មាធិការយល់ថាចាំបាច់។ ប្រសិនបើកាលៈទេសៈតម្រូវទំនាក់ទំនងជាមួយអង្គការដែលពាក់ព័ន្ធអាចត្រូវព្យួរជាបណ្តោះអាសន្ន រហូតដល់មានសេចក្តីសម្រេចដែលទាក់ទងទៅនឹងការបញ្ចប់ទំនាក់ទំនង ទាំងនេះត្រូវបានធ្វើឡើង។

**មុខងារប្រឹក្សាយោបល់**

៩៣. ដោយយោងទៅតាមមាត្រា៩.១នៃអនុសញ្ញា អង្គការក្រៅរដ្ឋាភិបាលដែលមានការទទួលស្គាល់ ត្រូវមានតួនាទីផ្តល់ប្រឹក្សាយោបល់ដល់គណៈកម្មាធិការ អាចត្រូវបានអញ្ជើញដោយគណៈកម្មាធិការដើម្បីផ្តល់យោបល់ ដោយរួមទាំងរបាយការណ៍ការត្រួតពិនិត្យដែលជាសំអាងសម្រាប់គណៈកម្មាធិការ ដើម្បីធ្វើការវាយតម្លៃ: មាត្រា ៩ 2.COM 7

ក. សំណុំឯកសារចុះបញ្ជីការអភិរក្សបន្ទាន់
ខ. កម្មវិធី គម្រោង និង សកម្មភាពនានាដែលបានលើកឡើងក្នុងមាត្រា១៨
គ. សំណើសុំជំនួយអន្តរជាតិ
ឃ. ឥទ្ធិពលនៃផែនការអភិរក្សបេតិកភណ្ឌដែលបានបញ្ចូលទៅក្នុងបញ្ជីការអភិរក្សបេតិកភណ្ឌ។

**នីតិវិធីសម្រាប់ការទទួលស្គាល់** 2.COM 7

៩៤. អង្គការក្រៅរដ្ឋាភិបាលដែលស្នើសុំការទទួលស្គាល់ធ្វើជាអ្នកចូលរួមផ្តល់ការប្រឹក្សាយោបល់ឱ្យគណៈកម្មាធិការត្រូវផ្តល់ព័ត៌មានដល់លេខាធិការដ្ឋាន ដូចខាងក្រោម:

ក. ការពិពណ៌នាអំពីអង្គការ /ស្ថាប័ន ដោយរាប់បញ្ចូលទាំងឈ្មោះផ្លូវការ

ខ. កម្មវត្ថុចម្បង

គ. អាសយដ្ឋានពេញលេញ

ឃ. កាលបរិច្ឆេទនៃការបង្កើត ឬរយៈពេលប្រហាក់ប្រហែលដែលអង្គការ បានកកើតឡើង

ង. ឯកសារដែលបង្ហាញថាអង្គការមានសមត្ថភាពប្រតិបត្តិការ រួមមាន ភស្តុតាងនៃ:

(i) សមាជិកភាពសកម្មអចិន្ត្រៃយ៍ ដែលបង្កើតសហគមន៍ដែលមានបំណងដើម្បីសម្រេចកម្មវត្ថុដែលបានបង្កើតឡើង។

(ii) មានទីលំនៅស្របច្បាប់ និង នីតិបុគ្គលភាពដែលមានការទទួល ស្គាល់ស្របទៅនឹងច្បាប់ ក្នុងស្រុក។

(iii) មានសកម្មភាពសមស្រប និងបានបន្តសកម្មភាពទាំងនោះ យ៉ាងហោចណាស់ ៤ឆ្នាំនៅពេលត្រូវបានពិចារណាទទួល ស្គាល់។

ច. សកម្មភាពរបស់អង្គការនៅក្នុងវិស័យអភិរក្សបេតិកភណ្ឌវប្បធម៌ អរូបិយ។

ជ. ការពិពណ៌នាអំពីបទពិសោធន៍ក្នុងការសហប្រតិបត្តិការជាមួយ សហគមន៍ ក្រុម និងម្ចាស់បេតិកភណ្ឌវប្បធម៌អរូបិយ។

សំណើសុំការទទួលស្គាល់ត្រូវបញ្ជូនទៅលេខាធិការដ្ឋាន ដោយប្រើប្រាស់ ទម្រង់គំរូដែលភ្ជាប់ជាឧបសម្ព័ន្ធនៅក្នុងសេចក្តីណែនាំនេះ ដោយធ្វើឡើងយ៉ាងតិចបីខែមុនកិច្ចប្រជុំសាមញ្ញរបស់គណៈកម្មាធិការ តាមរយៈអ៊ីមែល: ICH-assistance@unesco.org ឬ តាមរយៈប៉ុស្តិ៍ប្រៃសណីយ៍៖

UNESCO, Section of Intangible Cultural Heritage (NGOs)
1 rue Miollis
75732 Paris CEDEX 15-France

៩៥. លេខាធិការដ្ឋានត្រូវចុះបញ្ជីសំណើ និងធ្វើបច្ចុប្បន្នកម្មបញ្ជីឈ្មោះអង្គការក្រៅរដ្ឋាភិបាលដែលត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការ។

# ជំពូកទី IV: ការធ្វើរបាយការណ៍ទៅគណៈកម្មាធិការ

## របាយការណ៍របស់រដ្ឋភាគីស្តីពីការអនុវត្តអនុសញ្ញា

៩៦. រដ្ឋភាគីនីមួយៗ ត្រូវដាក់របាយការណ៍ជូនគណៈកម្មាធិការទៅតាម ពេលកំណត់អំពីវិធានការច្បាប់ បទបញ្ញា និងវិធានការផ្សេងៗទៀត ប្រើប្រាស់សម្រាប់អនុវត្តអនុសញ្ញា។

៩៧. រដ្ឋភាគីត្រូវដាក់របាយការណ៍ជូនគណៈកម្មាធិការទៅតាមពេលកំណត់ ដោយផ្អែកទៅលើគោលការណ៍ណែនាំរួម និង តាមទម្រង់សាមញ្ញដែលរៀបចំដោយលេខាធិការដ្ឋាន និងដែលបានអនុម័តដោយគណៈកម្មាធិការ ឱ្យបានមុនថ្ងៃទី១៥ ខែធ្នូ នៃឆ្នាំទី៦បន្ទាប់ពីឆ្នាំដែលរដ្ឋសមាជិកបានដាក់លិខិតូបករណ៍នៃការឱ្យសច្ចាប័ន ការទទួលយក ឬ ការព្រមព្រៀង និង រៀងរាល់ឆ្នាំទី៦បន្ទាប់ពីនោះ។

៩៨. រដ្ឋភាគីត្រូវធ្វើរបាយការណ៍អំពីវិធានការប្រើប្រាស់សម្រាប់ការអនុវត្តអនុសញ្ញានៅថ្នាក់ជាតិដែលរួមមាន:

ក. រៀបចំបញ្ជីសារពើភ័ណ្ឌបេតិកភណ្ឌវប្បធម៌អរូបិយដែលមានវត្តមាន នៅក្នុងទឹកដីខ្លួនដូចមានចែងក្នុងមាត្រា១១ និង ១២ នៃអនុសញ្ញា។

ខ. វិធានការផ្សេងៗទៀតសម្រាប់ការអភិរក្ស ដូចមានចែងក្នុងមាត្រា ១១ និង ១៣ នៃអុនសញ្ញាដែលរួមមាន:

(i) ការលើកកម្ពស់មុខងាររបស់បេតិកភណ្ឌវប្បធម៌អរូបិយនៅក្នុងសង្គម និង ការដាក់បញ្ចូលការអភិរក្សរបស់ខ្លួនទៅក្នុងការធ្វើផែនការកម្មវិធី។

(ii) អភិវឌ្ឍន៍ការសិក្សាទៅលើផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស និង សិល្បៈដោយមានក្តីសង្ឃឹមថានឹងធ្វើឱ្យមានប្រសិទ្ធភាពក្នុងការ អភិរក្ស។

(iii) តាមវិសាលភាពដែលអាចធ្វើបាន ជួយសម្របសម្រួលដល់ការទទួលបានព័ត៌មាន ដែលទាក់ទង ទៅនឹងបេតិកភណ្ឌវប្បធម៌ អរូបិយ ទន្ទឹមនឹងនោះដែរ

ក៏ត្រូវគោរពទូវការអនុវត្តតាម បែបទំនៀមទម្លាប់ដែលគ្រប់គ្រងទៅលើការទទួលបានព័ត៌មាន ក្នុងផ្នែកជាក់លាក់មួយចំនួន។

៩៩. រដ្ឋភាគីត្រូវធ្វើរបាយការណ៍អំពីវិធានការដែលប្រើប្រាស់នៅថ្នាក់ជាតិ ដើម្បីពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ ដូចមានចែងក្នុងមាត្រា១៣ ដែលរួមមាន:

ក. ការចាត់តាំង ឬ ការបង្កើតស្ថាប័នដែលមានសមត្ថកិច្ចមួយ ឬច្រើនសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយរបស់ខ្លួន។

ខ. ធ្វើឱ្យស្ថាប័នមានការប្រសើរឡើង សម្រាប់ការបណ្តុះបណ្តាលទៅលើការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌អរូបិយ និង ការផ្ទេរបេតិកភណ្ឌនេះ។

គ. បង្កើតស្ថាប័នតម្កល់ឯកសារបេតិកភណ្ឌវប្បធម៌អរូបិយនានា និង ជួយសម្រួលដល់លទ្ធភាពអាចប្រើប្រាស់វាបាន។

១០០. រដ្ឋភាគីត្រូវធ្វើរបាយការណ៍អំពីវិធានការដែលបានប្រើប្រាស់នៅថ្នាក់ជាតិ ដើម្បីធានាឱ្យមានការទទួលស្គាល់ការគោរព និងការលើកកម្ពស់បេតិកភណ្ឌវប្បធម៌អរូបិយកាន់តែខ្លាំងឡើង ជាពិសេសវិធានការដែលមាន ចែងនៅក្នុងមាត្រា១៤ទៅលើ៖

ក. កម្មវិធីអប់រំលើកកម្ពស់ការយល់ដឹង និង កម្មវិធីព័ត៌មានផ្សេងៗ។

ខ. កម្មវិធីអប់រំ និង បណ្តុះបណ្តាលនៅក្នុងសហគមន៍ និងក្រុមដែលពាក់ព័ន្ធ។

គ. សកម្មភាពកសាងសមត្ថភាពសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ អរូបិយ។

ឃ. មធ្យោបាយក្រៅប្រព័ន្ធនៃការផ្ទេរចំណេះដឹង។

ង. ការអប់រំសម្រាប់ការអភិរក្សទីតាំង និងទីតាំងអនុស្សាវរីយ៍ធម្មជាតិនានា។

១០១. រដ្ឋសមាជិកត្រូវធ្វើរបាយការណ៍អំពីវិធានការ ដែលប្រើប្រាស់ជាលក្ខណៈទ្វេភាគី អនុតំបន់តំបន់ និងជាអន្តរជាតិ សម្រាប់ការអនុវត្តអនុសញ្ញា ដោយរាប់បញ្ចូលទាំងវិធានការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិដែលរួមមាន ការផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មាន និងគំនិតផ្តួចផ្តើមរួមគ្នា ផ្សេងទៀត ដូចមានចែងក្នុងមាត្រា១៩នៃអនុសញ្ញា។

១០២. រដ្ឋសមាជិក ត្រូវធ្វើរបាយការណ៍អំពីស្ថានភាពបច្ចុប្បន្ននៃសមាសធាតុបេតិកភ័ណ្ឌវប្បធម៌អរូបិយដែលមានវត្តមាននៅលើទឹកដីរបស់រដ្ឋនោះ ដែលត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីឈ្មោះ

អ្នកតំណាង។ រដ្ឋសមាជិកត្រូវប្រឹងប្រែងធានាឱ្យមានការចូលរួមយ៉ាងទូលំទូលាយបំផុតតាមដែលអាចធ្វើបានពីសហគមន៍ ក្រុមនិងផ្នែកផ្សេងទៀតដូចជាបុគ្គលដែលពាក់ព័ន្ធនៅក្នុងអំឡុងពេលរៀបចំរបាយការណ៍ដែលត្រូវលើកឡើងពីគ្រប់សមាសធាតុដែលពាក់ព័ន្ធ៖

ក. សមាសធាតុនៃមុខងារវប្បធម៌ និង សង្គម

ខ. ការវាយតម្លៃទៅលើភាពសម្រេចបាន និង ស្ថានភាពហានិភ័យបច្ចុប្បន្នដែលខ្លួនប្រឈម ប្រសិនបើមាន។

គ. ការរួមវិភាគទានចំពោះគោលដៅនៃបញ្ជីឈ្មោះ។

ឃ. កិច្ចប្រឹងប្រែងដើម្បីលើកកម្ពស់ ឬ ពង្រឹងសមាសធាតុ ជាពិសេសការអនុវត្តវិធានការទាំងឡាយណាដែលអាចមានភាពចាំបាច់ដែលជាផលវិបាកនៃការដាក់បញ្ចូលទៅក្នុងបញ្ជី។

ង. ការចូលរួមរបស់សហគមន៍ ក្រុម និង បុគ្គល ក្នុងការអភិរក្ស សមាសធាតុ និងការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការអភិរក្សបន្ថែម។

១០៣. រដ្ឋភាគី ត្រូវធ្វើរបាយការណ៍អំពីបរិបទរបស់ស្ថាប័នសម្រាប់សមាសធាតុ ដែលត្រូវបានដាក់បញ្ចូល ទៅក្នុងបញ្ជីឈ្មោះអ្នកតំណាង ដែលរួមមាន៖

ក. ស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការគ្រប់គ្រង និង/ឬ ការ អភិរក្ស។

ខ. ការរៀបចំសហគមន៍ ឬ ក្រុមដែលពាក់ព័ន្ធជាមួយសមាសធាតុ និងការអភិរក្សរបស់ខ្លួន។

១០៤. រដ្ឋសមាជិក ត្រូវឆ្លើយតបទៅតាមពេលវេលាទៅនឹងសំណើជាក់លាក់ដែលគណៈកម្មាធិការលើកឡើង សម្រាប់ព័ត៌មានបន្ថែម ប្រសិនបើចាំបាច់ ក្នុង ចន្លោះពេលកំណត់ដែលកំណត់នៅក្នុងកថាខណ្ឌទី៩៧ខាងលើ។

## របាយការណ៍របស់រដ្ឋភាគីស្តីពីសមាសធាតុដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីការអភិរក្សបន្ទាន់

2.EXT.COM 14

១០៥. រដ្ឋសមាជិកនីមួយៗត្រូវដាក់របាយការណ៍ជូនគណៈកម្មាធិការអំពីស្ថានភាព នៃសមាសធាតុបេតិកភណ្ឌវប្បធម៌អរូបិយដែលមានវត្តមាននៅលើទឹកដីរបស់ខ្លួន ដែលត្រូវបានដាក់បញ្ចូល

ទៅក្នុងបញ្ជីការអភិរក្សបន្ទាន់តាមសំណើរបស់ខ្លួន ឬ ក្នុងករណីបន្ទាន់បំផុត បន្ទាប់ពីបាន ពិភាក្សាជាមួយគណៈកម្មាធិការ។ រដ្ឋភាគីត្រូវខិតខំធ្វើយ៉ាងណាឱ្យមានការចូលរួមពីសំណាក់ សហគមន៍ ក្រុម និង បុគ្គលដែលពាក់ព័ន្ធ ឱ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបានក្នុង ដំណើរការរៀបចំរបាយការណ៍នេះ។

១០៦. ជាធម្មតា របាយការណ៍នេះត្រូវដាក់ជូនគណៈកម្មាធិការ ដោយផ្អែកទៅលើគោលការណ៍ ណែនាំរួម និងតាមទម្រង់សាមញ្ញដែល រៀបចំ ដោយលេខាធិការដ្ឋាន និងដែលបានអនុម័ត ដោយគណៈកម្មាធិការ ឱ្យបានមុនថ្ងៃទី១៥ ខែធ្នូ នៃឆ្នាំទី៤បន្ទាប់ពីឆ្នាំដែលសមាសធាតុត្រូវ បានដាក់បញ្ចូល និង រៀង រាល់៤ឆ្នាំបន្ទាប់ពីនោះ។ នៅពេលដាក់បញ្ចូលទៅក្នុងបញ្ជីគណៈ កម្មាធិការអាចរៀបចំកាលវិភាគដាក់លាក់សម្រាប់ការរាយការណ៍ អាស្រ័យទៅតាមករណី នីមួយៗ ដែលនឹងមានអាទិភាពជាលក្ខណៈវដ្ត៤ឆ្នាំធម្មតា។

១០៧. រដ្ឋភាគីត្រូវធ្វើរបាយការណ៍អំពីស្ថានភាពបច្ចុប្បន្ននៃសមាសធាតុដែលរួមមាន:

ក. មុខងារវប្បធម៌ និង សង្គម

ខ. ការវាយតម្លៃទៅលើភាពសម្រេចបាន និងស្ថានភាពហានិភ័យបច្ចុប្បន្នដែលខ្លួនប្រឈម

គ. ឥទ្ធិពលនៃកិច្ចខិតខំប្រឹងប្រែងអភិរក្សសមាសធាតុ ជាពិសេសការអនុវត្តផែនការ អភិរក្សដែលត្រូវបានដាក់ជូននៅពេលទទួលការចុះបញ្ជី។

ឃ. ការចូលរួមរបស់សហគមន៍ ក្រុម និង បុគ្គល នៅក្នុងការអភិរក្សសមាសធាតុ និង ការប្តេជ្ញាចិត្តរបស់ពួកគេដើម្បីអភិរក្សបន្ថែម។

១០៨. រដ្ឋភាគី ត្រូវធ្វើរបាយការណ៍អំពីបរិបទរបស់ស្ថាប័ន សម្រាប់ការអភិរក្សសមាសធាតុដែលត្រូវ បានដាក់បញ្ចូលទៅក្នុងបញ្ជី ដែលរួមមាន:

ក. ស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការអភិរក្ស។

ខ. ការរៀបចំសហគមន៍ឬក្រុមដែលពាក់ព័ន្ធជាមួយសមាសធាតុនិងការអភិរក្សរបស់ខ្លួន។

១០៩. រដ្ឋភាគី ត្រូវឆ្លើយតបទៅតាមពេលវេលាទៅនឹងសំណើជាក់លាក់ដែលគណៈកម្មាធិការលើក ឡើងសម្រាប់ព័ត៌មានបន្ថែម ប្រសិនបើចាំបាច់ ក្នុងចន្លោះពេលកំណត់ដែលកំណត់នៅក្នុង កថាខណ្ឌទី១០៦ខាងលើ។

### ការទទួលយក និង ដំណើរការរបាយការណ៍

១១០. យោងទៅលើការទទួលយករបាយការណ៍ពីរដ្ឋភាគី លេខាធិការដ្ឋាន ត្រូវចុះបញ្ជីរបាយការណ៍ទាំងនោះ និងទទួលស្គាល់នូវការទទួលយកនោះ។ ប្រសិនបើរបាយការណ៍មិនពេញលេញ រដ្ឋសមាជិកនឹងត្រូវបានផ្តល់យោបល់អំពីរបៀបដើម្បីបញ្ចប់របាយការណ៍នោះ។

១១១. លេខាធិការដ្ឋាននឹងបញ្ជូនរបាយការណ៍ទៅគណៈកម្មាធិការ នូវសេចក្តីសង្ខេបនៃរបាយការណ៍ទាំងអស់ដែលបានទទួលមុនសម័យប្រជុំអចិន្ត្រៃយ៍របស់ខ្លួននីមួយៗ។ សេចក្តីសង្ខេប និងរបាយការណ៍នឹងអាចផ្តល់ដល់រដ្ឋភាគី សម្រាប់ជាព័ត៌មាន។

១១២. ក្រោយពីសម័យប្រជុំដែលបានសំរេចដោយគណៈកម្មាធិការ របាយការណ៍អាចផ្សព្វផ្សាយជូនសាធារណជនសម្រាប់ជាព័ត៌មានបាន លើកលែងតែមានការសំរេចដោយគណៈកម្មាធិការនៅក្នុងករណីពិសេសណាមួយ។

### របាយការណ៍របស់រដ្ឋមិនមែនជាភាគីនៃអនុសញ្ញាអំពីសមាសធាតុដែលត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីតំណាង

១១៣. កថាខណ្ឌទី ១០២ ដល់ ១០៤ និង ១១០ ដល់ ១១២ នៃសេចក្តីណែនាំទាំងនេះត្រូវអនុវត្តទាំងស្រុងទៅលើរដ្ឋមិនមែនជាភាគីនៃអនុសញ្ញា ដែលបេតិកភណ្ឌនៅក្នុងទឹកដីរបស់ពួកគេត្រូវបានប្រកាសថាជាស្នាដៃឯក និងបានដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះអ្នកតំណាង និងដែលត្រូវបានព្រមព្រៀងទទួលយកសិទ្ធិ និង កាតព្វកិច្ចដែលមាននៅក្នុងអនុសញ្ញា។

១១៤. របាយការណ៍ទាំងនោះ ត្រូវដាក់ជូនគណៈកម្មាធិការដោយរដ្ឋមិនមែនជាភាគី តាមទម្រង់បានបញ្ជាក់ច្បាស់លាស់ឱ្យបានមុន ថ្ងៃទី១៥ ខែធ្នូ នៃឆ្នាំទី៦ បន្ទាប់ពីឆ្នាំដែលសមាសធាតុត្រូវបានដាក់បញ្ចូល និង រៀងរាល់៦ឆ្នាំបន្ទាប់ពីពេលនោះ។

## ទម្រង់សម្រាប់ការចុះបញ្ជី សំណើ និងការស្នើសុំ

ទម្រង់ខាងក្រោមនេះអាចទាញយកបានតាមរយៈគេហទំព័រ:

**http://www.unesco.org/culture/ich/en/forms/**

ឬអាចរកបានតាមរយៈការស្នើសុំទៅ លេខាធិការដ្ឋានតាមរយៈ អ៊ីមែល ៖ ich@unesco.org

ទូរស័ព្ទលេខៈ + ៣៣ (0)១ ៤៥ ៦៨ ៤៥ ១៩ ទូរសារលេខ : + ៣៣ (0)១ ៤៥ ៦៨ ៥៧ ៥២

- ទម្រង់ស្នើសុំឱ្យចុះនៅក្នុងបញ្ជីអភិរក្សជាបន្ទាន់ (ICH-01)
- ទម្រង់ស្នើសុំ ឱ្យចុះនៅក្នុងបញ្ជីតំណាង (ICH-02)
- សំណើរបស់កម្មវិធី គម្រោង ឬសកម្មភាពដែលត្រូវធ្វើការជ្រើសរើស និងផ្សព្វផ្សាយជាការឆ្លុះបញ្ចាំងយ៉ាងល្អបំផុតនូវគោលការណ៍ និងគោលបំណងផ្សេងៗរបស់អនុសញ្ញា (ICH-03)
- ការស្នើសុំជំនួយអន្តរជាតិពីមូលនិធិបេតិកភណ្ឌអរូបិយ (IHC-04)
- ការស្នើសុំជំនួយរៀបចំសម្រាប់ការបកស្រាយលំអិតអំពីការអនុញ្ញាតិឱ្យចុះឈ្មោះនៅក្នុងបញ្ជីអភិរក្សជាបន្ទាន់ (ICH-05)
- ការស្នើសុំជំនួយរៀបចំសម្រាប់ធ្វើការបកស្រាយលំអិតអំពីសំណើ របស់កម្មវិធី គម្រោង ឬសកម្មភាពដែលត្រូវជ្រើសរើស និងផ្សព្វផ្សាយជាការឆ្លុះបញ្ចាំងយ៉ាងល្អបំផុតនូវគោលការណ៍ និងគោល បំណងផ្សេងៗរបស់អនុសញ្ញា (ICH-06)
- ការប្រគល់សិទ្ធិ និងរៀបចំចុះបញ្ជីឯកសារផ្សេងៗ (ICH-07)
- ការស្នើសុំធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលដែលត្រូវទទួលស្គាល់ឱ្យផ្តល់នូវសេវាផ្តល់ប្រឹក្សាដល់គណៈកម្មាធិការ (ICH-09)

ទម្រង់ ICH-01 ខាងក្រោមនេះអាចទាញយកបានតាមរយៈគេហទំព័រ **http://www.unesco.org/culture/ich/en/forms/** ឬ អាចរកបានតាមរយៈការស្នើសុំទៅលេខាធិការដ្ឋានតាមអ៊ីមែល : ich@unesco.org ទូរស័ព្ទ លេខ : + ៣៣ (0) ១ ៤៥ ៦៨ ៤៥ ១៩ ទូរសារលេខ :+ ៣៣ (0)១ ៤៥ ៦៨ ៥៧ ៥២

| **ICH-01- ទម្រង់នៃការតែងតាំងឱ្យចុះឈ្មោះនៅក្នុងបញ្ជីអភិរក្សជាបន្ទាន់** |
|---|
| គម្របឯកសារ |
| ក. រដ្ឋភាគី |
| ខ. ឈ្មោះរបស់បេតិកភណ្ឌ *មិនឱ្យលើសពី ២០០ តួអក្សរឡើយ។* |
| គ. ឈ្មោះសហគមន៍ ក្រុម ឬ បើពាក់ព័ន្ធ ដាក់ឈ្មោះបុគ្គលដែលពាក់ព័ន្ធ *មិនឱ្យលើសពី ២០០ ពាក្យឡើយ។* |
| ឃ. ការពិពណ៌នាដោយសរសេរជាអត្ថបទសង្ខេបអំពីបេតិកភណ្ឌដែលត្រូវបាន តែងតាំង *មិនឱ្យលើសពី ២០០ពាក្យឡើយ* |
| ង. សេចក្តីថ្លែងដោយសង្ខេបអំពីភាពគង់វង្សនៃបេតិកភណ្ឌ , តម្រូវការរបស់ខ្លួនសម្រាប់ការអភិរក្ស និងវិធានការណ៍អភិរក្សដែលបានស្នើសុំ *មិនឱ្យលើសពី ៣០០ពាក្យឡើយ។* |
| **ការចុះបញ្ជី** |
| **១. អត្តសញ្ញាណនៃបេតិកភណ្ឌ** |
| ១.ក. ឈ្មោះបេតិកភណ្ឌ |
| ១.ខ. ឈ្មោះផ្សេងទៀតនៃបេតិកភណ្ឌ ប្រសិនបើមាន |
| ១.គ. អត្តសញ្ញាណនៃសហគមន៍ ក្រុម ប្រសិនបើពាក់ព័ន្ធ ដាក់ឈ្មោះបុគ្គលដែលពាក់ព័ន្ធ និងទីតាំងរបស់ពួកគេ |
| ១.ឃ.ទីតាំងភូមិសាស្ត្រ និងលេខរៀងរបស់បេតិកភណ្ឌ |
| ១.ង. វិស័យដែលតំណាងដោយបេតិកភណ្ឌនោះ |
| **២. ការពិពណ៌នាពីបេតិកភណ្ឌ (cf. លក្ខណវិនិច្ឆ័យ U.1)** *មិនឱ្យលើសពី ១ ០០០ ពាក្យឡើយ* |
| **៣. តម្រូវការសម្រាប់ការអភិរក្សជាបន្ទាន់ (cf. លក្ខណវិនិច្ឆ័យ U.2)** |
| ៣.ក. ការវាយតម្លៃលើភាពគង់វង្ស *មិនលើសពី ៥០០ ពាក្យឡើយ* |
| ៣.ខ. ការវាយតម្លៃលើការគំរាមកំហែង និងហានិភ័យ *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |

| **៤.វិធានការណ៍អភិរក្ស(cf. លក្ខណវិនិច្ឆ័យ U.3)** |
|---|
| ៤.ក. កិច្ចខិតខំប្រឹងប្រែងនាពេលបច្ចុប្បន្នក្នុងការអភិរក្ស បេតិកភណ្ឌ *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| ៤.ខ. វិធានការណ៍ការអភិរក្សដែលបានស្នើសុំ *មិនឱ្យលើសពី ២ ០០០ ពាក្យឡើយ* |
| ៤.គ. ការប្តេជ្ញាចិត្តរបស់រដ្ឋ សហគមន៍ ក្រុម ឬ បុគ្គលដែល ពាក់ព័ន្ធ *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| **៥. ការចូលរួមពាក់ព័ន្ធ និងការឯកភាពរបស់សហគមន៍ (cf. លក្ខណវិនិច្ឆ័យ U.4)** |
| ៥.ក. ការចូលរួមរបស់សហគមន៍ ក្រុម និងបុគ្គល |
| ៥.ខ. ការយល់ព្រមដោយសេរី យល់ព្រមជាមុន និងយល់ព្រមតាមការជូនដំណឹង |
| ៥.គ. ការគោរពចំពោះការអនុវត្តតាមបែបប្រពៃណី ដែលគ្រប់គ្រងលើការចូលទៅកាន់បេតិកភណ្ឌ |
| **៦. សេចក្តីសន្និដ្ឋានលើបញ្ជីសារពើភ័ណ្ឌ (cf. លក្ខណវិនិច្ឆ័យ U.5)** |
| **៧. ការរៀបចំឯកសារ** |
| ៧.ក. ការរៀបចំឯកសារដែលត្រូវការ និងឯកសារបន្ថែម |
| ៧.ខ. ការប្រគល់សិទ្ធិ ឬ អជ្ញាប័ណ្ណាធម្មតាស្តីពីភាពច្នៃប្រឌិត |
| ៧.គ. បញ្ជីរាយនាមធនធានបន្ថែម *មិនឱ្យលើសពី ១ទំព័រឡើយ* |
| **៨. ព័ត៌មានសម្រាប់ទំនាក់ទំនង** |
| ៨.ក. រដ្ឋសមាជិកដែលដាក់សំណើ |
| ៨.ខ. មនុស្សសម្រាប់ទំនាក់ទំនងដើម្បីឆ្លើយឆ្លងព័ត៌មាន |
| ៨.គ. ស្ថាប័នមានសមត្ថកិច្ចដែលចូលរួមពាក់ព័ន្ធ |
| ៨.ឃ. អង្គការសហគមន៍ ឬ អ្នកតំណាងដែលពាក់ព័ន្ធ |
| **៩. ហត្ថលេខាជូនសមុខឱ្យរដ្ឋភាគី** |

ទម្រង់ ICH-02 ខាងក្រោមនេះអាចទាញយកបានតាមរយៈគេហទំព័រ **http://www.unesco.org/culture/ich/en/forms/** ឬ អាចរកបានតាមរយៈការស្នើសុំទៅលេខាធិការដ្ឋានតាមអ៊ីមែល : ich@unesco.org ទូរស័ព្ទ លេខ : + ៣៣ (0) ១ ៤៥ ៦៨ ៤៥ ១៩   ទូរសារលេខ :+ ៣៣ (0) ១ ៤៥ ៦៨ ៥៧ ៥២

| **ICH-02-**<br>**ទម្រង់នៃការស្នើសុំការអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីអ្នកតំណាង** |
|---|
| គម្របឯកសារ |
| ក. រដ្ឋភាគី |
| ខ. ឈ្មោះរបស់បេតិកភណ្ឌ *មិនឱ្យលើសពី ២០០ តួអក្សរឡើយ។* |
| គ. ឈ្មោះសហគមន៍ ក្រុម ឬ បើពាក់ព័ន្ធ ដាក់ឈ្មោះបុគ្គលដែលពាក់ព័ន្ធ *មិនឱ្យលើសពី ១០០ ពាក្យឡើយ។* |
| ឃ. ការពិពណ៌នាដោយសរសេរជាអត្ថបទសង្ខេបអំពីបេតិកភណ្ឌដែលត្រូវបាន តែងតាំង *មិនឱ្យលើសពី ២០០ពាក្យឡើយ* |
| **ការចុះបញ្ជី** |
| **១. អត្តសញ្ញាណនៃបេតិកភណ្ឌ** |
| ១.ក. ឈ្មោះបេតិកភណ្ឌ |
| ១.ខ. ឈ្មោះផ្សេងទៀតនៃបេតិកភណ្ឌ ប្រសិនបើមាន |
| ១.គ. អត្តសញ្ញាណនៃសហគមន៍ ក្រុម ប្រសិនបើពាក់ព័ន្ធ ដាក់ឈ្មោះបុគ្គលដែលពាក់ព័ន្ធ និងទីតាំងរបស់ពួកគេ |
| ១.ឃ.ទីតាំងភូមិសាស្ត្រ និងលេខរៀងរបស់បេតិកភណ្ឌ |
| ១.ង. វិស័យដែលតំណាងដោយបេតិកភណ្ឌនោះ |
| **២. ការពិពណ៌នាពីបេតិកភណ្ឌ (cf. លក្ខណវិនិច្ឆ័យ U.1)**<br>*មិនឱ្យលើសពី ១ ០០០ ពាក្យឡើយ* |
| **៣. ការចូលរួមចំណែកក្នុងការធានាភាពគង់វង្ស និងការយល់ដឹង និងលើកទឹកចិត្តឱ្យមានការពិគ្រោះពិភាក្សា (cf. លក្ខណវិនិច្ឆ័យ U.2)**<br>*មិនឱ្យលើសពី ១ ០០០ ពាក្យឡើយ* |
| **៤. វិធានការណ៍អភិរក្ស(cf. លក្ខណវិនិច្ឆ័យ U.3)** |

| |
|---|
| ៤.ក. កិច្ចខិតខំប្រឹងប្រែងនាពេលបច្ចុប្បន្នក្នុងការអភិរក្សបេតិកភណ្ឌ<br>*មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| ៤.គ. ការប្ដេជ្ញាចិត្តរបស់រដ្ឋ សហគមន៍ ក្រុម ឬ បុគ្គលដែល ពាក់ព័ន្ធ<br>*មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| **៥. ការចូលរួមពាក់ព័ន្ធ និងការឯកភាពរបស់សហគមន៍ (cf. លក្ខណវិនិច្ឆ័យ U.4)** |
| ៥.ក. ការចូលរួមរបស់សហគមន៍ ក្រុម និងបុគ្គល |
| ៥.ខ. ការយល់ព្រមដោយសេរី យល់ព្រមជាមុន និងយល់ព្រមតាមការជូនដំណឹង |
| ៥.គ. ការគោរពចំពោះការអនុវត្តតាមបែបប្រពៃណី ដែលគ្រប់គ្រងលើការចូលទៅកាន់បេតិកភណ្ឌ |
| **៦. សេចក្ដីសន្និដ្ឋានលើបញ្ជីសារពើភ័ណ្ឌ (cf. លក្ខណវិនិច្ឆ័យ U.5)** |
| **៧. ការរៀបចំឯកសារ** |
| ៧.ក. ការរៀបចំឯកសារដែលត្រូវការ និងឯកសារបន្ថែម |
| ៧.ខ. ការប្រគល់សិទ្ធិ ឬ អជ្ញាប័ណ្ណធម្មតាស្ដីពីភាពច្នៃប្រឌិត |
| ៧.គ. បញ្ជីរាយនាមធនធានបន្ថែម *មិនឱ្យលើសពី ១ទំព័រឡើយ* |
| **៨. ព័ត៌មានសម្រាប់ទំនាក់ទំនង** |
| ៨.ក. រដ្ឋសមាជិកដែលដាក់សំណើ |
| ៨.ខ. មនុស្សសម្រាប់ទំនាក់ដើម្បីឆ្លើយឆ្លងព័ត៌មាន |
| ៨.គ. ស្ថាប័នមានសមត្ថកិច្ចដែលចូលរួមពាក់ព័ន្ធ |
| ៨.ឃ. អង្គការសហគមន៍ ឬ អ្នកតំណាងដែលពាក់ព័ន្ធ |
| **៩. ហត្ថលេខាជួសមុខឱ្យរដ្ឋសមាជិក** |

ទម្រង់ ICH-03 ខាងក្រោមនេះអាចទាញយកបានតាមរយៈគេហទំព័រ **http:// www.unesco.org/culture/ich/en/forms/** ឬអាចរកបានតាមរយៈការស្នើសុំទៅលេខាធិការដ្ឋានតាមអ៊ីមែល៖ ich@unesco.org ទូរស័ព្ទលេខ : + ៣៣ (0) ១ ៤៥ ៦៨ ៤៥ ១៩ ទូរសារលេខ:+ ៣៣ (0) ១ ៤៥ ៦៨ ៥៧ ៥២

| **ICH-03- *សំណើកម្មវិធី គម្រោង ឬសកម្មភាពដែលត្រូវជ្រើសរើស និងផ្សព្វផ្សាយជាការឆ្លុះបញ្ចាំងល្អបំផុតនូវគោលការណ៍ និងគោលបំណងនៃអនុសញ្ញា*** |
|---|
| **គម្របឯកសារ** |
| ក. រដ្ឋភាគី |
| ខ. ឈ្មោះកម្មវិធី គម្រោង ឬសកម្មភាពដែលបានស្នើសុំឱ្យជ្រើសរើស និងផ្សព្វផ្សាយ *មិនឱ្យលើសពី ២០០ តួអក្សរឡើយ* |
| គ. វិសាលភាពនៃកម្មវិធី គម្រោង ឬសកម្មភាព<br>□ ថ្នាក់ជាតិ<br>□ ថ្នាក់អនុតំបន់<br>□ ថ្នាក់តំបន់<br>□ ថ្នាក់អន្តរជាតិ(រួមបញ្ចូលទាំងតំបន់ដែលមិនមានភូមិសាស្ត្រជាប់គ្នា) |
| ឃ. ស្ថានភាពនៃកម្មវិធី គម្រោង ឬសកម្មភាព<br>□ ចប់សព្វគ្រប់<br>□ កំពុងដំណើរការ<br>□ ស្ថិតក្នុងគម្រោង |
| ង. សហគមន៍ ក្រុម ឬ បើពាក់ព័ន្ធ ដាក់ឈ្មោះបុគ្គលដែលពាក់ព័ន្ធ *មិនត្រូវឱ្យលើសពី ១០០ ពាក្យឡើយ។* |
| ច. ការពិណិនាដោយសរសេរជាអត្ថបទសង្ខេបអំពីកម្មវិធី គម្រោង ឬសកម្មភាព *មិនឱ្យលើសពី ២០០ពាក្យឡើយ* |
| **សំណើ** |
| **១. អត្តសញ្ញាណនៃកម្មវិធី គម្រោង ឬសកម្មភាពដែលត្រូវជ្រើសរើស និងផ្សព្វផ្សាយ** |
| ១.ក. ឈ្មោះកម្មវិធី គម្រោង ឬសកម្មភាព |
| ១.ខ. អត្តសញ្ញាណនៃសហគមន៍ ក្រុម បើពាក់ព័ន្ធ ដាក់ឈ្មោះបុគ្គលដែលពាក់ព័ន្ធ និង ទីតាំងរបស់ពួកគេ |
| ១.គ. ទីតាំងភូមិសាស្ត្រ និងលេខរៀងរបស់កម្មវិធី គម្រោង ឬសកម្មភាព |
| ១.ឃ. វិស័យដែលតំណាងដោយកម្មវិធី គម្រោង ឬសកម្មភាព ប្រសិនបើមាន |

| **២. ការពិណិនាលើកម្មវិធី គម្រោង ឬសកម្មភាព** |
|---|
| ២.ក. សាវតារ និងសនិទានភាព *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| ២.ខ. វិធានការណ៍អភិរក្សដែលរួមចំណែក *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| **៣. មូលហេតុដែលកម្មវិធី គម្រោង ឬសកម្មភាពនោះស័ក្តិសមនឹងជ្រើសរើស** |
| ៣.ក. របៀបដែលបេតិកភណ្ឌនោះឆ្លុះបញ្ចាំងពីគោលការណ៍ និងគោលបំណងនៃអនុសញ្ញា : *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| ៣.ខ. ប្រសិទ្ធភាពរបស់បេតិកភណ្ឌដែលបានបង្ហាញ និងបានរំពឹងទុកសមហេតុផល *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| ៣.គ. របៀបដែលបេតិកភណ្ឌអាចលើកកម្ពស់ការសម្របសម្រួលនៅថ្នាក់តំបន់ អនុតំបន់ និង/ឬ ថ្នាក់អន្តរជាតិ ប្រសិនបើ ពាក់ព័ន្ធ : *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| ៣.ឃ. របៀបដែលបេតិកភណ្ឌអាចដើរតួជាគំរូនៅ ថ្នាក់តំបន់ អនុតំបន់ និង/ឬ ថ្នាក់អន្តរជាតិ ជាពិសេស សម្រាប់ប្រទេសកំពុងអភិវឌ្ឍ : *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| **៤. ការចូលរួមពាក់ព័ន្ធ និងការឯកភាពរបស់សហគមន៍** |
| ៤.ក. ការចូលរួមពីសំណាក់សហគមន៍ ក្រុម និងបុគ្គលក្នុងកម្មវិធី គម្រោង ឬសកម្មភាព |
| ៤.ខ. ការយល់ព្រមដោយសេរី យល់ព្រមជាមុន និងយល់ព្រមតាមការជូនដំណឹង |
| **៥. ឆន្ទៈក្នុងការសហការផ្សព្វផ្សាយនូវការអនុវត្តដ៏ល្អបំផុត :** *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| **៦. ព័ត៌មានសម្រាប់ទំនាក់ទំនង** |
| ៦.ក. រដ្ឋសមាជិកដែលដាក់សំណើ |
| ៦.ខ. មនុស្សសម្រាប់ទំនាក់ទំនងដើម្បីឆ្លើយឆ្លងព័ត៌មាន |
| ៦.គ. ស្ថាប័នទទួលខុសត្រូវដែលបានចូលរួមចំណែក |
| ៦.ឃ. អង្គការ សហគមន៍ ឬអ្នកតំណាងដែលពាក់ព័ន្ធ |
| **៧. ហត្ថលេខាជួសមុខឱ្យរដ្ឋភាគី** |

ទម្រង់ ICH-04 ខាងក្រោមនេះអាចទាញយកបានតាមរយៈគេហទំព័រ

**http:// www.unesco.org/culture/ich/en/forms/** ឬអាចរកបានតាមរយៈការស្នើសុំទៅ

លេខាធិការដ្ឋានតាមអ៊ីមែល : ich@unesco.org ទូរស័ព្ទលេខ : + ៣៣ (0) ១ ៤៥ ៦៨ ៤៥ ១៩

ទូរសារលេខ :+ ៣៣ (0)១ ៤៥ ៦៨ ៥៧ ៥២

| **ICH-04-** *ការស្នើសុំជំនួយអន្តរជាតិពីមូលនិធីបេតិកភណ្ឌ អរូបិយ* |
|---|
| **គម្របឯកសារ** |
| ក. ឈ្មោះគម្រោង *មិនឱ្យលើសពី ២០០តួអក្សរឡើយ* |
| ខ. រដ្ឋសមាជិកដែលដាក់សំណើ |
| គ. សហគមន៍ ក្រុម ឬបុគ្គល អ្នកទទួលផល |
| ឃ. តើនេះគឺជាការស្នើបន្ទាន់ដែលតម្រូវឱ្យមានដំណើរការចាប់រហ័ស ដែរឬទេ?<br>☐ ការស្នើបន្ទាន់<br>☐ ការស្នើមិនបន្ទាន់<br>*ប្រសិនបើនេះជាសំណើបន្ទាន់ នោះព័ត៌មានដែលត្រូវការនៅក្នុងផ្នែកទី ៤ ទី៥ និងទី៦ អាចបញ្ជូននៅក្នុង ដំណាក់កាលបន្ទាប់ ប្រសិនបើចាំបាច់។* |
| ង. គោលបំណងនៃសំណើ (ត្រួតពិនិត្យមើល)<br>☐ ការពារបេតិកភណ្ឌដែលបានចុះនៅក្នុងបញ្ជីអភិរក្សជាបន្ទាន់<br>☐ ការពារបេតិកភណ្ឌដែលបានកំពុងត្រូវបានតែងតាំងឱ្យចុះឈ្មោះនៅក្នុងបញ្ជីអភិរក្សជាបន្ទាន់<br>☐ ពិពណ៌នាលំអិតអំពីបញ្ជីសារពើភណ្ឌ<br>☐ ការអនុវត្តកម្មវិធី គម្រោង និងសកម្មភាពនានា សម្រាប់ការការពារ |
| ច. ទីតាំងរបស់គម្រោង |
| ឆ. អង្គការ ឬស្ថាប័នអ្នកអនុវត្តដែលបានស្នើ |
| ជ. ការត្រួតពិនិត្យថវិកា (ជាប្រាក់ដុល្លារអាមេរិក)<br>ចំនួនទឹកប្រាក់ដែលបានស្នើសុំពីមូលនិធិ<br>វិភាគទានរបស់រដ្ឋសមាជិក |
| ឈ. គម្រោងពេលវេលា |

| ញ. ការពិពណ៌នាសង្ខេបស្តីពីគម្រោង *មិនឱ្យលើសពី ២០០ ពាក្យឡើយ* |
|---|
| **ការដាក់ពាក្យសុំ** |
| **១. សាវតារ និងសនិទានភាព** *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| **២. គោលបំណង និងលទ្ធផលរំពឹងទុក** *មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| **៣. សកម្មភាព** *មិនឱ្យលើសពី ៥០០ ពាក្យឡើយ* |
| **៤. ការគ្រប់គ្រង និងការអនុវត្តគម្រោង** |
| ៤.ក. ការចូលរួមរបស់សហគមន៍ *មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| ៤.ខ. អង្គការអនុវត្តគម្រោង |
| ៤.គ. ដៃគូ |
| ៤.ឃ. ការត្រួតពិនិត្យតាមដានការរាយការណ៍ និងការវាយតម្លៃ:<br>*មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| **៥. ការកសាងសមត្ថភាព និរន្តរភាព និងប្រសិទ្ធភាពរយៈពេលវែងរបស់គម្រោង** |
| ៥.ក. ការកសាងសមត្ថភាព *មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| ៥.ខ. និរន្តរភាព *មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| ៥.គ. ផលប៉ះពាល់ផ្សេងៗ *មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| **៦. កាលវិភាគ និងគម្រោងថវិកា** |
| ៦.ក. កាលវិភាគ |
| ៦.ខ. គម្រោងថវិកា |
| **៧. ព័ត៌មានសម្រាប់ទំនាក់ទំនង** |
| ៧.ក. រដ្ឋសមាជិកដែលដាក់សំណើ |
| ៧.ខ. មនុស្សសម្រាប់ទំនាក់ទំនងដើម្បីឆ្លើយឆ្លងព័ត៌មាន |
| ៧.គ. ស្ថាប័ន ឬអង្គការដែលទទួលខុសត្រូវអនុវត្តគម្រោង |
| **៨. ហត្ថលេខា** |

ទម្រង់ICH-05 ខាងក្រោមនេះអាចទាញយកបានតាមរយៈគេហទំព័រ **http://www.unesco.org/culture/ich/en/forms/** ឬអាចរកបានតាមរយៈការស្នើសុំទៅលេខាធិការដ្ឋានតាមអ៊ីមែល : ich@unesco.org ទូរស័ព្ទលេខ : + ៣៣ (0) ១ ៤៥ ៦៨ ៤៥ ១៩ ទូរសារលេខ: + ៣៣ (0)១ ៤៥ ៦៨ ៥៧ ៥២

| **ICH-05- ការស្នើសុំជំនួយរៀបចំ ដើម្បី បកស្រាយលំអិតនូវការតែងតាំងឱ្យចុះឈ្មោះនៅក្នុងបញ្ជីអភិរក្សជាបន្ទាន់** |
|---|
| គម្របឯកសារ |
| ក. ឈ្មោះបេតិកភណ្ឌ *មិនឱ្យលើសពី ២០០ តួអក្សរឡើយ* |
| ខ. រដ្ឋសមាជិកដែលដាក់សំណើ |
| គ. អង្គការ ឬស្ថាប័នដែលទទួលខុសត្រូវ |
| ឃ. មនុស្សសម្រាប់ទំនាក់ទំនងដើម្បីឆ្លើយឆ្លងព័ត៌មាន |
| ង. ចំនួននៃប្រាក់ជំនួយដែលបានស្នើសុំ (គិតជាប្រាក់ដុល្លារអាមេរិក) |
| ច. គម្រោងពេលវេលាសម្រាប់រៀបចំការតែងតាំង |
| **ការដាក់ពាក្យសុំ** |
| ១. ឈ្មោះរបស់បេតិកភណ្ឌពាក់ព័ន្ធ :  *មិនឱ្យលើសពី ២០០ ពាក្យឡើយ* |
| ២. ការពិពណ៌នាពីបេតិកភណ្ឌ និងតម្រូវការដើម្បីអភិរក្សជាបន្ទាន់ : *មិនឱ្យលើសពី ២០០ ពាក្យឡើយ* |
| ៣. អត្តសញ្ញាណនៃសហគមន៏ ក្រុម បុគ្គលដែលពាក់ព័ន្ធ និងទីតាំងរបស់ពួកគេ |
| ៤. ទីតាំងភូមិសាស្ត្រ និងលេខរៀងរបស់បេតិកភណ្ឌ |
| ៥. វិស័យដែលតំណាងដោយបេតិកភណ្ឌនោះ |
| ៦. ការប្រមើលមើលពីដំណើរការរៀបចំ *មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| ៧. វិធានការរៀបចំដែលត្រូវគាំទ្រផ្នែកហិរញ្ញវត្ថុដោយសំណើនេះ : *មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| **៨. ហត្ថលេខា** |

ទម្រង់ICH-06 ខាងក្រោមនេះអាចទាញយកបានតាមរយៈគេហទំព័រ **http://www.unesco.org/culture/ich/en/forms/** ឬអាចរកបានតាមរយៈការស្នើសុំទៅលេខាធិការដ្ឋានតាមអ៊ីមែល : ich@unesco.org ទូរស័ព្ទលេខ : + ៣៣ (0) ១ ៤៥ ៦៨ ៤៥ ១៩ ទូរសារលេខ: + ៣៣ (0)១ ៤៥ ៦៨ ៥៧ ៥២

| **ICH-06- ការស្នើសុំជំនួយរៀបចំដើម្បីបកស្រាយលំអិតពីសំណើនៃកម្មវិធី គម្រោង ឬសកម្មភាពដែលត្រូវជ្រើសរើសថាបានឆ្លុះបញ្ចាំងយ៉ាងល្អបំផុតនូវគោលការណ៍ និងគោលបំណងរបស់អនុសញ្ញា** |
|---|
| គម្របឯកសារ |
| ក. ឈ្មោះកម្មវិធី គម្រោង ឬសកម្មភាព *មិនឱ្យលើសពី ២០០ តួអក្សរឡើយ* |
| ខ. រដ្ឋសមាជិកដែលដាក់សំណើ |
| គ. អង្គការ ឬស្ថាប័នដែលទទួលខុសត្រូវ |
| ឃ. មនុស្សសម្រាប់ទំនាក់ទំនងដើម្បីឆ្លើយឆ្លងព័ត៌មាន |
| ង. ចំនួននៃប្រាក់ជំនួយដែលបានស្នើសុំ (គិតជាប្រាក់ដុល្លារអាមេរិក) |
| ច. គម្រោងពេលវេលា |
| **ការដាក់ពាក្យសុំ** |
| ១. ឈ្មោះ កម្មវិធី គម្រោង ឬសកម្មភាព : *មិនឱ្យលើសពី ២០០ តួអក្សរឡើយ* |
| ២. ការពិពណ៌នាសង្ខេបពីកម្មវិធី គម្រោង ឬសកម្មភាព :<br>*មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| ៣. អត្តសញ្ញាណនៃសហគមន៍ ក្រុម ឬបុគ្គលដែលពាក់ព័ន្ធ និងទីតាំងរបស់ពួកគេ |
| ៤. វិសាលភាពភូមិសាស្ត្ររបស់កម្មវិធី គម្រោង ឬ សកម្មភាព<br>☐ ថ្នាក់ជាតិ<br>☐ ថ្នាក់អនុតំបន់<br>☐ ថ្នាក់តំបន់<br>ថ្នាក់អន្តរជាតិ (រួមទាំងតំបន់ដែលមិនមានភូមិសាស្ត្រជាប់គ្នា) |
| ៥. ស្ថានភាពនៃកម្មវិធី គម្រោង ឬសកម្មភាព (ពិនិត្យមើល)<br>☐ បានចប់សព្វគ្រប់ហើយ<br>☐ កំពុងដំណើរការ<br>☐ ស្ថិតក្នុងគម្រោង |
| ៦. ការប្រមើលមើលពីដំណើរការរៀបចំ : *មិនឱ្យលើសពី ២៥០ ពាក្យឡើយ* |
| ៧. វិធានការរៀបចំ ដើម្បីទទួលបានការគាំទ្រផ្នែកហិរញ្ញបេតិកភណ្ឌតាមរយៈការស្នើសុំនេះ : *មិនលើសពី ២៥០ ពាក្យ។* |
| **៨. ហត្ថលេខា :** |

ទម្រង់ ICH-07 ខាងក្រោមនេះអាចទាញយកបានតាមរយៈគេហទំព័រ **http://www.unesco.org/culture/ich/en/forms/** ឬអាចរកបានតាមរយៈការស្នើសុំទៅលេខាធិការដ្ឋានតាមអ៊ីមែល : ich@unesco.org ទូរស័ព្ទលេខ : + ៣៣ (0) ១ ៤៥ ៦៨ ៤៥ ១៩ ទូរសារលេខ : + ៣៣ (0)១ ៤៥ ៦៨ ៥៧ ៥២

**ICH-07- ការផ្តល់សិទ្ធិ និងការចុះបញ្ជីឯកសារដែលបានដាក់ស្នើជាផ្នែកមួយនៃសំណុំឯកសារតែងតាំងសម្រាប់ចុះឈ្មោះក្នុងបញ្ជីអភិរក្សជាបន្ទាន់ ឬបញ្ជី ឈ្មោះអ្នកតំណាង**

ឈ្មោះបេតិកភណ្ឌដែលបានតែងតាំង: ................................................

រដ្ឋសមាជិកដែលដាក់សំណើ: ........................................................

១ ខ្ញុំជាភាគីហត្ថលេខី:.................................... ប្រគល់ជូនអង្គការយូណេស្កូ នូវសិទ្ធិមិនផ្តាច់មុខក្នុងការប្រើប្រាស់ បោះពុម្ពផ្សព្វផ្សាយ ផលិតសារជាថ្មី ចែកចាយ ដាក់តាំងបង្ហាញ ទំនាក់ទំនង ធ្វើឱ្យមានជាសាធារណៈ ជាភាសាណាមួយ ក្រោម រូបភាពណា មួយ និងតាមមធ្យោបាយណាមួយ រួមទាំងតាមប្រព័ន្ធអេឡិចត្រូនិចសម្ភារដូចខាងក្រោម ទាំងមូល ឬជាផ្នែក។ ខ្ញុំសូមប្រគល់សិទ្ធិនេះ ជូនអង្គការយូណេស្កូ ដោយគ្មានការកែប្រែ ដោយមិនកំណត់ពេលវេលា និងប្រើបានជុំវិញពិភព លោក។

រូបថត (បន្ថែមចំនួនតារាងស្របទៅតាមចំនួនរូបថត)

| លេខសម្គាល់ | ចំណងជើង | កាលបរិច្ឆេទ | ឈ្មោះអ្នកថតរូប | ព័ត៌មានក្រេឌីត © (ឆ្នាំ) .......... |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

ឯកសារសោតទស្សន៍ (បន្ថែមចំនួនតារាងស្របទៅតាមចំនួនរូបថត)

| លេខសម្គាល់ | ចំណងជើង ភាពយន្ត ឬ ខ្សែអាត់ | កាលបរិច្ឆេទ | ឈ្មោះអ្នកផលិត | ព័ត៌មានក្រេឌីត © (ឆ្នាំ) ដោយ.... |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

២ ខ្ញុំសូមផ្តល់បន្ថែមដល់អង្គការ យូណេស្កូ នូវសិទ្ធិមិនផ្តាច់មុខក្នុងការផ្តល់អាជ្ញាប័ណ្ណបន្តទៅតតិយជនផ្សេងទៀតដើម្បីប្រើប្រាស់សម្ភារទាំងមូល ឬជាផ្នែកសម្រាប់តែក្នុងការប្រើប្រាស់ជាព័ត៌មានអប់រំ ឬ ព័ត៌មានសាធារណៈប៉ុណ្ណោះ។

៣ សិទ្ធិទាំងនេះនឹងត្រូវបានផ្តល់ជូនស្ថិតក្រោមល័ក្ខខ័ណ្ឌដែល ខ្លឹមសារខុសៗគ្នាមានចែងខាងលើ ឬ ព័ត៌មានសមមូលរបស់ខ្លួនត្រូវបានផ្តល់ជូនប្រសិនបើ ឬនៅពេលដែលសម្ភារនោះត្រូវបានប្រើ ប្រាស់។

៤ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមានសិទ្ធិប្រគល់សិទ្ធិទាំងអស់ដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ១ និងទី២ នៃកិច្ចព្រមព្រៀងនេះពាក់ព័ន្ធទៅនឹងសម្ភារដែល:

ក. មិនមានការរំលោភបំពាន ឬរំលោភច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ ឬអាជ្ញាប័ណ្ណណាមួយដែលមានចែង។

ខ. មិនមានការរំលោភបំពាន ឬ រំលោភច្បាប់ស្តីពីការអនុវត្តតាមប្រពៃណីផ្សេងៗដែលគ្រប់គ្រងលើការប្រើប្រាស់បេតិកភណ្ឌ ដែលបានធ្វើការពិពណ៌នា ឬ បានដាក់បញ្ចូល ហើយមិនមានការបាត់បង់ផ្នែកណាមួយ និងមិនមានការបង្ខូចកេរ្តិ៍ឈ្មោះ ឬការប្រមាទអ្វី ឡើយ។

កាលបរិច្ឆេទ: ........................................................................

ឈ្មោះ:...................................................................................

អាសយដ្ឋាន:

...........................................................................................

ហត្ថលេខា:..............................................................................

សូមចុះហត្ថលេខារួចផ្ញើច្បាប់ដើមពីរច្បាប់ទៅយូណេស្កូ និងទុកខ្លួនឯងមួយច្បាប់។

ទម្រង់ ICH-09 ខាងក្រោមនេះអាចទាញយកបានតាមរយៈគេហទំព័រ **http://www.unesco.org/culture/ich/en/forms/** ឬ អាចរកបានតាមរយៈការស្នើសុំទៅលេខាធិការដ្ឋានតាមអ៊ីមែល : ich@unesco.org ទូរស័ព្ទ លេខ : + ៣៣ (0) ១ ៤៥ ៦៨ ៤៥ ១៩   ទូរសារលេខ: + ៣៣ (0)១ ៤៥ ៦៨ ៥៧ ៥២

| |
|---|
| **ICH-07-**<br>ការស្នើសុំការឯកភាពធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់សេវាប្រឹក្សាដល់គណៈកម្មាធិការ |
| **១. ឈ្មោះអង្គការ :** |
| **២. អាសយដ្ឋានរបស់អង្គការ :** |
| **៣. ប្រទេសដែលអង្គការធ្វើសកម្មភាព**<br>□ ថ្នាក់ជាតិ<br>□ ថ្នាក់អន្តរជាតិ (*សូមបញ្ជាក់*)<br>□ ទូទាំងពិភពលោក<br>□ ទ្វីបអាហ្វ្រិក<br>□ រដ្ឋអារ៉ាប់រួម<br>□ ទ្វីបអាស៊ី និងប៉ាស៊ីហ្វិក<br>□ ទ្វីបអឺរ៉ុប និងអាមេរិកខាងជើង<br>□ អាមេរិកឡាទីន និងតំបន់ការ៉ាអ៊ីប<br>*សូមរៀបរាប់ពីប្រទេសដំបូងដែលអង្គការបានចុះធ្វើសកម្មភាព* |
| ៤. កាលបរិច្ឆេទនៃការបង្កើត ឬ រយៈពេលប្រហាក់ប្រហែលនៃវត្តមាន របស់អង្គការ។ |
| **៥. គោលបំណងរបស់អង្គការ** *មិនឱ្យលើសពី ៣៥០ ពាក្យឡើយ* |
| **៦.សកម្មភាពរបស់អង្គការក្នុងមុខងារអភិរក្សបេតិកភណ្ឌវប្បធមិអរូបិយ** |
| ៦.ក. វិស័យដែលអង្គការធ្វើសកម្មភាព<br>□ ប្រពៃណី តាមរយៈការនិយាយ និងការសម្តែងចេញ<br>□ សិល្បៈសម្តែង<br>□ ការអនុវត្តក្នុងសង្គម ពិធីបុណ្យតាមសាសនា ពិធីបុណ្យផ្សេងៗ<br>□ ចំណេះដឹង និងការអនុវត្តពាក់ព័ន្ធទៅនឹងធម្មជាតិ និងសាកលលោក<br>□ សិប្បកម្មបែបប្រពៃណី<br>□ វិស័យផ្សេងៗទៀត _ សូមបញ្ជាក់ |
| ៦.ខ. សកម្មភាពការពារជាបឋមដែលអង្គការបានចូលរួម |
| □ អត្តសញ្ញាណ ចងក្រងឯកសារ ការស្រាវជ្រាវ (*រាប់បញ្ចូលទាំង ការធ្វើបញ្ជីសារពើភ័ណ្ឌ*)<br>□ ការថែរក្សា ការអភិរក្ស<br>□ ការផ្សព្វផ្សាយ ការអភិវឌ្ឍ<br>□ ការផ្ទេរ ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ<br>□ ការធ្វើឱ្យរស់ឡើងវិញ<br>□ វិធានការណ៍អភិរក្សផ្សេងៗទៀត— សូមបញ្ជាក់ |
| ៦.គ. ការពណ៌នាអំពីសកម្មភាពរបស់អង្គការ : *មិនលើសពី ១៥០ ពាក្យ។* |
| **ពិសោធន៍របស់អង្គការក្នុងការសហការជាមួយនឹងសហគមន៍ ក្រុម និងអ្នកអនុវត្តបេតិកភណ្ឌវប្បធមិអរូបិយ :**<br>*មិនលើសពី ៣៥០ ពាក្យ។* |
| ៨. ការរៀបចំឯកសារនៃសមត្ថភាពប្រតិបត្តិការរបស់អង្គការ :<br>*សូមបញ្ជាក់ អំពីសមត្ថភាពប្រតិបត្តិការរបស់អង្គការជាមួយនឹងឯកសារសមស្រប ដែលមានរៀបរាប់នៅក្នុងកថាខ័ណ្ឌ ៩៤ នៃគោលការណ៍ណែនាំសម្រាប់ ប្រតិបត្តិការ។* |
| ៨.ក. សមាជិកភាព និងបុគ្គលិក *សូមបញ្ជូនមកនូវឯកសារគាំទ្រ* |
| ៨.ខ. បុគ្គលិកលក្ខណៈស្របច្បាប់ដែលត្រូវបានគេទទួលស្គាល់<br>*សូមបញ្ជូនមកនូវឯកសារគាំទ្រ* |
| ៨.គ. រយៈពេលនៃវត្តមាន និងសកម្មភាពផ្សេងៗ<br>*សូមបញ្ជូនមកនូវឯកសារគាំទ្រ* |
| **៩. មនុស្សសម្រាប់ទំនាក់ទំនង ដើម្បីសាកសួរព័ត៌មាន** |
| **១០. ហត្ថលេខា:** |

# មហាសន្និបាតរដ្ឋភាគីនៃអនុសញ្ញាស្តីអំពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ បញ្ញត្តិនៃនីតិវិធី

*ត្រូវបានអនុម័តដោយមហាសន្និបាតនៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន (ទីក្រុងប៉ារីស ពីថ្ងៃទី២៧ ដល់ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦) បានធ្វើវិសោធនកម្ម នៅក្នុងសម័យប្រជុំលើកទីពីររបស់ខ្លួន (ទីក្រុងប៉ារីស ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨)*

## I. ការចូលរួម

### បញ្ញត្តិ ១– ការចូលរួម

គ្រប់អ្នកតំណាងរបស់រដ្ឋភាគីនៃអនុសញ្ញាសម្រាប់អភិរក្សបេតិកភណ្ឌវប្ប-ធម៌អរូបិយ (ហៅថា “អនុសញ្ញា”) ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៅ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ ដែលមានរួមទាំងសិទ្ធិក្នុងការបោះឆ្នោតនៅក្នុង ការងាររបស់មហាសន្និបាតនៃរដ្ឋភាគី (ហៅថា “អង្គសន្និបាត”។

### បញ្ញត្តិ ២ –អ្នកតំណាង និងអ្នកសង្កេតការណ៍

២.១ អ្នកតំណាងនៃរដ្ឋសមាជិករបស់អង្គការ យូណេស្កូ ដែលមិនមែនជាភាគី នៃអនុសញ្ញានេះ និងគណៈកម្មការអ្នកសង្កេតការណ៍អចិន្ត្រៃយ៍របស់អង្គការ យូណេស្កូ អាចចូលរួមក្នុងការងាររបស់អង្គសន្និបាតបានក្នុង នាមជាអ្នកសង្កេតការណ៍ដោយមិនមានសិទ្ធិបោះឆ្នោត និងស្ថិតក្រោម បញ្ញត្តិ ៧.៣។

២.២ អ្នកតំណាងរបស់អង្គការសហប្រជាជាតិ និងអង្គការដទៃទៀតស្ថិតក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ និងអង្គការអន្តររដ្ឋាភិបាលផ្សេងទៀតដែលបានសម្រេចក្នុងកិច្ចព្រមព្រៀងតំណាងឱ្យគ្នាទៅវិញទៅមកជាមួយនឹងអង្គការ យូណេស្កូ ព្រមទាំងយល់ព្រមធ្វើជាអ្នកសង្កេតការណ៍អន្តររដ្ឋាភិបាល និងបណ្ដាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដែលបានអញ្ជើញឱ្យចូលរួមដោយអគ្គនាយកអាចចូលរួមនៅក្នុងការងាររបស់អង្គសន្និបាតបាន ដោយមិនមានសិទ្ធិបោះឆ្នោត និងស្ថិតនៅក្រោមបញ្ញត្តិ ៧.៣។

## II. ការរៀបចំអង្គសន្និបាត

### បញ្ញត្តិ ៣_ ការបោះឆ្នោតជ្រើសរើសមន្ត្រី

អង្គសន្និបាតត្រូវជ្រើសរើសប្រធានមួយរូប អនុប្រធានមួយ ឬ ច្រើនរូប និងអ្នករៀបចំរបាយការណ៍មួយរូប។

### បញ្ញត្តិ ៤_ ភារកិច្ចរបស់ប្រធានអង្គសន្និបាត

៤.១ បន្ថែមពីលើការអនុវត្តអំណាចដែលគេបានផ្តល់ជូនស្របតាមបញ្ញត្តិនានា ដែលមានចែងប្រធានអង្គសន្និបាត គឺជាអ្នកបើក និងបិទកិច្ចប្រជុំពេញអង្គនីមួយៗនៃអង្គសន្និបាត។ ប្រធានត្រូវដឹកនាំការពិភាក្សា ធានាការគោរព តាមបញ្ញត្តិទាំងនេះ សម្រុះសម្រួលផ្តល់សិទ្ធិឱ្យមានមតិ លើកសំណួរ សម្រាប់ធ្វើការបោះឆ្នោត និងការប្រកាសសេចក្តីសម្រេច។ ប្រធានត្រូវសម្រេចលើបញ្ហានៃនីតិវិធីរៀបចំកិច្ចប្រជុំផ្លូវការ ដោយគោរពទៅតាម បញ្ញត្តិដែលមានចែង ហើយត្រូវគ្រប់គ្រងលើរបាយការណ៍អង្គប្រជុំ និងថែរក្សានីតិវិធី។ ប្រធានមិនត្រូវចូលរួមបោះឆ្នោតឡើយ ប៉ុន្តែគាត់អាចណែនាំ ឱ្យសមាជិកដទៃទៀតដែលនៅក្រោមបង្គាប់របស់គាត់ឱ្យបោះឆ្នោតជំនួស គាត់បាន។

៤.២ ប្រសិនបើប្រធានអវត្តមានក្នុងអំឡុងពេលនៃកិច្ចប្រជុំ ឬ ពេលណាមួយ គាត់នឹងត្រូវជំនួសដោយអនុប្រធានមួយរូប។ អនុប្រធានដែលដើរតួជា ប្រធានរូបនោះ មានអំណាច និងភារកិច្ចដូចប្រធានដែរ។

## III. ដំណើរការការងារ

### បញ្ញត្តិ ៥_ លក្ខណៈសាធារណៈនៃកិច្ចប្រជុំ

កិច្ចប្រជុំផ្សេងៗត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែមានការសម្រេចពីអង្គសន្និបាត។

### បញ្ញត្តិ ៦_ ចំនួនកូរ៉ុម

៦.១. ចំនួនកូរ៉ុមត្រូវមានរដ្ឋសមាជិកភាគច្រើនដូចមានចែងក្នុងបញ្ញត្តិ ១ ហើយបានធ្វើជាតំណាងនៅក្នុងអង្គសន្និបាត។

៦.២. អង្គសន្និបាតមិនអាចសម្រេចលើបញ្ហាណាមួយបានឡើយ លុះត្រាតែមានវត្តមានកូរ៉ុមគ្រប់ចំនួន។

## បញ្ញត្តិ ៧_ នីតិវិធី និងរយៈពេលកំណត់សម្រាប់អ្នកបញ្ចេញមតិ

៧.១. ប្រធានអង្គសន្និបាតត្រូវហៅអ្នកថ្លែងសុន្ទរកថាតាមលំដាប់លំដោយ ដោយក្នុងនោះមានការបង្ហាញពីគោលបំណងរបស់គេដែលត្រូវនិយាយ។

៧.២. ដើម្បីជាភាពងាយស្រួលក្នុងការពិភាក្សា ប្រធានអាចកំណត់ពេលវេលាដែលអនុញ្ញាតឱ្យអ្នកឡើងមានប្រសាសន៍ម្នាក់ម្តងៗ។

៧.៣. ត្រូវមានការព្រមព្រៀងរបស់ប្រធាននៅពេលដែលអ្នកសង្កេតការណ៍ម្នាក់ចង់មានប្រសាសន៍នៅក្នុងអង្គសន្និបាត។

## បញ្ញត្តិ ៨_ បញ្ហានៃនីតិវិធី

៨.១ ក្នុងអំឡុងពេលនៃការពិភាក្សា ប្រតិភូអាចលើកពីបញ្ហានៃនីតិវិធី ហើយបញ្ហានៃនីតិវិធីនេះត្រូវធ្វើការសម្រេចភ្លាមៗដោយប្រធានអង្គសន្និបាត។

៨.២ ការប្តឹងជំទាស់អាចនឹងធ្វើឡើងប្រឆាំងទៅនឹងការសម្រេចរបស់ប្រធានអង្គសន្និបាត។ ការបណ្តឹងជំទាស់បែបនេះត្រូវយកមកធ្វើការបោះឆ្នោតភ្លាមៗ ហើយការសម្រេចរបស់ប្រធានត្រូវព្យួរមួយរយៈរហូតទាល់តែមានការ សម្រេចជាថ្មីដោយមតិភាគច្រើននៃប្រតិភូដែលមានវត្តមាន និងបានចូលរួម បោះឆ្នោត។

## បញ្ញត្តិ ៩_ សំណើនីតិវិធី

៩.១. ក្នុងអំឡុងពេលពិភាក្សា ប្រតិភូអាចស្នើសុំធ្វើការព្យួរ ឬ ផ្អាកកិច្ចប្រជុំ ឬ ផ្អាក ឬ បញ្ចប់កិច្ចពិភាក្សា។

៩.២. សំណើបែបនេះត្រូវដាក់ឱ្យបោះឆ្នោតភ្លាមៗ។ ស្ថិតក្រោមបញ្ញត្តិ ៨.១ សំណើបែបនេះមានអាទិភាពតាមលំដាប់ដូចខាងក្រោម លើសពីសំណើ និងសំណើនីតិវិធីផ្សេងៗទៀតនៅមុនកិច្ចប្រជុំ :

ក. ការពន្យារកិច្ចប្រជុំ

ខ. ការផ្អាកកិច្ចប្រជុំ

គ. ការផ្អាកកិច្ចពិភាក្សាអំពីសំណួរដែលជាប្រធានបទនៃកាពិភាក្សា

ឃ. ការបិទកិច្ចពិភាក្សាស្តីពីសំណួរ ដែលជាប្រធានបទនៃកាពិភាក្សា។

**បញ្ញត្តិទី ១០_ ភាសាផ្លូវការ**

១០.១ ភាសាផ្លូវការក្នុងអង្គសន្និបាតអាចជាភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្សី និងភាសាអេស្ប៉ាញ។

១០.២ សុន្ទរកថាដែលថ្លែងនៅក្នុងអង្គសន្និបាតជាភាសាណាមួយ ក្នុងចំណោមភាសាផ្លូវការត្រូវបកប្រែទៅជាភាសាផ្សេងៗ។

១០.៣ អ្នកថ្លែងសុន្ទរកថាអាចប្រើភាសាផ្សេងណាមួយក៏បាន ប៉ុន្តែត្រូវរៀបចំ ដោយខ្លួនឯងនូវអ្នកបកប្រែសុន្ទរកថារបស់ខ្លួនទៅជាភាសាមួយក្នុង ចំណោមភាសាផ្លូវការទាំងនោះ។

**បញ្ញត្តិ ១១_ សេចក្តីសម្រេច និងការធ្វើវិសោធនកម្ម**

១១.១ ពង្រាងសេចក្តីសម្រេច និងវិសោធនកម្ម គឺអាចស្នើឡើងដោយអ្នកចូលរួម យោងតាមបញ្ញត្តិ ១ ហើយត្រូវបញ្ជូនជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋានរបស់អង្គសន្និបាតដែលនឹងចែកចាយច្បាប់ចម្លងទៅដល់អ្នក ចូលរួមគ្រប់រូប។

១១.២ ជាបញ្ញត្តិទូទៅ ពង្រាងសេចក្តីសម្រេច ឬ វិសោធនកម្មមិនអាចលើកមកពិភាក្សា ឬ ដាក់ឱ្យបោះឆ្នោតបានឡើយ លុះត្រាតែពង្រាងនោះត្រូវបានចែកចាយសមស្របជាមុនទៅដល់ដៃអ្នកចូលរួមទាំងអស់ជាភាសាផ្លូវការ របស់អង្គសន្និបាត។

**បញ្ញត្តិ១២_ ការបោះឆ្នោត**

១២.១ អ្នកតំណាងនៃរដ្ឋនីមួយៗដែលមានចែងនៅក្នុងបញ្ញត្តិ ១ ត្រូវមានសម្លេង ឆ្នោតមួយនៅក្នុងអង្គសន្និបាត។

១២.២ ស្ថិតក្រោមបទបញ្ញត្តិនៃបញ្ញត្តិ ៦.២ និងបញ្ញត្តិ ១៧ សេចក្តីសម្រេចត្រូវ ធ្វើឡើងដោយមតិភាគច្រើននៃរដ្ឋភាគី ដែលមានវត្តមាន និងបានបោះឆ្នោត លើកលែងតែបទបញ្ញត្តិមួយចំនួននៅក្នុងបញ្ញត្តិ១២.៣ប៉ុណ្ណោះ។

១២.៣ សេចក្តីសម្រេចពាក់ព័ន្ធទៅនឹងចំនួននៃវិភាគទាន ក្នុងទម្រង់ជាភាគរយដូចគ្នាដែលអាចអនុវត្តបានសម្រាប់រដ្ឋភាគីទាំងអស់ ដែលមិនទាន់បាន ធ្វើសេចក្តីប្រកាសដូចមានចែងនៅក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ២៦ នៃអនុសញ្ញា ត្រូវតែកំណត់ដោយសម្លេងឆ្នោតភាគច្រើននៃរដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោតដែលខ្លួនមិនទាន់បានធ្វើសេចក្តីប្រកាសដូចខាងលើ។

១២.៤ សម្រាប់គោលបំណងនៃបញ្ញត្តិនានាដែលមានការលើកឡើងថា "រដ្ឋមានវត្តមាន និងបានបោះឆ្នោត " គឺសំដៅទៅលើរដ្ឋទាំងឡាយដែលបោះឆ្នោតយល់ព្រម ឬ មិនយល់ព្រម។ ចំពោះរដ្ឋណាដែលបោះឆ្នោតអនុបវាទ ត្រូវចាត់ទុកថាមិនបានបោះឆ្នោត។

១២.៥ ជាទូទៅ ការបោះឆ្នោតត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់អភិរក្សបេតិកភណ្ឌវប្បធមិអរូបិយប៉ុណ្ណោះ (ហៅថា “គណៈកម្មាធិការ”)

១២.៦ នៅពេលដែលលទ្ធផលនៃការបោះឆ្នោតដោយលើកដៃមិនមានភាពច្បាស់លាស់ ពេលនោះប្រធានអង្គសន្និបាតត្រូវរៀបចំបោះឆ្នោតជាលើក ទីពីរ ដោយការហៅឈ្មោះតែម្តង។ ការបោះឆ្នោតដោយហៅឈ្មោះនឹងត្រូវធ្វើឡើងផងដែរ ក្នុងករណីដែលមានការស្នើសុំពីប្រតិភូលើសពី ២ក្រុម នៅមុនពេលធ្វើការបោះឆ្នោត និងសម្រាប់តែសេចក្តីសម្រេចដូចបានលើកឡើងក្នុងបញ្ញត្តិ ១២.៣។

១២.៧ ប្រសិនបើមានការស្នើសុំឱ្យធ្វើវិសោធនកម្មទៅលើសំណើមួយ ការធ្វើវិសោធនកម្មនោះត្រូវដាក់ឱ្យបោះឆ្នោតមុន។ ប្រសិនបើមានការស្នើឱ្យធ្វើវិសោធនកម្មពីរ ឬ ច្រើនទៅលើសំណើមួយ អង្គសន្និបាតត្រូវធ្វើការបោះឆ្នោតជាមុនទៅលើវិសោធនកម្មណាដែលប្រធានអង្គសន្និ

បាតយល់ឃើញថា ត្រូវការលុបផ្នែកផ្សេងច្រើនបន្ថែមទៀតចេញពីសំណើដើម ហើយបន្ទាប់មកបោះឆ្នោតទៅលើវិសោធនកម្មដែលត្រូវការលុបចោលបន្ទាប់មួយទៀត ហើយធ្វើបន្តបន្ទាប់មករហូតទាល់តែវិសោធនកម្មទាំងអស់ត្រូវបានដាក់ឱ្យបោះឆ្នោតសម្រេច។

១២.៨ ប្រសិនបើការធ្វើវិសោធនកម្មមួយចំណុច ឬ លើសពីនេះ ត្រូវបានអនុម័ត បន្ទាប់មកសំណើដែលបានធ្វើវិសោធនកម្មនោះត្រូវដាក់ឱ្យបោះឆ្នោតជារួមតែម្តង។

១២.៩ ការស្នើច្បាប់នឹងត្រូវចាត់ទុកថាជាការធ្វើវិសោធនកម្មទៅលើសំណើមួយ ប្រសិនបើត្រូវបន្ថែម លុបចោល ឬពិនិត្យកែសម្រួលផ្នែកណាមួយនៃសំណើនោះ។

## IV. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាល ស្តីពី ការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ

### បញ្ញត្តិ ១៣_ ការបែងចែកទៅតាមទីតាំងភូមិសាស្ត្រ

១៣.១ ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ ត្រូវធ្វើឡើងដោយឈរលើមូលដ្ឋាននៃក្រុមឈរឈ្មោះបោះឆ្នោតរបស់អង្គការ យូណេស្កូ ដូចបានកំណត់ដោយអង្គមហាសន្និបាតអង្គការ យូណេស្កូ នៅឯកិច្ចប្រជុំចុង ក្រោយបំផុតរបស់ខ្លួន ដោយក្នុងនោះគេបានដឹងថា "ក្រុម V" បង្កើតឡើង ចេញពីក្រុមពីរដាច់ដោយឡែកពីគ្នាសម្រាប់រដ្ឋអាហ្វ្រិក និងរដ្ឋអារ៉ាប់។

១៣.២ (i) ចំនួនអាសនៈនៅក្នុងគណៈកម្មាធិការដែលមានសមាជិកចំនួន ១៨រូប ត្រូវធ្វើការបែងចែកក្នុងចំណោមក្រុមអ្នកឈរឈ្មោះបោះឆ្នោត តាមសមាមាត្រនៃចំនួនរដ្ឋភាគីមកពីក្រុមនីមួយៗ ដោយធ្វើយ៉ាងណាឱ្យក្រោយពីការបែងចែកនេះមានអាសនៈ យ៉ាងតិច២ ត្រូវបានបែងចែកទៅឱ្យក្រុមនីមួយៗ។

(ii) នៅពេលចំនួនរដ្ឋសមាជិកនៃគណៈកម្មាធិការឡើងដល់ ២៤ នោះអាសនៈត្រូវបែងចែកនៅកន្លែងបោះឆ្នោតនីមួយៗក្នុងចំណោមក្រុមអ្នកឈរឈ្មោះបោះឆ្នោតតាមសមាមាត្រនៃចំនួនរដ្ឋភាគីមកពីក្រុមនីមួយៗដោយធ្វើយ៉ាងណាឱ្យ ក្រោយពីការបែងចែកនេះមានអាសនៈយ៉ាងតិច ៣ ត្រូវបានបែងចែកទៅឱ្យ ក្រុមនីមួយៗ។

### បញ្ញត្តិ ១៤_ នីតិវិធីសម្រាប់ការបង្ហាញបេក្ខភាពការធ្វើបទបង្ហាញដល់គណៈ កម្មាធិការ

១៤.១ លេខាធិការដ្ឋានត្រូវសួរទៅរដ្ឋភាគី យ៉ាងហោចណាស់ ៣ខែ មុននឹង បើកអង្គសន្និបាត ថាតើពួកគេចង់ឈរឈ្មោះក្នុងការបោះឆ្នោតធ្វើជា សមាជិកគណៈកម្មាធិការដែរ ឬ អត់។ ប្រសិនបើគេចង់ឈរឈ្មោះនោះ បេក្ខភាពនៃរដ្ឋភាគីត្រូវបញ្ជូនទៅកាន់លេខាធិការដ្ឋាន យ៉ាងហោច ណាស់ឱ្យបាន ៦សប្តាហ៍ មុនពេលបើកអង្គសន្និបាត ។

១៤.២ យ៉ាងហោចណាស់ ៤សប្តាហ៍ មុនពេលបើកអង្គសន្និបាត លេខាធិការដ្ឋាន ត្រូវផ្ញើបញ្ជីឈ្មោះបេក្ខជនបណ្តោះអាសន្ននៃរដ្ឋភាគីទៅរដ្ឋភាគីទាំងអស់ ដោយបង្ហាញពីក្រុមអ្នកឈរឈ្មោះដែលជាក្រុមរបស់គេនិងចំនួនអាសនៈដែលត្រូវបំពេញនៅក្នុងក្រុមអ្នកឈរឈ្មោះនីមួយៗ។ លេខាធិការដ្ឋានក៏ត្រូវតែផ្តល់ផងដែរ នូវព័ត៌មានស្តីអំពីការផ្តល់វិភាគទានដែលមិនអាចខ្វះបាន និងវិភាគទានស្ម័គ្រចិត្តចូលក្នុងមូលនិធិអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយដែលត្រូវធ្វើឡើងដោយបេក្ខជនម្នាក់ៗ។ បញ្ជីបេក្ខភាពនឹងត្រូវត្រួតពិនិត្យកែសម្រួលឡើងវិញ ប្រសិនបើមានការចាំបាច់។

១៤.៣ ការបង់ប្រាក់វិភាគទានចាំបាច់ ឬ ដោយស្ម័គ្រចិត្តចូលទៅក្នុងមូលនិធិ (ក្នុងគោលបំណងបង្ហាញបេក្ខភាពដល់គណៈកម្មាធិការ) គឺមិនត្រូវឱ្យហួសពីរយៈពេលមួយសប្តាហ៍មុនពេលបើកអង្គសន្និបាតឡើយ។

## បញ្ញត្តិ ១៥_ ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ

១៥.១ ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការត្រូវធ្វើឡើងដោយការ បោះឆ្នោតជាសម្ងាត់ លើកលែងតែបេក្ខជននៅក្នុងតំបន់ភូមិសាស្ត្រដែលបានបែងចែកមានចំនួនស្មើ ឬ តិចជាងចំនួនអាសនៈដែលត្រូវចូលកាន់ក្នុងករណីបែបនេះ បេក្ខជននឹងត្រូវប្រកាសជាប់ឆ្នោតដោយមិនចាំបាច់ធ្វើការបោះឆ្នោតឡើយ។

១៥.២ មុនពេលការបោះឆ្នោតចាប់ផ្តើម ប្រធានអង្គសន្និបាតត្រូវតែងតាំងអ្នករាប់សន្លឹកឆ្នោតចំនួនពីររូបដែលជ្រើសចេញពីចំណោមប្រតិភូដែលមានវត្តមាន ហើយប្រធានត្រូវប្រគល់ជូនអ្នកទាំងពីររូបនោះនូវបញ្ជីឈ្មោះរបស់រដ្ឋភាគីដែលមានសិទ្ធិបោះឆ្នោត និងបញ្ជីឈ្មោះរដ្ឋភាគីជាបេក្ខជនទាំងអស់។ ប្រធានត្រូវប្រកាសពីចំនួនអាសនៈដែលត្រូវចូលកាន់។

១៥.៣ លេខាធិការដ្ឋានត្រូវរៀបចំស្រោមសំបុត្រមួយសម្រាប់ក្រុមប្រតិភូនីមួយៗ ដែលមានសិទ្ធិបោះឆ្នោតដោយមិនចាំបាច់មានសញ្ញាចំណាំ ឬ សន្លឹកឆ្នោត ដាច់ដោយឡែកពីគ្នាឡើយសម្រាប់ក្រុមអ្នកឈរឈ្មោះនីមួយៗ។ សន្លឹកឆ្នោតសម្រាប់ក្រុមអ្នកឈរឈ្មោះបោះឆ្នោតនីមួយត្រូវមានឈ្មោះរដ្ឋភាគីជាបេក្ខជនទាំងអស់នៅក្នុងក្រុមអ្នកឈរឈ្មោះនោះ។

១៥.៤ គណៈប្រតិភូម្នាក់ៗត្រូវបោះឆ្នោតដោយគូសរង្វង់ជុំវិញឈ្មោះរដ្ឋភាគីដែលខ្លួនចង់បោះឆ្នោតឱ្យ។

១៥.៥ អ្នករាប់សន្លឹកឆ្នោតត្រូវប្រមូលស្រោមសំបុត្រដែលមានសន្លឹកឆ្នោតនៅខាងក្នុងពីក្រុមប្រតិភូនីមួយៗ ហើយរាប់សន្លឹកឆ្នោតនោះ ក្រោមការត្រួតពិនិត្យពីប្រធានអង្គសន្និបាត។

១៥.៦ ចំពោះស្រោមសំបុត្រដែលមិនមានសន្លឹកឆ្នោតត្រូវចាត់ទុកជាមោឃៈ។

១៥.៧ សន្លឹកឆ្នោតដែលមានគូសរង្វង់លើឈ្មោះច្រើនជាងចំនួនអាសនៈដែលមាន ហើយមិនមានការបញ្ជាក់ច្បាស់លាស់ពីបំណងរបស់អ្នកបោះឆ្នោត នឹងត្រូវចាត់ទុកថាគ្មានសុពលភាព។

១៥.៨ ការរាប់សន្លឹកឆ្នោតរបស់ក្រុមអ្នកឈរឈ្មោះនីមួយៗត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នា។ អ្នករាប់សន្លឹកឆ្នោតត្រូវបើកស្រោមសំបុត្រម្ដងមួយៗ ហើយដាក់សន្លឹកឆ្នោតនោះទៅតាមក្រុមអ្នកឈរឈ្មោះនីមួយៗ។ សន្លឹកឆ្នោតដែលបោះឱ្យរដ្ឋភាគីជាបេក្ខជន ត្រូវកត់ចូលក្នុងបញ្ជីដែលបានរៀបចំទុកសម្រាប់គោលបំណងនេះ។

១៥.៩ ប្រធានអង្គសន្និបាតត្រូវប្រកាសអំពីបេក្ខជនជាប់ឆ្នោតដែលទទួលបាន ចំនួនសន្លឹកឆ្នោតច្រើនបំផុតរហូតដល់ចំនួនអាសនៈដែលមាន។ ប្រសិនបើមានបេក្ខជនពីរ ឬ ច្រើនរូបទទួលបានសម្លេងឆ្នោតស្មើគ្នា ហើយជាលទ្ធផលបេក្ខជនមានចំនួនច្រើនជាងចំនួនអាសនៈដែលមានពេលនោះ ត្រូវធ្វើការបោះឆ្នោតដោយសម្ងាត់ជាលើកទីពីរ ដើម្បីកាត់បន្ថយចំនួនបេក្ខជនដែលទទួលបានសម្លេងឆ្នោតស្មើគ្នានោះ។ ប្រសិនបើក្នុងការបោះឆ្នោតលើកទីពីរ មានបេក្ខជនពីរ ឬ ច្រើនរូបទទួលបានសម្លេងឆ្នោតស្មើគ្នា ប្រធានអង្គសន្និបាតត្រូវរៀបចំការចាប់ឆ្នោតជ្រើសរើសយកឈ្មោះបេក្ខជនដែលត្រូវជាប់ឆ្នោត។

១៥.១០ នៅពេលការរាប់សន្លឹកឆ្នោតបានបញ្ចប់ ប្រធានអង្គសន្និបាតត្រូវប្រកាសលទ្ធផលនៃសន្លឹកឆ្នោតដាច់ដោយឡែកពីគ្នាសម្រាប់ក្រុមឈរ ឈ្មោះ បោះឆ្នោតនីមួយៗ។

## V. លេខាធិការដ្ឋាន នៃអង្គសន្និបាត

### បញ្ញត្តិ ១៦_ លេខាធិការដ្ឋាន

១៦.១ ប្រធានអង្គការ យូណេស្កូ ឬ អ្នកតំណាងរបស់ខ្លួនមានសិទ្ធិចូលរួមក្នុង ការងារនៃអង្គសន្និបាត ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតឡើយ។ គាត់អាចធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរទៅកាន់ អង្គសន្និបាតស្តីអំពីចម្ងល់ណាមួយដែលត្រូវធ្វើការពិភាក្សា។

១៦.២ អគ្គនាយកអង្គការ យូណេស្កូ ត្រូវតែងតាំងមន្ត្រីមួយរូបនៅក្នុងលេខាធិការដ្ឋានរបស់អង្គការ យូណេស្កូ ឱ្យបំពេញតួនាទីលេខានៅក្នុងអង្គសន្និបាត និងតែងតាំងមន្ត្រីផ្សេងៗទៀតដែលត្រូវរួមគ្នាបង្កើតលេខាធិការដ្ឋាននៃ អង្គសន្និបាត។

១៦.៣ (i) លេខាធិការដ្ឋានត្រូវទទួលបកប្រែ និងចែកចាយឯកសារផ្លូវការទាំងអស់ដែលសរសេរជា៦ភាសាផ្លូវការឱ្យរួចរាល់យ៉ាងតិច ៣០ថ្ងៃ មុនពេលបើកសម័យប្រជុំនៃអង្គសន្និបាត។

(ii) លេខាធិការដ្ឋានត្រូវរៀបចំសម្រាប់ការងារបកប្រែកិច្ចពិភាក្សានិងអនុវត្តរាល់តួនាទីចាំបាច់ផ្សេងៗដើម្បីឱ្យការងារក្នុងអង្គសន្និបាត ដំណើការដោយរលូន។

## VI. ការអនុម័ត ការធ្វើវិសោធនកម្ម និងការព្យួរបញ្ញត្តិនៃនីតិវិធី

### បញ្ញត្តិ ១៧_ ការអនុម័ត

អង្គសន្និបាតត្រូវអនុម័តបញ្ញត្តិនៃនីតិវិធីរបស់ខ្លួន តាមរយៈសេចក្តីសម្រេចធ្វើឡើងនៅក្នុងកិច្ចប្រជុំពេញអង្គផ្អែកលើសម្លេងភាគច្រើន ២/៣ នៃអ្នកតំណាងរបស់រដ្ឋដែលមានវត្តមាន និងបានបោះឆ្នោត។

### បញ្ញត្តិ ១៨_ ការធ្វើវិសោធនកម្ម

អង្គសន្និបាត អាចធ្វើវិសោធនកម្មទៅលើបញ្ញត្តិនៃនីតិវិធីទាំងនេះ តាមរយៈសេចក្តីសម្រេចធ្វើឡើងដោយកិច្ចប្រជុំពេញអង្គ ផ្អែកលើសម្លេងភាគច្រើន ២/៣ នៃអ្នកតំណាងរបស់រដ្ឋដែលមានវត្តមាន និងបានបោះឆ្នោត។

## បញ្ញត្តិ ១៩_ ការព្យួរ

មហាសន្និបាត អាចព្យួរការដាក់ឱ្យអនុវត្តនូវបញ្ញត្តិនៃនីតិវិធីណាមួយក្នុងចំណោមបញ្ញត្តិនៃនីតិវិធីទាំងនេះបាន លើកលែងតែនៅពេលណាដែលនីតិវិធីនេះ ត្រូវបានបង្កើតជាបទបញ្ញត្តិ នៅក្នុងអនុសញ្ញា ដោយសេចក្តីសម្រេចក្នុងកិច្ចប្រជុំពេញអង្គ ផ្អែកលើសម្លេងភាគច្រើន ២/៣ នៃរដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត។

# គណៈកម្មាធិការអន្តររដ្ឋាភិបាលស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ បញ្ញត្តិនៃនីតិវិធី

បានអនុម័តដោយគណៈកម្មាធិការនៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន (នៅ ប្រទេសអាល់ហ្សេរី ថ្ងៃទី១៨ និង ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៦) និងបានធ្វើវិសោធន កម្មនៅក្នុងសម័យប្រជុំវិសាមញ្ញរបស់ខ្លួន (នៅទីក្រុង សូហ្វីយ៉ា ប្រទេសប៊ុលហ្គារី ពីថ្ងៃទី១៨ ដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨)

រាល់ល័ក្ខខ័ណ្ឌទាំងអស់ដែលបានប្រើនៅក្នុងបញ្ញត្តិទាំងនេះដើម្បីតែងតាំងបុគ្គល ឱ្យបំពេញភារកិច្ច អាណត្តិ ឬ មុខងារគឺក្នុងគោលបំណងបញ្ជាក់ថា បុរស និងស្ត្រីទាំងឡាយមានសិទ្ធិស្មើៗគ្នាតាមផ្លូវច្បាប់ ក្នុងការចូលកាន់តួនាទី ឬ អាសនៈណាមួយ ពាក់ព័ន្ធនឹងការផ្តល់ជូនដែលមានចែង។

## I. សមាជិកភាព

### បញ្ញត្តិ ១_ គណៈកម្មាធិការអន្តររដ្ឋាភិបាលស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌ អរូបិយ (មាត្រា ៥ នៃអនុសញ្ញា)

គណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់អភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ ដែលគេស្គាល់ថាជា 'គណៈកម្មាធិការបេតិកភណ្ឌអរូបិយ' ហើយដែលគេហៅកាត់ថា 'គណៈកម្មាធិការ' ត្រូវបានបង្កើតឡើងដោយរដ្ឋភាគីនៃអនុសញ្ញាដែលបានជាប់ឆ្នោតស្របតាមមាត្រា ៥ នៃអនុសញ្ញាសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ អរូបិយ ដែលហៅកាត់ថា 'អនុសញ្ញា'។

## II. សម័យប្រជុំ

### បញ្ញត្តិ ២_ សម័យប្រជុំសាមញ្ញ និងវិសាមញ្ញ

២.១ គណៈកម្មាធិការត្រូវជួបគ្នាយ៉ាងហោចណាស់ម្តងក្នុង ១ឆ្នាំ នៅក្នុងសម័យ ប្រជុំសាមញ្ញ។

២.២ គណៈកម្មាធិការត្រូវជួបគ្នាក្នុងសម័យប្រជុំវិសាមញ្ញតបតាមសំណើយ៉ាងតិច២/៣នៃរដ្ឋសមា ជិក។

### បញ្ញត្តិ ៣_ ការកោះប្រជុំ

៣.១ សម័យប្រជុំរបស់គណៈកម្មាធិការត្រូវរៀបចំឡើងដោយប្រធានគណៈ កម្មាធិការ ដែលហៅថា 'ប្រធាន' ដោយមានការប្រឹក្សាជាមួយអគ្គនាយក អង្គការ យូណេស្កូ ដែលហៅថា 'អគ្គនាយក'។

៣.២ អគ្គនាយកត្រូវជូនដំណឹងទៅរដ្ឋសមាជិកនៃគណៈកម្មាធិការអំពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈបណ្តោះអាសន្ននៃសម័យប្រជុំនីមួយៗ ដោយមិនឱ្យតិចជាង ៦០ថ្ងៃជាមុន ប្រសិនបើវាជាសម័យប្រជុំសាមញ្ញ ហើយរយៈពេលមិនតិចជាង ៣០ថ្ងៃជាមុនសម្រាប់សម័យប្រជុំសាមញ្ញ និង ៣០ថ្ងៃជាមុន សម្រាប់សម័យប្រជុំវិសាមញ្ញ។

៣.៣ នៅពេលជាមួយគ្នានោះ អគ្គនាយកត្រូវជូនដំណឹងទៅរដ្ឋ អង្គការ និងបុគ្គលទាំងឡាយដែលបានលើកឡើងនៅក្នុងបញ្ញត្តិ ៦, ៧ និង ៨ អំពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈបណ្តោះអាសន្ននៃសម័យប្រជុំនីមួយៗ។

## បញ្ញត្តិ ៤_ កាលបរិច្ឆេទ និងទីកន្លែងនៃសម័យប្រជុំ

៤.១ នៅក្នុងសម័យប្រជុំនីមួយៗ ដោយមានការប្រឹក្សាជាមួយអគ្គនាយក គណៈកម្មាធិការត្រូវកំណត់នូវកាលបរិច្ឆេទ និងទីកន្លែងសម្រាប់សម័យប្រជុំលើកក្រោយទៀត។ ប្រសិនបើមានការចាំបាច់ ការិយាល័យអាចកែប្រែកាលបរិច្ឆេទ និង/ឬ ទីកន្លែង ដោយត្រូវប្រឹក្សាជាមួយអគ្គនាយក។

៤.២ រដ្ឋសមាជិកនីមួយៗនៃគណៈកម្មាធិការ អាចអញ្ជើញគណៈកម្មាធិការឱ្យរៀបចំសម័យប្រជុំសាមញ្ញនៅក្នុងទឹកដីរបស់ខ្លួនបាន។

៤.៣ នៅក្នុងការកំណត់ទីកន្លែងសម្រាប់សម័យប្រជុំសាមញ្ញលើកក្រោយ គណៈកម្មាធិការត្រូវពិចារណាទៅលើតម្រូវការ ក្នុងការធានាឱ្យមានការផ្លាស់ប្តូរវេនស្មើភាពក្នុងចំណោមតំបន់ផ្សេងគ្នានៅលើពិភពលោក។

## III. អ្នកចូលរួម

## បញ្ញត្តិ ៥_ ក្រុមប្រតិភូ

៥.១ រដ្ឋសមាជិកនីមួយៗរបស់គណៈកម្មាធិការត្រូវតំណាងដោយប្រតិភូមួយរូប ដែលអាចមានការជួយ ពីអ្នកជំនួសទីប្រឹក្សា និងអ្នកជំនាញ។

៥.២ រដ្ឋសមាជិកនៃគណៈកម្មាធិការ ត្រូវជ្រើសរើសអ្នកតំណាងរបស់ខ្លួន ជាមនុស្សដែលមានសមត្ថភាពនៅក្នុងផ្នែកផ្សេងៗនៃបេតិកភណ្ឌវប្បធម៌អរូបិយ (មាត្រា ៦.៧ នៃអនុសញ្ញា)។

៥.៣ រដ្ឋសមាជិកនៃគណៈកម្មាធិការ ត្រូវបញ្ជូនបញ្ជីឈ្មោះ តួនាទី និងលក្ខណៈសម្បត្តិនៃអ្នកតំណាងរបស់ខ្លួនទៅលេខាធិការដ្ឋាន។

៥.៤ ដើម្បីធានាឱ្យមានការធ្វើជាតំណាងដោយសមត្ថភាព នៅក្នុងគណៈកម្មាធិការនៃតំបន់ភូមិសាស្ត្រផ្សេងៗគ្នា គណៈកម្មាធិការត្រូវបែងចែកចំនួនទឹកប្រាក់នៅក្នុងគម្រោងថវិការបស់ខ្លួន ដើម្បីគ្រប់គ្រងថ្លៃចំណាយ សម្រាប់ការចូលរួមរបស់អ្នកតំណាងនៃរដ្ឋសមាជិកពីប្រទេសកំពុងអភិវឌ្ឍនៅក្នុងសម័យប្រជុំ និង កិច្ចប្រជុំនៅក្នុងការិយាល័យរបស់ខ្លួន ប៉ុន្តែទឹកប្រាក់នោះគឺសម្រាប់តែអ្នកជំនាញផ្នែកបេតិកភណ្ឌវប្បធម៌អរូបិយប៉ុណ្ណោះ។ ប្រសិនបើគម្រោងថវិកានោះមានគ្រប់គ្រាន់ ប្រទេសកំពុងអភិវឌ្ឍដែលជាភាគីនៅក្នុងអនុសញ្ញា ប៉ុន្តែមិនមែនជាសមាជិកគណៈកម្មាធិការនោះក៏អាចទទួលបានជំនួយនោះដែរ ដោយជំនួយនោះផ្តល់ជូនតែអ្នក ជំនាញផ្នែកបេតិកភណ្ឌវប្បធម៌ អរូបិយប៉ុណ្ណោះ។

៥.៥ សំណើសុំជំនួយដើម្បីចូលរួមនៅក្នុងកិច្ចប្រជុំរបស់ការិយាល័យ និងរបស់គណៈកម្មាធិការត្រូវបញ្ជូនឱ្យដល់ដៃលេខាធិការដ្ឋានយ៉ាងតិច ៤សប្តាហ៍ មុនសម័យប្រជុំពាក់ព័ន្ធចាប់ផ្តើម។ ផ្អែកលើការសម្រេចរបស់គណៈកម្មាធិការ សំណើបែបនោះនឹងត្រូវធ្វើការពិចារណាផ្តល់ជូនតែក្នុងវង្វង់នៃធនធានដែលមានប៉ុណ្ណោះដើម្បីបង្កើនកម្រិតផលទុនជាតិសរុប (GNP) ក្នុងមនុស្សម្នាក់ៗរបស់រដ្ឋសមាជិកនីមួយៗនៃគណៈកម្មាធិការ។ តាមបញ្ញត្តិ មូលនិធិបេតិកភណ្ឌវប្បធម៌អរូបិយមិនផ្តល់ហិរញ្ញវត្ថុជូនអ្នកតំណាងលើស ពីម្នាក់ឡើយ សម្រាប់រដ្ឋមួយ។

## បញ្ញត្តិ ៦_ អង្គការដែលដើរតួនាទីនៅក្នុងការផ្តល់ប្រឹក្សាដល់គណៈកម្មាធិការ

អង្គការក្រៅរដ្ឋាភិបាលដែលសមត្ថភាពរបស់ខ្លួនត្រូវបានទទួលស្គាល់ ហើយដែលត្រូវបានទទួលយកសម្រាប់គោលបំណងនេះ ដោយមហាសន្និបាតស្របតាមលក្ខណវិនិច្ឆ័យដែលមហាសន្និបាតបានបង្កើតឡើង (មាត្រា ៩.១ នៃអនុសញ្ញានេះ) អាចចូលរួមនៅក្នុងអង្គប្រជុំគណៈកម្មាធិការបានក្នុងនាមជាអ្នកផ្តល់ប្រឹក្សា។

## បញ្ញាត្តិ ៧_ ការអញ្ជើញឱ្យចូលរួមផ្តល់ប្រឹក្សា

គណៈកម្មាធិការអាចអញ្ជើញស្ថាប័នសាធារណៈ ឬ ឯកជន ព្រមទាំងបុគ្គលឯកជនដែលសមត្ថភាពរបស់ពួកគេត្រូវបានទទួលស្គាល់តាមផ្នែកជាច្រើនពាក់ព័ន្ធ នឹងបេតិកភណ្ឌវប្បធម៌អរូបិយឱ្យចូលរួមក្នុង

សម័យប្រជុំរបស់ខ្លួនដើម្បីផ្តល់ប្រឹក្សាដល់ពួកគាត់អំពីបញ្ហាជាក់លាក់ផ្សេងៗ នៅពេលណាមួយ (មាត្រា ៨.៤ នៃអនុសញ្ញានេះ)។

**បញ្ញត្តិ ៨_ អ្នកចូលរួមផ្សេងៗទៀត**

៨.១ រដ្ឋភាគីនៃអនុសញ្ញា ដែលមិនមែនជាសមាជិករបស់គណៈកម្មាធិការ អាចចូលរួមនៅក្នុងសម័យ ប្រជុំ បានក្នុងនាមជាអ្នកសង្កេតការណ៍។

៨.២ រដ្ឋមិនមែនជាសមាជិកនៃអនុសញ្ញាដែលជារដ្ឋសមាជិករបស់អង្គការ យូណេស្កូ ឬ ជាសមាជិកអង្គការសហប្រជាជាតិ សមាជិកពាក់ព័ន្ធរបស់អង្គការ យូណេស្កូ អ្នកសង្កេតការណ៍អចិន្ត្រៃយ៍ប្រចាំនៅអង្គការយូណេស្កូ អ្នកតំណាងរបស់អង្គការសហប្រជាជាតិ និងអង្គការផ្សេងៗ នៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ អាចចូលរួមក្នុងសម័យប្រជុំរបស់គណៈកម្មាធិការបានក្នុងនាមជាអ្នកសង្កេតការណ៍។

៨.៣ គណៈកម្មាការអាចនឹងផ្តល់សិទ្ធិដល់អង្គការអន្តររដ្ឋាភិបាលមួយចំនួន បន្ថែមលើអ្វីដែលមានចែងនៅក្នុងបញ្ញត្តិ ៨.២ បូករួមទាំងស្ថាប័នសារ ធារណៈ ឬស្ថាប័នឯកជន ព្រមទាំងបុគ្គលឯកជនដែលសមត្ថភាពរបស់ពួកគេត្រូវបានទទួលស្គាល់នៅក្នុងវិស័យផ្សេងៗនៃ ICH ឱ្យចូលរួមនៅក្នុងសម័យប្រជុំរបស់ខ្លួន នៅពេលក្រោយទៀតក្នុងនាមជាអ្នកសង្កេតការណ៍តបតាមសំណើជាលាយលក្ខណ៍អក្សររបស់ពួកគេ។ គណៈកម្មាធិការអាចផ្តល់សិទ្ធិដល់ស្ថាប័ន អង្គការ ឬ បុគ្គលឯកជនទាំងនោះឱ្យចូលរួមនៅក្នុងសម័យប្រជុំមួយ ឬ ច្រើនក្នុងចំណោមសម័យប្រជុំរបស់ខ្លួន ដោយមិនរើសអើងតាមរយៈការប្រើប្រាស់សិទ្ធិរបស់ខ្លួនទៅកំណត់ចំនួនអ្នកតំណាងក្នុង អង្គការ ឬស្ថាប័នណាមួយឡើយ។

៨.៤ អគ្គនាយក ត្រូវអញ្ជើញអង្គភាពណាមួយ ដែលគណៈកម្មាធិការធ្លាប់បានផ្តល់សិទ្ធិឱ្យចូលរួមស្របតាមបញ្ញត្តិ ៨.២ និង ៨.៣។

៨.៥ កិច្ចប្រជុំជាសាធារណៈរបស់គណៈកម្មាធិការ ត្រូវបើកចំហចំពោះសាធារណជនដើម្បីឱ្យពួកគេចូលរួមក្នុងនាមជាទស្សនិកជនទៅតាមទំហំទី កន្លែងដែលអាចទទួលពួកគេបាន។

## IV. របៀបវារៈ

**បញ្ញត្តិ ៩_ របៀបវារៈបណ្តោះអាសន្ន**

៩.១ អគ្គនាយក ត្រូវរៀបចំរបៀបវារៈបណ្តោះអាសន្នសម្រាប់សម័យប្រជុំរបស់គណៈកម្មាធិការ (មាត្រា ១០.២ នៃអនុសញ្ញា)។

៩.២ របៀបវារៈបណ្តោះអាសន្នសម្រាប់សម័យប្រជុំសាមញ្ញរបស់គណៈកម្មាធិការ រួមមាន :

ក. គ្រប់សំណួរទាំងអស់ ដែលគណៈកម្មាធិការបានសម្រេចដាក់បញ្ចូលនៅក្នុងសម័យប្រជុំលើកមុន

ខ. គ្រប់សំណួរទាំងអស់ដែលលើកឡើងដោយរដ្ឋភាគីរបស់គណៈកម្មាធិការ

គ. គ្រប់សំណួរទាំងអស់ដែលលើកឡើងដោយរដ្ឋសមាជិកនៃអនុសញ្ញា ប៉ុន្តែមិនមែនជាសមាជិករបស់គណៈកម្មាធិការ

ឃ. គ្រប់សំណួរទាំងអស់ដែលលើកឡើងដោយអគ្គនាយក។

៩.៣ របៀបវារៈបណ្តោះអាសន្ននៃសម័យប្រជុំវិសាមញ្ញ ត្រូវដាក់បញ្ចូលតែសំណួរទាំងឡាយ ដែលសម័យប្រជុំបានលើកយកមកការពិចារណាប៉ុណ្ណោះ។

### បញ្ញត្តិ ១០_ ការអនុម័តរបៀបវារៈ

នៅដើមដំបូងនៃសម័យប្រជុំនីមួយៗ គណៈកម្មាធិការត្រូវអនុម័តរបៀបវារៈរបស់ខ្លួន សម្រាប់សម័យប្រជុំនោះ។

### បញ្ញត្តិ ១១_ ការកែប្រែ ការលុបចោល និងការបន្ថែមខ្លឹមសារថ្មី

គណៈកម្មាធិការអាចនឹងធ្វើការកែប្រែ លុបចោល ឬ បន្ថែមខ្លឹមសារថ្មីទៅលើរបៀបវារៈដែលបានអនុម័តរួច ប្រសិនបើមានការសម្រេចពីសម្លេងភាគច្រើន ២/៣ នៃសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត។

## V. ការិយាល័យ

### បញ្ញត្តិ ១២_ ការិយាល័យ

១២.១ ការិយាល័យរបស់គណៈកម្មាធិការត្រូវមាន ប្រធាន អនុប្រធានមួយ ឬ ច្រើនរូប អ្នករៀបចំរបាយការណ៍ ស្របតាមគោលការណ៍នៃការតំណាង តាមតំបន់ភូមិសាស្ត្រប្រកបដោយគោលការណ៍ស្មើភាព។

១២.២ ការិយាល័យត្រូវសម្របសម្រួលការងាររបស់គណៈកម្មាធិការ និងកំណត់ កាលបរិច្ឆេទ ពេលម៉ោង និងលំដាប់លំដោយនៃកិច្ចការប្រជុំការងារ។ ការិយាល័យនេះត្រូវអនុវត្តតួនាទីផ្សេងទៀតដែលគណៈកម្មាធិការប្រគល់ឱ្យ ហើយសមាជិកផ្សេងទៀតរបស់ការិយាល័យនេះត្រូវជួយប្រធានក្នុងការអនុវត្តតួនាទីរបស់ គាត់។

១២.៣ ដោយមានការអញ្ជើញពីប្រធានរបស់ខ្លួន ការិយាល័យត្រូវធ្វើការជួបប្រជុំ គ្នាឱ្យបានញឹកញាប់តាមតម្រូវការ។ នៅចន្លោះសម័យប្រជុំ ការិយាល័យនេះត្រូវជួបប្រជុំគ្នានៅឯទីស្នាក់ការកណ្ដាលរបស់អង្គការ យូណេស្កូ។

១២.៤ កិច្ចប្រជុំត្រូវបើកចំហសម្រាប់សមាជិកគណៈកម្មាធិការ និងរដ្ឋសមាជិកឱ្យចូលរួមក្នុងនាមជាអ្នកសង្កេតការណ៍ លើកលែងតែមានការសម្រេចពីការិយាល័យ។ អ្នកសង្កេតការណ៍អាចនិយាយទៅកាន់ការិយាល័យបាន តែក្នុងករណីដែលមានការយល់ព្រមជាមុនពីប្រធានការិយាល័យ ប៉ុណ្ណោះ។

## បញ្ញត្តិ ១៣_ ការបោះឆ្នោត

១៣.១ នៅពេលបញ្ចប់សម័យប្រជុំសាមញ្ញនីមួយៗ គណៈកម្មាធិការត្រូវបោះឆ្នោតជ្រើសរើសក្នុងចំណោមសមាជិករបស់ខ្លួន ដែលអាណត្តិរបស់ពួកគាត់នៅបន្តរហូតដល់សម័យប្រជុំសាមញ្ញលើកក្រោយទៀត ដើម្បីធ្វើជាប្រធានមួយរូប អនុប្រធានមួយ ឬ ច្រើនរូប និងអ្នករៀបចំរបាយការណ៍មួយរូប ឱ្យកាន់តួនាទីក្នុងការិយាល័យរហូតដល់ចុងបញ្ចប់នៃសម័យប្រជុំនោះ។

១៣.២ ក្នុងករណីជាសម័យប្រជុំវិសាមញ្ញ គណៈកម្មាធិការត្រូវបោះឆ្នោតជ្រើសរើសប្រធាន មួយរូប អនុប្រធានមួយ ឬ ច្រើនរូប និងអ្នករៀបចំរបាយការណ៍មួយរូបឱ្យកាន់តួនាទីនៅក្នុងការិយាល័យរហូតដល់ចុងបញ្ចប់នៃ សម័យប្រជុំនោះ។

១៣.៣ ប្រធាន អនុប្រធាន និងអ្នករៀបចំរបាយការណ៍មានសិទ្ធិឈរឈ្មោះក្នុង ការបោះឆ្នោតថ្មីទៀតដើម្បីបន្តកាន់តួនាទីក្នុងការិយាល័យសម្រាប់អាណត្តិ ទី ២ ក្នុងករណីប្រទេសដែលខ្លួនតំណាងឱ្យនោះនៅបន្តធ្វើរដ្ឋសមាជិកនៃគណៈកម្មាធិការ យ៉ាងតិចរហូតដល់ចប់អាណត្តថ្មីរបស់ការិយាល័យនេះ។

១៣.៤ នៅក្នុងការបោះឆ្នោតជ្រើសរើសបុគ្គលិកការិយាល័យ គណៈកម្មាធិការត្រូវ ពិចារណាទៅលើសេចក្តីត្រូវការដើម្បីធានាការធ្វើជាតំណាងតាមតំបន់ភូមិសាស្ត្រប្រកបដោយសមភាព ហើយធ្វើយ៉ាងណាឱ្យមានតុល្យភាពក្នុង ចំណោមផ្នែកផ្សេងនៃបេតិកភណ្ឌវប្បធម៌អរូបិយ។

## បញ្ញត្តិ ១៤_ ភារកិច្ចរបស់ប្រធានការិយាល័យ

១៤.១ បន្ថែមពីលើអំណាចដែលបានផ្តល់ជូនប្រធានតាមរយៈបញ្ញត្តិទាំងនេះ ប្រធានគឺជាអ្នកបើក និងបិទកិច្ចប្រជុំពេញអង្គរបស់គណៈកម្មាធិការ។ ប្រធានត្រូវដឹកនាំកិច្ចពិភាក្សា ធានាការគោរពបញ្ញត្តិទាំងនេះ បែងចែកសិទ្ធិ និងឡើងមានប្រសាសន៍ ដាក់សំណួរដើម្បីធ្វើការបោះឆ្នោត និងប្រកាសសេចក្តីសម្រេច។ ប្រធានការិយាល័យធ្វើការសម្រេចលើបញ្ហានៃនីតិវិធី ហើយដោយផ្អែកលើបញ្ញត្តិទាំងនេះ ប្រធានត្រូវឃ្លាំមើលពីដំណើរការប្រកបដោយភាពរលូន និងការរក្សានីតិវិធី។ ប្រធានមិនមានសិទ្ធិបោះឆ្នោតឡើយ ប៉ុន្តែគាត់អាចណែនាំសមាជិកផ្សេងនៅក្នុងក្រុមប្រតិភូរបស់គាត់ឱ្យបោះឆ្នោតជំនួសគាត់បាន។ គាត់ត្រូវអនុវត្តនូវគ្រប់ភារកិច្ចទាំងអស់ដែលគណៈកម្មាធិការដាក់ជូនគាត់។

១៤.២ អនុប្រធានមួយរូបដែលដើរតួជាប្រធានការិយាល័យត្រូវមានអំណាច និងភារកិច្ចស្មើនឹងប្រធានការិយាល័យដែរ។

១៤.៣ ប្រធាន ឬ អនុប្រធានរបស់ស្ថាប័នសាខារបស់គណៈកម្មាធិការត្រូវមាន ភារកិច្ចដូចគ្នានៅក្នុងស្ថាប័នផ្សេងៗទៀតដែលប្រធាន ឬ អនុប្រធានត្រូវបានអញ្ជើញឱ្យធ្វើជាអធិបតីក្នុងនាមជាប្រធាន ឬ អនុប្រធានរបស់គណៈកម្មាធិការនេះ។

## បញ្ញត្តិ ១៥_ ការចូលជំនួសតួនាទីរបស់ប្រធាន

១៥.១ ប្រសិនបើប្រធានមិនអាចអនុវត្តតួនាទីនៅក្នុងសម័យប្រជុំណាមួយរបស់គណៈកម្មាធិការ ឬ ការិយាល័យ ឬផ្នែកណាមួយ ពេលនោះមុខងាររបស់ គាត់នឹងត្រូវអនុវត្តដោយអនុប្រធាន។

១៥.២ ប្រសិនបើអ្នករៀបចំរបាយការណ៍ឈប់ធ្វើជាតំណាងឱ្យរដ្ឋសមាជិកនៃគណៈកម្មាធិការ ឬ មិនអាចបំពេញភារកិច្ចរហូតដល់ចប់អាណត្តិរបស់គាត់ នៅក្នុងការិយាល័យដោយហេតុផលណាមួយ ពេលនោះគាត់នឹងត្រូវដាក់ជំនួសដោយអនុប្រធានមួយរូបក្រោយពីធ្វើការប្រឹក្សាជាមួយគណៈកម្មាធិការចំពោះអាណត្តិដែល នៅសល់នោះ។

១៥.៣ ប្រធានត្រូវផ្អាកការអនុវត្តមុខងាររបស់ខ្លួនចំពោះកិច្ចការទាំងអស់ដែលពាក់ព័ន្ធនឹងផ្នែកណាមួយនៃបេតិកភណ្ឌវប្បធម៌អរូបិយដែលមានវត្តមាននៅក្នុងទឹកដីនៃរដ្ឋភាគី ដែលខ្លួនគាត់មានសញ្ជាតិនៅក្នុងរដ្ឋនោះ។

**បញ្ញត្តិ ១៦_ ការចូលជំនួសតួនាទីរបស់អ្នករៀបចំរបាយការណ៍**

១៦.១ ប្រសិនបើអ្នករៀបចំរបាយការណ៍មិនអាចអនុវត្តតួនាទីក្នុងសម័យប្រជុំណាមួយរបស់គណៈកម្មាធិការ ឬ ការិយាល័យ ឬ ផ្នែកណាមួយ ពេលនោះមុខងាររបស់គាត់នឹងត្រូវអនុវត្តដោយអនុប្រធានមួយរូប។

១៦.២ ប្រសិនបើអ្នករៀបចំរបាយការណ៍នោះ ឈប់ធ្វើជាតំណាងឱ្យរដ្ឋសមាជិករបស់គណៈកម្មាធិការ ឬ មិនអាចបញ្ចប់អាណត្តិរបស់គាត់នៅក្នុងការិយាល័យដោយហេតុផលណាមួយគាត់នឹងត្រូវបានជំនួសតំណែងដោយអនុប្រធាន សម្រាប់ពេលវេលាសេសសល់នៃអាណត្តិនៅក្នុងការិយាល័យ បន្ទាប់ពីមានការប្រឹក្សាជាមួយគណៈកម្មាធិការ។

## VI. *ការដំណើរការការងារ*

**បញ្ញត្តិ ១៧_ ចំនួនកូរ៉ុម**

១៧.១ នៅក្នុងកិច្ចប្រជុំពេញអង្គ ចំនួនកូរ៉ុមត្រូវមានរដ្ឋសមាជិកភាគច្រើនរបស់ គណៈកម្មាធិការ។

១៧.២ នៅក្នុងកិច្ចប្រជុំរបស់ស្ថាប័នសាខា ចំនួនកូរ៉ុមត្រូវមានរដ្ឋភាគច្រើនដែលជាសមាជិករបស់ស្ថាប័នដែលពាក់ព័ន្ធនោះ។

១៧.៣ ទាំងគណៈកម្មាធិការ និងស្ថាប័នសាខារបស់ខ្លួនមិនអាចធ្វើសេចក្ដីសម្រេចទៅលើបញ្ហាណាមួយឡើយ លើកលែងតែមានវត្តមានគ្រប់ចំនួនកូរ៉ុមនោះ។

**បញ្ញត្តិ ១៨_ កិច្ចប្រជុំសាធារណៈ**

កិច្ចប្រជុំត្រូវរៀបចំឡើងជាសាធារណៈ លើកលែងតែមានការសម្រេចពីគណៈកម្មាធិការ។ ថ្នាក់ការិយាល័យមិនអាចព្យួរបញ្ញត្តិនេះបានឡើយ។

**បញ្ញត្តិ ១៩_កិច្ចប្រជុំជាឯកជន**

១៩.១ នៅក្នុងកាលៈទេសៈពិសេស គណៈកម្មាធិការនឹងសម្រេចរៀបចំកិច្ចប្រជុំ ជាលក្ខណៈឯកជន ដោយក្នុងនោះគណៈកម្មាធិការនឹងកំណត់មនុស្សដែលត្រូវមានវត្តមាន បន្ថែមពីលើអ្នកតំណាងរបស់រដ្ឋសមាជិក។

១៩.២ សេចក្តីសម្រេចណាមួយ ធ្វើឡើងដោយគណៈកម្មាធិការនៅក្នុងកិច្ចប្រជុំលក្ខណៈឯកជន ត្រូវធ្វើការបង្ហាញជាលាយលក្ខណ៍អក្សរនៅក្នុងកិច្ចប្រជុំ ជាសាធារណៈលើកក្រោយៗទៀត។

១៩.៣ នៅក្នុងកិច្ចប្រជុំលក្ខណៈឯកជនទីមួយៗ គណៈកម្មាធិការត្រូវសម្រេចថា តើរបាយការណ៍សង្ខេប និងឯកសារការងារនៃកិច្ចប្រជុំនោះត្រូវ ឬ មិនត្រូវបោះពុម្ពផ្សាយ។ ឯកសារដែលប្រមូលមកពីកិច្ចប្រជុំលក្ខណៈឯកជនត្រូវបើកចំហដល់សាធារណៈជនក្រោយអំឡុងពេល២០ ឆ្នាំ។

## បញ្ញត្តិ ២០_ ស្ថានប័នផ្តល់ប្រឹក្សាបណ្តោះអាសន្ន

២០.១ ជាបណ្តោះអាសន្ន គណៈកម្មាការអាចនឹងបង្កើតស្ថាប័នផ្តល់ប្រឹក្សា បណ្តោះអាសន្នដែលខ្លួនយល់ថា មានការចាំបាច់ដើម្បីអនុវត្តកិច្ចការរបស់ខ្លួន (មាត្រា៨.៣ នៃអនុសញ្ញា)។

២០.២ គណៈកម្មាធិការត្រូវកំណត់ការចងក្រង និងឯកសារគោលដែលពាក់ព័ន្ធនានា (រាប់បញ្ចូលទាំងអាណត្តិ និងរយៈពេលរបស់ករិយាល័យ) នៃស្ថាប័នផ្តល់ប្រឹក្សាបណ្តោះអាសន្នបែបនេះនៅក្នុងអំឡុងពេលដែលស្ថាប័ននោះ នៅមានវត្តមាននៅឡើយ។

២០.៣ ស្ថាប័នផ្តល់ប្រឹក្សាបណ្តោះអាសន្នទីមួយៗត្រូវបោះឆ្នោតជ្រើសរើសប្រធានរបស់ខ្លួន ហើយបើចាំបាច់ត្រូវជ្រើសរើសអ្នករៀបចំរបាយការណ៍របស់ខ្លួនផងដែរ។

២០.៤ ក្នុងការតែងតាំងសមាជិករបស់ស្ថាប័នផ្តល់ប្រឹក្សាបណ្តោះអាសន្ន ចាំបាច់ត្រូវធ្វើការពិចារណាសមស្របទៅលើការធានាឱ្យមានការតំណាងប្រកប ដោយសមភាពសម្រាប់តំបន់ផ្សេងៗគ្នាទូទាំងពិភពលោក។

## បញ្ញត្តិ ២១_ ស្ថាប័នសាខា

២១.១ គណៈកម្មាធិការ អាចនឹងបង្កើតស្ថាប័នសាខាដែលខ្លួនយល់ថាចាំបាច់ ដើម្បីដំណើរការការងារ របស់ខ្លួន។

២១.២ គណៈកម្មាធិការត្រូវកំណត់ការចងក្រង និងឯកសារគោលដែលពាក់ព័ន្ធនានា (រាប់បញ្ចូលទាំងអាណត្តិ និងរយៈពេលរបស់ករិយាល័យ) នៃស្ថាប័នផ្តល់ប្រឹក្សាបណ្តោះអាសន្នបែបនេះ នៅក្នុងអំឡុងពេលស្ថាប័ននោះនៅមានវត្តមាននៅឡើយ។ ស្ថាប័នទាំងនេះអាចបង្កើតឡើងតែក្នុងចំណោមរដ្ឋសមាជិកនៃគណៈកម្មាធិការប៉ុណ្ណោះ។

២១.៣ ស្ថាប័នសាខានីមួយៗត្រូវបោះឆ្នោតជ្រើសរើសប្រធានរបស់ខ្លួន ហើយបើចាំបាច់ត្រូវជ្រើសរើសអនុប្រធាន និងអ្នករៀបចំរបាយការណ៍របស់ខ្លួនផងដែរ។

២១.៤ ក្នុងការតែងតាំងសមាជិករបស់ស្ថាប័នផ្តល់ប្រឹក្សាបណ្តោះអាសន្ន ចាំបាច់ត្រូវធ្វើការពិចារណាសមស្របទៅលើការធានាឱ្យមានការតំណាងប្រកបដោយសមភាពសម្រាប់តំបន់ផ្សេងៗគ្នាទូទាំងពិភពលោក។

## បញ្ញត្តិ ២២_ លំដាប់លំដោយ និងពេលកំណត់សម្រាប់សុន្ទរកថា

២២.១ ប្រធានស្ថាប័នត្រូវអញ្ជើញអ្នកត្រូវឡើងមានមតិឱ្យឡើងតាមលំដាប់លំដោយ ដោយមានបញ្ជាក់ពីបំណងដែលអ្នកទាំងនោះត្រូវលើកឡើងផងដែរ។

២២.២ ប្រធានអាចកំណត់ពេលវេលា ដែលត្រូវអនុញ្ញាតឱ្យអ្នកឡើងមានមតិម្នាក់ៗប្រសិនបើកាលៈទេសៈតម្រូវ។

២២.៣ អ្នកតំណាងរបស់អង្គការ បុគ្គល និងអ្នកសង្កេតការណ៍ ដែលបានលើកឡើង នៅក្នុងបញ្ញត្តិ ៦, ៧ និង ៨ អាចថ្លែងទៅកាន់អង្គប្រជុំតែក្នុងករណីដែលមានការយល់ព្រមជាមុនពីប្រធាន។

២២.៤ អ្នកតំណាងរបស់រដ្ឋភាគី ទោះបីជា ឬមិនមែនជាសមាជិករបស់គណៈ កម្មាធិការនោះក៏ដោយ គឺមិនត្រូវនិយាយគាំទ្រសេចក្តីសន្និដ្ឋាននៅក្នុងបញ្ជី ដែលបានលើកឡើងនៅក្នុងមាត្រា ១៦ និង ១៧ នៃអនុសញ្ញាស្តីពីបេតិកភណ្ឌវប្បធម៌អរូបិយដែលបានតែងតាំងដោយរដ្ឋនោះ ឬ ផ្តល់ការអនុម័តលើសំណើសុំជំនួយដែលធ្វើឡើងដោយរដ្ឋនោះឡើយ គឺពួកគេមានសិទ្ធិត្រឹមតែផ្តល់ព័ត៌មានឆ្លើយតបទៅនឹងសំណួរ ដែលបានលើកឡើងប៉ុណ្ណោះ។ បញ្ញត្តិដែលត្រូវដាក់ឱ្យអនុវត្តចំពោះអ្នកសង្កេតការណ៍ទាំងអស់មានចែងនៅក្នុងបញ្ញត្តិ ៨។

## បញ្ញត្តិ ២៣_ ឯកសារសំណើ

តបតាមសំណើរបស់សមាជិកណាមួយនៃគណៈកម្មាធិការ ដោយមានការគាំទ្រពីសមាជិកពីរផ្សេងទៀតកិច្ចពិភាក្សាអំពីសំណើច្បាប់សំខាន់ៗ ដំណោះស្រាយ ឬ ការធ្វើវិសោធនកម្មនឹងត្រូវពន្យារហូតទាល់តែឯកសារនោះត្រូវបានចែកជូនជា ភាសាផ្លូវការដល់ដែសមាជិកនៃគណៈកម្មាធិការទាំងអស់ដែលមានវត្តមាន។

## បញ្ញត្តិ ២៤_ ការបែងចែកសំណើ

ផ្នែកផ្សេងៗនៃសំណើមួយនឹងត្រូវធ្វើការបោះឆ្នោតដាច់ដោយឡែកពីគ្នា ប្រសិនបើសមាជិកមួយរបស់គណៈកម្មាធិការស្នើសុំឱ្យធ្វើការបែងចែកសំណើនោះ។ ផ្នែកទាំងឡាយនៃសំណើដែលត្រូវបានអនុម័តដោយការបោះឆ្នោតដោយឡែកៗពីគ្នានោះ នឹងត្រូវដាក់ឱ្យធ្វើការបោះឆ្នោតជារួម។ ប្រសិនបើផ្នែកដែលដំណើរការនានា នៅក្នុងសំណើមួយត្រូវបានច្រានចោល សំណើនោះនឹងត្រូវចាត់ទុកថាបានច្រានចោលទាំងស្រុង។

## បញ្ញត្តិ ២៥_ ការបោះឆ្នោតលើការធ្វើវិសោធនកម្ម

២៥.១ ប្រសិនបើមានការស្នើសុំឱ្យធ្វើវិសោធនកម្មទៅលើសំណើមួយ ការធ្វើវិសោធនកម្មនោះនឹងត្រូវដាក់ឱ្យបោះឆ្នោតមុន។ ប្រសិនបើមានការស្នើឱ្យធ្វើវិសោធនកម្មពីរ ឬ ច្រើនទៅលើសំណើមួយ អង្គសន្និបាតត្រូវធ្វើការបោះឆ្នោតជាមុនទៅលើវិសោធនកម្មណាដែលប្រធានសន្និបាតយល់ឃើញថា ត្រូវការលុបផ្នែកផ្សេងច្រើនបន្ថែមទៀតចេញពីសំណើដើម ហើយបន្ទាប់មកការធ្វើវិសោធនកម្ម ដែលត្រូវការលុបផ្នែកផ្សេងច្រើនបន្ថែមទៀតដោយត្រូវធ្វើបន្តបន្ទាប់មកទៀតរហូតទាល់តែវិសោធនកម្មទាំងអស់ត្រូវបានដាក់ឱ្យបោះឆ្នោតសម្រេចចុងក្រោយ។

២៥.២ ប្រសិនបើការធ្វើវិសោធនកម្មមួយ ឬ ច្រើនត្រូវបានអនុម័តសំណើដែលត្រូវបានធ្វើវិសោធនកម្មនោះនឹងត្រូវដាក់ឱ្យបោះឆ្នោតជារួម តែម្តង។

២៥.៣ ការស្នើច្បាប់នឹងត្រូវចាត់ទុកថាជាការធ្វើវិសោធនកម្មទៅលើសំណើមួយ ប្រសិនបើវាតម្រូវឱ្យបន្ថែម លុបចោល ឬ ពិនិត្យកែសម្រួលឡើងវិញលើផ្នែកណាមួយនៃសំណើនោះ។

## បញ្ញត្តិ ២៦_ ការបោះឆ្នោតលើសំណើ

ប្រសិនបើមានសំណើពីរ ឬ ច្រើនពាក់ព័ន្ធនឹងសំណួរតែមួយ គណៈកម្មាធិការត្រូវបោះឆ្នោតលើសំណើទាំងអស់តាមលំដាប់នៃសំណើដែលគេបានបញ្ជូនមក ប្រសិនបើគ្មានការសម្រេចណាផ្សេង។

បន្ទាប់ពីការបោះឆ្នោតនីមួយៗទៅលើសំណើមួយ គណៈកម្មាធិការនឹងធ្វើការសម្រេចថាតើត្រូវបោះឆ្នោតទៅលើសំណើបន្ទាប់ទៀត ឬ អត់។

**បញ្ញត្តិ ២៧- ការដកសំណើ**

អ្នកដាក់សំណើ អាចដកសំណើរបស់ខ្លួនវិញបាន នៅពេលណាមួយមុនការបោះឆ្នោតទៅលើសំណើនោះបានចាប់ផ្តើម ឬ ប្រសិនបើសំណើនោះមិនទាន់បានធ្វើវិសោធនកម្មនៅឡើយ។ សំណើដែលបានដកអាចដាក់សារជាថ្មីបានដោយរដ្ឋសមាជិកផ្សេងទៀតរបស់គណៈកម្មាធិការ។

**បញ្ញត្តិ ២៨- បញ្ហានៃនីតិវិធី**

២៨.១ ក្នុងអំឡុងពេលពិភាក្សា រដ្ឋសមាជិកអាចលើកឡើងនូវបញ្ហានៃនីតិវិធី ហើយបញ្ហានៃនីតិវិធីនោះនឹងត្រូវធ្វើការសម្រេចភ្លាមៗដោយប្រធាន។

២៨.២ ការប្តឹងជំទាស់ អាចនឹងធ្វើឡើងប្រឆាំងទៅនឹងការសម្រេចរបស់ប្រធានគណៈកម្មាធិការ។ ការបណ្តឹងជំទាស់បែបនេះត្រូវយកមកធ្វើការបោះឆ្នោតភ្លាមៗ ហើយការសម្រេចរបស់ប្រធានត្រូវព្យួរមួយរយៈរហូតទាល់តែមានការកែប្រែ។

**បញ្ញត្តិ ២៩- សំណើនីតិវិធី**

ក្នុងអំឡុងពេលពិភាក្សាលើបញ្ហាណាមួយ រដ្ឋសមាជិកនៃគណៈកម្មាធិការអាចស្នើសុំច្បាប់ ដូចជា ៖ សុំព្យួរ ឬលើកកិច្ចប្រជុំ លើកកិច្ចពិភាក្សា ឬការបិទការពិភាក្សា។

**បញ្ញត្តិ ៣០- ការព្យួរ ឬការលើកការប្រជុំ**

ក្នុងអំឡុងពេលពិភាក្សាលើបញ្ហាណាមួយ រដ្ឋសមាជិករបស់គណៈកម្មាធិការអាច ស្នើសុំព្យួរ ឬ លើកការប្រជុំទៅពេលក្រោយ។ សំណើច្បាប់បែបនេះត្រូវដាក់ ឱ្យធ្វើការបោះឆ្នោតសម្រេចភ្លាមៗ ដោយមិនចាំបាច់មានការពិភាក្សាឡើយ។

**បញ្ញត្តិ ៣១- ការលើកកិច្ចពិភាក្សា**

ក្នុងអំឡុងពេលពិភាក្សាលើបញ្ហាណាមួយ រដ្ឋសមាជិករបស់គណៈកម្មាធិការអាចស្នើសុំលើកកិច្ចពិភាក្សាលើបញ្ហាណាមួយដែលត្រូវលើកមកពិភាក្សានោះ។ នៅក្នុងសំណើសុំលើកពេលនោះ រដ្ឋសមាជិកត្រូវបង្ហាញថាតើត្រូវលើកពេលដោយគ្មានកាលកំណត់ ឬ លើកទៅពេលជាក់លាក់ណាមួយដែល

ខ្លួនត្រូវបញ្ជាក់។ បន្ថែមលើអ្នកលើកសំណើនោះ អាចមានមនុស្សម្នាក់ឡើងមានមតិគាំទ្រ ហើយម្នាក់ទៀតឡើងមានមតិជំទាស់នឹងការលើកសំណើនោះ។

### បញ្ញត្តិ ៣២_ ការបិទកិច្ចពិភាក្សា

រដ្ឋសមាជិកមួយ នៃគណៈកម្មាធិការអាចស្នើសុំឱ្យធ្វើការបិទកិច្ចពិភាក្សា នៅពេលណាមួយដោយមិនគិតថា តើមាន ឬ គ្មានអ្នកចង់មានមតិណាម្នាក់បានបញ្ជាក់រួច ហើយនូវបំណងរបស់ខ្លួនដែលគាត់ចង់ចូលរួមក្នុងការពិភាក្សានោះឡើយ។ ប្រសិនបើមានការអនុញ្ញាតឱ្យឡើងបញ្ចេញមតិជំទាស់ទៅនឹងការបិទនេះ អ្នកឡើងបញ្ចេញមតិ គឺត្រូវកំណត់ចំនួនមិនឱ្យលើសពី ២ រូបឡើយ។ នៅពេលនោះប្រធានត្រូវដាក់សំណើសុំបិទកិច្ចពិភាក្សានោះដោយធ្វើការបោះឆ្នោតសម្រេច ហើយប្រសិនបើគណៈកម្មាធិការគាំទ្រសំណើនោះ ប្រធានគណៈកម្មាធិការត្រូវ ប្រកាសបិទកិច្ចពិភាក្សា។

### បញ្ញត្តិ ៣៣_ លំដាប់លំដោយនៃសំណើនិតិវិធី

ស្ថិតក្រោមបញ្ញត្តិ ២៨ សំណើច្បាប់ដូចខាងក្រោមមានសារៈសំខាន់ណាស់ ដោយត្រូវរៀបរាំតាមលំដាប់លំដោយដូចខាងក្រោម ហើយគ្រប់សំណើ និងសំណើនិតិវិធីទាំងអស់ ត្រូវធ្វើឡើងមុនពេលបើកកិច្ចប្រជុំ:

ក. សំណើសុំព្យួរកិច្ចប្រជុំ
ខ. សំណើសុំលើកកិច្ចប្រជុំ
គ. សំណើសុំលើកកិច្ចពិភាក្សាអំពីសំណួរដែលត្រូវធ្វើការពិភាក្សា
ឃ. សំណើសុំបិទកិច្ចពិភាក្សាអំពីសំណួរដែលត្រូវធ្វើការពិភាក្សា។

### បញ្ញត្តិ ៣៤_ សេចក្តីសម្រេច

៣៤.១ គណៈកម្មាធិការត្រូវអនុម័តលើសេចក្តីសម្រេច និងអនុសាសន៍ទាំងឡាយដែលខ្លួនយល់ថាសមស្រប។

៣៤.២ ឯកសារស្តីពីការសម្រេចនីមួយៗគឺត្រូវអនុម័តនៅចុងបញ្ចប់នៃកិច្ចពិភាក្សានៃរបៀបវារៈនោះ។

## VII. ការបោះឆ្នោត

### បញ្ញត្តិ ៣៥_ សិទ្ធិបោះឆ្នោត

រដ្ឋសមាជិកនីមួយៗរបស់គណៈកម្មាធិការ ត្រូវមានសម្លេងឆ្នោតមួយនៅក្នុងគណៈ កម្មាធិការ។

### បញ្ញត្តិ ៣៦_ ដំណើរការក្នុងពេលបោះឆ្នោត

បន្ទាប់ពីប្រធានបានប្រកាសចាប់ផ្ដើមធ្វើការបោះឆ្នោត គ្មានជនណាម្នាក់អាចរំខានការបោះឆ្នោតបានឡើយ លើកលែងតែអ្នកនោះជារដ្ឋសមាជិករបស់គណៈកម្មាធិការពាក់ព័ន្ធទៅនឹងបញ្ហានៃនីតិវិធីនៃដំណើការជាក់ស្ដែងនៃការបោះឆ្នោត នោះ។

### បញ្ញត្តិ ៣៧_ សម្លេងភាគច្រើន

លើកលែងតែមានបញ្ជាក់នៅក្នុងបញ្ញត្តិទាំងនេះ បើមិនដូច្នេះទេសេចក្ដីសម្រេចទាំងអស់របស់គណៈកម្មាធិការត្រូវធ្វើឡើងដោយផ្អែកលើមតិភាគច្រើននៃរដ្ឋសមាជិកដែលមានវត្តមាន និងបានបោះ ឆ្នោត។

### បញ្ញត្តិ ៣៨_ ការរាប់សន្លឹកឆ្នោត

សម្រាប់គោលបំណងនៃបញ្ញត្តិទាំងនេះ ការកំណត់ថា "រដ្ឋសមាជិកមានវត្តមាន និងបានបោះឆ្នោត" គឺសំដៅលើ រដ្ឋសមាជិកដែលបានបោះឆ្នោតគាំទ្រ ឬ បដិសេធន៏។ រដ្ឋសមាជិកដែលបោះឆ្នោតអនុបវាទគឺត្រូវបានចាត់ទុកថា មិនបាន បោះឆ្នោត។

### បញ្ញត្តិ ៣៩_ ការបោះឆ្នោតដោយលើកដៃ

៣៩.១ ជាទូទៅ ការបោះឆ្នោត គឺធ្វើឡើងដោយការលើកដៃ។

៣៩.២ ប្រសិនបើមានភាពមិនច្បាស់ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតដោយ ការលើកដៃនោះ ប្រធាននឹងរៀបចំការបោះឆ្នោតលើកទី ២ ដោយការហៅ ឈ្មោះបញ្ជីវត្តមានម្ដង។

៣៩.៣ ការបោះឆ្នោតដោយហៅឈ្មោះក៏អាចធ្វើទៅបានផងដែរ ប្រសិនបើមានការស្នើឡើងពីរដ្ឋសមាជិកពីរ ឬ ច្រើនរបស់គណៈកម្មាធិការនៅមុនពេល ការបោះឆ្នោតចាប់ផ្ដើម។

## VIII. លេខាធិការដ្ឋានរបស់គណៈកម្មាធិការ

### បញ្ញត្តិ ៤០_ លេខាធិការដ្ឋាន

៤០.១ គណៈកម្មាធិការត្រូវមានការជួយជ្រោមជ្រែងពីលេខាធិការដ្ឋានរបស់អង្គការ យូណេស្កូ (មាត្រា ១០.១ នៃអនុសញ្ញា)។

៤០.២ អគ្គនាយក ឬ អ្នកតំណាងរបស់គាត់ត្រូវចូលរួមនៅក្នុងការងាររបស់គណៈកម្មាធិការ និងការងាររបស់ស្ថាប័នផ្ដល់ប្រឹក្សាបណ្ដោះអាសន្ន និងស្ថាប័នសាខា ប៉ុន្តែគាត់គ្មានសិទ្ធិបោះឆ្នោតឡើយ។ គាត់អាចថ្លែងការណ៍ដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរនៅពេលណាមួយអំពីចម្ងល់ណាមួយ ដើម្បី ធ្វើការពិចារណា។

៤០.៣ អគ្គនាយកត្រូវតែងតាំងមន្ត្រីមួយរូបនៅក្នុងលេខាធិការដ្ឋានរបស់អង្គការ យូណេស្កូ ឱ្យធ្វើជាលេខារបស់គណៈកម្មាធិការ និងតែងតាំងមន្ត្រីផ្សេងៗ ទៀតឱ្យរួមបង្កើតលេខាធិការដ្ឋានរបស់គណៈកម្មាធិការ។

៤០.៤ លេខាធិការដ្ឋានត្រូវទទួលបកប្រែ និងចែកចាយឯកសារផ្លូវការទាំងអស់របស់គណៈកម្មាធិការ ហើយត្រូវរៀបចំការងារបកប្រែនៅក្នុងការពិភាក្សា ដូចមានចែងនៅក្នុងបញ្ញត្តិ ៤៣។

៤០.៥ លេខាធិការដ្ឋាន ត្រូវអនុវត្តភារកិច្ចសំខាន់ៗទាំងអស់ផ្សេងៗទៀត ដើម្បីឱ្យដំណើរការការងាររបស់គណៈកម្មាធិការមានភាពល្អប្រសើរ។

## IX. ភាសាផ្លូវការនិងរបាយការណ៍

### បញ្ញត្តិ ៤១_ ភាសាផ្លូវការ

៤១.១ ភាសាផ្លូវការរបស់គណៈកម្មាធិការ គឺភាសាអង់គ្លេស និងភាសាបារាំង។ កិច្ចខិតខំប្រឹងប្រែងនានាត្រូវធ្វើឡើង រួមទាំងតាមរយៈការផ្ដល់មូលនិធិបន្ថែម ដើម្បីជួយសម្រួលដល់ការប្រើប្រាស់ភាសាផ្លូវការផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ឱ្យទៅជាភាសាដែលប្រើការ។ ដោយឡែកប្រទេស ម្ចាស់ផ្ទះត្រូវជួយសម្រួលចំពោះការប្រើប្រាស់ភាសារបស់ខ្លួនផ្ទាល់។

៤១.២ សេចក្ដីថ្លែងការណ៍ដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ ដោយប្រើភាសាមួយក្នុងចំណោមភាសាផ្លូវការទាំងនោះ គឺត្រូវបកប្រែទៅ ជាភាសាផ្សេងទៀត។

៤១.៣ ទោះបីជាយ៉ាងនេះក៏ដោយ អ្នកថ្លែងការណ៍អាចប្រើភាសាផ្សេងណាមួយក៏បាន ប៉ុន្តែគេត្រូវរៀបចំដោយខ្លួនឯងនូវការងារបកប្រែសេចក្ដីថ្លែងការណ៍ខ្លួនឱ្យទៅជាភាសាផ្លូវការទាំង នោះ។

៤១.៤ ឯកសាររបស់គណៈកម្មាធិការត្រូវធ្វើឡើងជាពីរភាសា គឺភាសាអង់គ្លេស និងភាសាបារាំង។

**បញ្ញត្តិ ៤២_ កាលបរិច្ឆេទចែកចាយឯកសារ**

ឯកសារពាក់ព័ន្ធនឹងខ្លឹមសារស្តីពីរបៀបវារៈបណ្តោះអាសន្ននៃសម័យប្រជុំនីមួយៗ របស់គណៈកម្មាធិការ ត្រូវចែកចាយទៅឱ្យសមាជិកទាំងអស់របស់គណៈកម្មាធិការជាភាសាផ្លូវការទាំងពីរយ៉ាងតិច៤សប្តាហ៍ មុនពេលចាប់ផ្តើមសម័យប្រជុំ។ ឯកសារទាំងនោះ ត្រូវចែកចាយតាមប្រព័ន្ធអេឡិចត្រូនិចទៅអង្គការ ដែលមានការទទួលស្គាល់ ស្ថាប័នសាធារណៈ ឬ ស្ថាប័នឯកជន និងបុគ្គលឯកជនដែលត្រូវបាន អញ្ជើញឱ្យចូលរួមក្នុងសម័យប្រជុំ និងចែកចាយទៅរដ្ឋភាគីដែលមិនមែនជាសមាជិករបស់គណៈ កម្មាធិការ។

**បញ្ញត្តិ ៤៣_ របាយការណ៍សម័យប្រជុំ**

នៅពេលបញ្ចប់សម័យប្រជុំនីមួយៗ គណៈកម្មាធិការត្រូវអនុម័តលើរបាយការណ៍របស់ខ្លួនក្នុងទម្រង់ ជាបញ្ជីនៃសេចក្តីសម្រេច។ របាយការណ៍នេះត្រូវបោះពុម្ពជាពីរភាសាផ្លូវការនៅក្នុងខែបន្ទាប់ពីបិទ សម័យប្រជុំដែលបានលើកឡើងនោះ។

**បញ្ញត្តិ ៤៤_ កំណត់ហេតុសង្ខេប**

លេខាធិការដ្ឋានត្រូវរៀបចំកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំរបស់គណៈកម្មាធិការដើម្បីសុំការឯកភាព នៅពេលបើកសម័យប្រជុំលើកក្រោយ។

**បញ្ញត្តិ ៤៥_ ការទំនាក់ទំនងនៃការងាររៀបចំឯកសារ**

អគ្គនាយកត្រូវបញ្ជូនបញ្ជីនៃសេចក្តីសម្រេច និងកំណត់ហេតុសង្ខេបចុងក្រោយនៃកិច្ចពិភាក្សានៅក្នុង កិច្ចប្រជុំជាសាធារណៈទៅឱ្យសមាជិកនៃគណៈកម្មាធិការ រដ្ឋភាគីទាំងអស់នៃអនុសញ្ញា អង្គការ ដែលបានទទួលស្គាល់ ស្ថាប័នសាធារណៈ ឬ ស្ថាប័នឯកជន និងបុគ្គលឯកជនដែលបានអញ្ជើញឱ្យចូល រួមក្នុងសម័យប្រជុំ នោះ។

**បញ្ញត្តិ ៤៦_ របាយការណ៍ដាក់ជូនមហាសន្និបាតនៃរដ្ឋភាគី និង មហា សន្និបាទរបស់អង្គការ យូណេស្កូ**

៤៦.១ គណៈកម្មាធិការត្រូវដាក់របាយការណ៍ស្តីអំពីសកម្មភាព និងសេចក្តីសម្រេចរបស់ខ្លួនជូន មហាសន្និបាតនៃរដ្ឋភាគីនៅពេលរៀបចំសម័យប្រជុំសាមញ្ញនីមួយៗ និងដាក់ជូនមហាសន្និ បាតរបស់អង្គការ យូណេស្កូ នៅពេលរៀបចំសម័យប្រជុំសាមញ្ញនីមួយៗដើម្បីពិនិត្យ (មាត្រា ៣០.២ នៃ អនុសញ្ញា)។

៤៦.២ គណៈកម្មាធិការ អាចនឹងផ្តល់សិទ្ធិជូនប្រធានរបស់ខ្លួន ឱ្យបញ្ជូនរបាយការណ៍ទាំងនេះក្នុងនាមគណៈកម្មាការតែម្តង។

៤៦.៣ ច្បាប់ថតចម្លងនៃរបាយការណ៍ទាំងនេះនឹងត្រូវផ្ញើទៅឱ្យរដ្ឋភាគីទាំង អស់នៃអនុសញ្ញា។

## X. ការអនុម័ត ការធ្វើវិសោធនកម្ម ការព្យួរបញ្ញត្តិនៃនីតិវិធី

### បញ្ញត្តិ ៤៧_ ការអនុម័ត

គណៈកម្មាធិការត្រូវអនុម័តបញ្ញត្តិនៃនីតិវិធីរបស់ខ្លួនដោយមតិ ២/៣ នៃសមាជិក ដែល មានវត្តមាន និងបានបោះឆ្នោត (មាត្រា ៨.២ នៃអនុសញ្ញា)។

### បញ្ញត្តិ ៤៨_ ការធ្វើវិសោធនកម្ម

លើកលែងតែបញ្ញត្តិនៃនីតិវិធីនោះបង្កើតជាបទបញ្ញត្តិនៃអនុសញ្ញា បើមិនដូច្នោះទេ គណៈកម្មាធិការអាចធ្វើវិសោធនកម្មទៅលើបញ្ញត្តិនៃនីតិវិធីទាំងនោះបាន ដោយផ្អែកលើសេចក្តីសម្រេចធ្វើឡើងក្នុងកិច្ចប្រជុំពេញអង្គ ដោយមតិភាគច្រើន ២/៣ នៃរដ្ឋសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត ប្រសិនបើការធ្វើវិសោធ នកម្មដែលបានស្នើឡើងនោះត្រូវបានដាក់បញ្ចូលនៅក្នុងរបៀបវារៈនៃសម័យប្រជុំស្រប តាមបញ្ញត្តិ ៩ និង១០។

### បញ្ញត្តិ ៤៩_ ការព្យួរ

លើកលែងតែបញ្ញត្តិនៃនីតិវិធីនោះបង្កើតជាបទបញ្ញត្តិនៃអនុសញ្ញា បើមិនដូចច្នោះទេ គណៈកម្មាធិការអាចព្យួរការដាក់ឱ្យអនុវត្តបញ្ញតិណាមួយនៃនីតិវិធីទាំងនេះ ដោយផ្អែកលើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំពេញអង្គ ដោយមតិភាគច្រើន២/៣ នៃ រដ្ឋសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត។

# បទបញ្ញត្តិហិរញ្ញវត្ថុនៃគណនេយ្យពិសេសសម្រាប់បេតិកភណ្ឌអរូបិយ

បានអនុម័តដោយគណៈកម្មាធិការនៅក្នុងសម័យប្រជុំវិសាមញ្ញលើកទី ១ របស់ខ្លួន (នៅ Chengdu ប្រទេសចិន ពីថ្ងៃទី ២៣ ដល់ ២៧ ខែឧសភា ឆ្នាំ ២០០៧)។

### មត្រា ១_ ការបង្កើតគណនីពិសេសសម្រាប់បេតិកភណ្ឌអរូបិយ

១.១ មាត្រា ២៥ នៃអនុសញ្ញាសម្រាប់អភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយ (ដែលហៅថា "អនុសញ្ញា" បានបង្កើតមូលនិធិមួយមានឈ្មោះថា មូលនិធិ សម្រាប់អភិរក្សបេតិកភណ្ឌវប្ប

ធម៌អរូបិយ (ដែលគេហៅថា 'មូលនិធិ ')។ ដោយសារវាជាមូលនិធិដែលមានលក្ខណៈជាម្ចាស់ជំនួយចម្រុះជាតិសាសន៍ មូលនិធិនេះនឹងត្រូវគ្រប់គ្រងជារបៀបគណនីពិសេសមួយ។

១.២ យោងតាមមាត្រា ៦.៦ នៃបញ្ញត្តិហិរញ្ញវត្ថុរបស់អង្គការ យូណេស្កូ គណនីពិសេសមួយត្រូវបានបង្កើតឡើងធ្វើជាមូលនិធិសម្រាប់ភាគីបេតិកភណ្ឌវប្បធម៌អរូបិយ (ដែលហៅថា "គណនីពិសេស")។

១.៣ បញ្ញត្តិខាងក្រោមនេះត្រូវគ្រប់គ្រងលើប្រតិបត្តិការនៃគណនីពិសេសនេះ។

### មាត្រា ២_ អំឡុងពេលប្រតិបត្តិហិរញ្ញវត្ថុ

អំឡុងពេលប្រតិបត្តិហិរញ្ញវត្ថុត្រូវស្របគ្នាទៅនឹងអំឡុងពេលប្រតិបត្តិហិរញ្ញវត្ថុរបស់អង្គការ យូណេស្កូ។

### មត្រា ៣_ គោលបំណង

គោលបំណងនៃគណនីពិសេសនេះ គឺដើម្បីទទួលបាននូវប្រាក់វិភាគទានពីប្រភពផ្សេងៗដែលមានបង្ហាញនៅក្នុងមាត្រា ៤.១ ខាងក្រោម និងសម្រាប់ចំណាយក្នុងការជួយអភិរក្សបេតិកភណ្ឌវប្បធម៌អរូបិយអនុលោមទៅតាមល័ក្ខខ័ណ្ឌនៃអនុសញ្ញា និងបទបញ្ញត្តិនាពេលបច្ចុប្បន្ន។

### មាត្រា ៤_ ប្រាក់ចំណូល

៤.១ យោងតាមមាត្រា ២៥.៣ នៃអនុសញ្ញានេះ ប្រាក់ចំណូលរបស់គណនី ពិសេសរួមមាន:

ក. ប្រាក់វិភាគទានផ្តល់ដោយរដ្ឋភាគីនៃអនុសញ្ញា ស្របតាមមាត្រា ២៦

ខ. មូលនិធិដែលរៀបចំដោយមហាសន្និបាតអង្គការ យូណេស្កូសម្រាប់ គោលបំណងនេះ

គ. ប្រាក់វិភាគទាន អំណោយ ឬទ្រព្យសម្បត្តិដែលផ្តល់ឱ្យដោយ:

(i) រដ្ឋផ្សេងៗ

(ii) អង្គការ និងកម្មវិធីក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ ជាពិសេសកម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ ព្រមទាំងអង្គការអន្តរជាតិផ្សេងៗទៀត

(iii) ស្ថាប័នសាធារណៈ ឬស្ថាប័នឯកជន ឬបុគ្គលទាំងឡាយ

ឃ. ការប្រាក់ត្រូវបង់លើធនធានផ្សេងរបស់គណនីពិសេស

ង. មូលនិធិទទួលបានពីការរៃអង្គាស និងទទួលប្រាក់ពីក្នុងពិធីផ្សេងៗដែលរៀបចំឡើងសម្រាប់ផលប្រយោជន៍របស់គណនីពិសេស

ច. ប្រភពផ្សេងៗទៀតដែលមានការអនុញ្ញាតពីគណៈកម្មាធិការ។

៤.២ ដូចមានចែងនៅក្នុងមាត្រា ២៦.១ នៃអនុសញ្ញានេះ ប្រាក់វិភាគទានរបស់រដ្ឋភាគីដែលមិនបានប្រកាសស្របតាមមាត្រា ២៦.២ នៃអនុសញ្ញានេះ ត្រូវផ្តល់ជូនទៅតាមភាគរយស្មើៗគ្នាដូចដែលបានកំណត់ដោយមហាសន្និបាតនៃរដ្ឋភាគីនៃអនុសញ្ញានេះ។

**មាត្រា ៥_ ការចំណាយ**

៥.១ យោងទៅលើមាត្រា ២៥.៤ នៃអនុសញ្ញា ការប្រើប្រាស់ធនធានផ្សេងៗ នៅក្នុងគណនីពិសេសនេះដោយគណៈកម្មាធិការ ត្រូវធ្វើការសម្រេចដោយផ្អែកលើគោលការណ៍ណែនាំជាមូលដ្ឋានដែលដាក់ចេញដោយមហាសន្និបាត។

៥.២ គណនីពិសេសនេះ នឹងត្រូវកត់ត្រាឥណពន្ធជាមួយនឹងការចំណាយពាក់ព័ន្ធនឹងគោលបំណងរបស់ខ្លួនដូចមានចែងក្នុងមាត្រា ៣ ខាងលើ ដោយរួមទាំងការចំណាយផ្នែករដ្ឋបាលផ្ទាល់ជាពិសេសពាក់ព័ន្ធនឹងការងាររដ្ឋ បាល។

៥.៣ ខ្ទង់ចំណាយត្រូវធ្វើឡើងនៅក្នុងវង្វង់ដែនកំណត់នៃមូលនិធិដែលមាន។

**មាត្រា ៦_ មូលនិធិបម្រុង**

នៅក្នុងគណនីពិសេសនេះ គឺមានបង្កើតមូលនិធិបម្រុងមួយ ដើម្បីបំពេញតាមសំណើសុំជំនួយក្នុងករណីមានបញ្ហាបន្ទាន់ខ្លាំង ដូចបានប្រមើលជាមុននៅក្នុង មាត្រា ១៧.៣ និង ២២.២ នៃអនុសញ្ញានេះ។ ចំនួនទឹកប្រាក់បម្រុង គឺត្រូវកំណត់ដោយគណៈកម្មាធិការតែម្តង។

**មាត្រា ៧_ គណនេយ្យ**

៧.១ អ្នកត្រួតពិនិត្យគណនេយ្យរបស់អង្គការយូណេស្កូត្រូវរក្សារបាយការណ៍គណនេយ្យនេះជាចាំបាច់។

៧.២ សម្រាប់សមតុល្យដែលមិនបានប្រើប្រាស់នៅចុងបញ្ចប់នៃអំឡុងពេលប្រតិបត្តិហិរញ្ញវត្ថុត្រូវលើកយកទៅប្រើក្នុងអំឡុងពេលប្រតិបត្តិហិរញ្ញវត្ថុ លើកក្រោយ។

៧.៣ គណនេយ្យនៃគណនេយ្យពិសេសនេះត្រូវដាក់ជូនសវនករខាងក្រៅរបស់អង្គការ យូណេស្កូ ដើម្បីធ្វើ សវនកម្ម រួមជាមួយនឹងគណនេយ្យផ្សេងៗរបស់អង្គការផងដែរ។

៧.៤ ប្រាក់វិភាគទានមនុស្សធម៌ត្រូវកត់ត្រាដោយឡែកពីគណនីពិសេស។

៧.៥ អគ្គនាយកត្រូវដាក់គណនេយ្យទាំងអស់ជូនមហាសន្និបាតនៃរដ្ឋភាគីនៃអនុសញ្ញាដើម្បីពិនិត្យ។

**មាត្រា ៨_ វិនិយោគទុន**

៨.១ អគ្គនាយកអាចធ្វើការវិនិយោគរយៈពេលខ្លីនៃចំនួនទឹកប្រាក់អចិន្ត្រៃយ៍និងផ្តល់ឥណទានដល់គណនីពិសេស។

៨.២ ការប្រាក់ដែលទទួលបានពីការវិនិយោគទាំងនេះត្រូវផ្តល់ឥណទានចូលក្នុងគណនីពិសេស។

**មាត្រា ៩_ បញ្ញត្តិទូទៅ**

លើកលែងតែមានចែងនៅក្នុងបទបញ្ញត្តិទាំងនេះ បើមិនដូច្នោះទេគណនីពិសេសនេះត្រូវធ្វើការគ្រប់គ្រងស្របតាមបទបញ្ញត្តិហិរញ្ញវត្ថុរបស់អង្គការ យូណេស្កូ។

# បែបបទគំរូនៃការផ្ញើសច្ចាប័ន/ការទទួលយក/ការអនុម័ត/ការយល់ព្រម

យើង.................................................................................................

*(ឈ្មោះប្រមុខរដ្ឋ ឬ រដ្ឋាភិបាល ឬ រដ្ឋមន្ត្រីការបរទេស)*

នៃ...................................................................................................

*(ឈ្មោះប្រទេស)*

បានឃើញ និងពិនិត្យ **អនុសញ្ញារបស់អង្គការ យូណេស្កូ ស្តីពីការអភិរក្ស បេតិកភណ្ឌវប្បធម៌អរូបិយ (ឆ្នាំ២០០៣)**

តាមរយៈអំណាចដែលបានផ្តល់មកឱ្យយើង យើងបានឯកភាព និងពិតជាឯកភាព លើខ្លឹមសារទាំងមូល និងតាមផ្នែកនីមួយៗស្របតាមបទបញ្ញត្តិនានាដែលមាន ចែង។

យើងសូមប្រកាសថា យើងផ្ញើសច្ចាប័ន/ទទួលយក/អនុម័ត/យល់ព្រម ចំពោះអនុសញ្ញាខាងលើស្រប តាមមាត្រា៣២ និង ៣៣ ហើយអះអាងថាអនុសញ្ញា នេះពិតជា ត្រូវបានពិនិត្យយ៉ាងហ្មត់ចត់

ដើម្បីជាសក្ខីភាព យើងសូមដាក់លិខិតុបករណ៍វង់នេះជាការផ្ញើសច្ចាប័ន/ការទទួលយក/ការអនុម័ត /ការយល់ព្រម ដោយយើងបានបោះត្រាដើម្បីបញ្ជាក់ជាភស្តុតាង។

ផ្ញើនៅ (ទីកន្លែង) .........................................................................

នៅថ្ងៃទី (កាលបរិច្ឆេទ) .................................................................

(ត្រា) (ហត្ថលេខា) ...........................................................

ប្រមុខរដ្ឋ ឬ

ប្រមុខរដ្ឋាភិបាល ឬ

រដ្ឋមន្ត្រីការបរទេស

Section of Intangible Cultural Heritage
Division of Cultural Projects and Intangible Heritage
Culture Sector
UNESCO, Paris

សំណៅដើម៖

Graphic design: Doc Levin/Judith Spinatsch, Marion Duval
Printed by: Albe De Coker, Belgium
©UNESCO, 2009

United Nations
Educational, Scientific and
Cultural Organization

Intangible
Cultural
Heritage

**UNESCO**
**Section of Intangible Cultural Heritage**
**Division of Cultural Projects and Intangible Heritage**
**Culture Sector**

1, rue Miollis
75732 Paris Cedex 15
Tel.: +(33) 1 45 68 42 52
Fax : +(33) 1 45 68 57 52

ISSN: 2072-7909

កូនសៀវភៅនេះអាចប្រែសម្រួលនិងបោះពុម្ពជាភាសាខ្មែរបានដោយសារគម្រោង **MDG-F** ដែលឧបត្ថម្ភថវិកាដោយប្រទេសអេស្ប៉ាញ។

**UNESCO**
**Section of Intangible Cultural Heritage**
**Division of Cultural Projects and Intangible Heritage**
**Culture Sector**

1, rue Miollis
75732 Paris Cedex 15
Tel. : +(33) 1 45 68 42 52
Fax : +(33) 1 45 68 57 52

ISSN: 2072-7909

កូនសៀវភៅនេះអាចប្រែសម្រួលនិងបោះពុម្ពជាភាសាខ្មែរបានដោយសារគម្រោង **MDG-F** ដែលឧបត្ថម្ភដោយប្រទេសអេស្ប៉ាញ។